# សៀវភៅថនិកសត្វ
# ប្រទេសកម្ពុជា

ចងក្រងដោយ :
ម៉ើន សុរិយន់ កែវ អុម៉ាណីស្ស ចក់ សុខវិជ្ជបុត្រ



សៀវភៅនេះ សូមឧទ្ទិសដល់វិញ្ញាណក្ខន្ធលោក **សំ វាសនា** និងលោក **មាស ចិន្តាមុនី** ដែលបានទទួលមរណៈភាព ក្នុងបុព្វហេតុបេសកកម្មសិក្សាស្រាវជ្រាវ និង អភិរក្សសត្វព្រៃនៅប្រទេសកម្ពុជា ។

This book is dedicated to Sam Veasna and Meas Chandamony, both of whom tragically died in the service of wildlife conservation in Cambodia.

សូមថ្លែងអំណរគុណយ៉ាងពិសេសចំពោះ ស្ថានទូតអង់គ្លេសប្រចាំនៅព្រះរាជណាចក្រកម្ពុជា ធនាគារពិភពលោក រដ្ឋាភិបាលប្រទេសហូឡង់ និងកម្មវិធីអាស៊ីរបស់អង្គការ IUCN ដែលបានផ្តល់ឱកាសសំរាប់ការរៀបចំចងក្រងសៀវភៅនេះ ។

Funds for this field guide were provided by The British Embassy, Phnom Penh and the World Bank executed PHRD Project preparation grant for the World Bank/GEF Biodiversity and Protected Areas Management Project. Additional copies have been made possible with funding from the CY 99 Environment Component of the World Bank/Netherlands Partnership Programme, through the IUCN Regional Biodiversity Programme for South and Southeast Asia.

THE WORLD BANK

BRITISH AID

IUCN
The World Conservation Union

JSRC

Printed by JSRC Printing House, Phnom Penh

# សៀវភៅថនិកសត្វប្រទេសកម្ពុជា


ចងក្រងដោយ :

ម៉ែន សុរិយន់ កែវ អូម៉ាលីស្ស ចក់ សុខវិជ្ជបុត្រ

ជំនួយការបន្ថែមដោយ :

រ័ត្ន ប៊ុនធឿន ឈាង ដានី

ហួត ពិសិដ្ឋ ប៊ី សេងលៀង

ព្រុំ សុវណ្ណា



បោះពុម្ពដោយ :

- នាយកដ្ឋានរុក្ខា-ប្រមាញ់
- នាយកដ្ឋានការពារអភិរក្សធម្មជាតិ
- អង្គការសមាគមអភិរក្សសត្វព្រៃ

ភ្នំពេញ, កម្ពុជា

ខែ ឧសភា ឆ្នាំ ២០០០



ម.ឯ.ឯ.ក AIDOC

Code: 173-032

Date:

Donated by:


# Mammals of Cambodia


**Compiled by:**

Men Soriyun, Keo Omaliss, Chak Sokhavicheaboth.

**With contributions by:**

Roth Bunthoeun, Hout Piseth, Prum Sovanna, Chheang Dany and By Seng Leang.



**Published by:**

The Department of Forestry and Wildlife
The Department of Nature Conservation and Protection
and the Wildlife Conservation Society Cambodia Program.

**Phnom Penh, Cambodia.**
**May, 2000.**

# សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅបំផុតចំពោះការផ្ដល់នូវវិភាគទាន ទៅលើការរៀបចំចងក្រងសៀវភៅថនិកសត្វនេះ អោយកាន់តែមានភាពប្រសើរឡើង ។

ជាបឋមសូមថ្លែងអំណរគុណចំពោះលោក **ទី សុគន្ធ** ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ លោក **ម៉ែន ភីមៀន** ប្រធានការិយាល័យការពារសត្វព្រៃ លោក លោក **ចាយ សាមិត្ត** ប្រធាននាយកដ្ឋានការពារអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន **ឡាយ ឃីម** ប្រធានការិយាល័យតំបន់ការពារ ដែលបានគាំទ្រ និងជួយជំរុញការងារចងក្រងបានចប់សព្វគ្រប់ ។

សូមថ្លែងអំណរគុណលោក **Sakon Jaisomkom** បុគ្គលិកអង្គការ **WWF** នៅប្រទេសថៃ ចំពោះការផ្ដល់ការរៀបចំតាក់តែងរូបភាព និងសូមថ្លែងអំណរគុណចំពោះការផ្ដល់រូបថតសត្វរបស់លោក **ស៊ុន ហឿន**, **គែត អូម៉ាលីស្ស**, **Colin Poole, Dave Ware, WWF Cat Tien Project (Gert Polet), WWF-Canon (Mike Baltzer), WCS Thailand (Tony Lynam, Lee Whitehead, Tongbai Chareoendong), Roland Seitre, FAO/CIAP (Luke Leung), Wildlife Conservation Society (Dennis Demello, H. Coolidge), Charles Francis, Heng Sinith, Frédéric Goes, Wayne Gum** និងលោក **Cuc Phuong Conservation Project (Doug Hendrie)**. លើសពីនេះទៀត សូមថ្លែងអំណរគុណលោក **Joe Walston** ចំពោះជំនួយការបច្ចេកទេសទៅលើអំបូរសត្វប្រចៀវ និងលោក **អ៊ុំ ហឿនឈាង** លោក **Will Duckworth, Rob Timmins** ចំពោះការផ្ដល់យោបល់ និង ជំនួយទៅលើការងារជាច្រើនទាក់ទងទៅនឹងការធ្វើអត្តសញ្ញាណកម្មសត្វ និង ស្ថានភាពថនិកសត្វនៅកម្ពុជា ។

សូមថ្លែងអំណរគុណយ៉ាងពិសេសចំពោះស្ថានទូតអង់គ្លេសប្រចាំនៅប្រទេសកម្ពុជា, ធនាគារពិភពលោក រដ្ឋាភិបាលប្រទេសហូឡង់ និងកម្មវិធីអាស៊ីរបស់អង្គការ **IUCN** ដែលបានផ្ដល់ថវិកាសំរាប់ការរៀបចំចងក្រងសៀវភៅ ។ សូមថ្លែងអំណរគុណចំពោះលោក **ឡៅ គីមសុខ**, **សួន ផល្លា**, **ជួន គង់**, **ញ៉ិក រតនៈពេជ្រ**, **គុយ តុខ**, **មាស មិន្ទាមុនី**, **ខាច់ គៀន**, **អ៊ុច សីហា**, **គ្រី ម៉ាក់ផល**, **អ៊ុក គីមសាន**, **ស៊ុន ប៉ុលីន** ដែលបានចូលរួមក្នុងការកំណត់ឈ្មោះប្រភេទសត្វ ។

ជាទីបញ្ចប់ សូមថ្លែងអំណរគុណយ៉ាងពិសេសបំផុត ចំពោះលោក **ស៊ុន ហឿន** និងលោក **Colin Poole** ដែលបាន ផ្ដួចផ្ដើមរៀបចំសៀវភៅថនិកសត្វនៅកម្ពុជា ប្រសិនបើគ្មានអ្នកទាំងពីរទេសៀវភៅនេះក៏មិនអាចកើតមានដែរ ។

# មាតិកា


| | ទំព័រ | | ទំព័រ |
|---|---|---|---|
| I- សេចក្តីផ្តើម | ១ | ខ្លែព្រៃ | ៥០ |
| II-ថនិកសត្វ និង ការកត់សំគាល់ | ៣ | ខ្លាឃ្មុំធំ | ៥២ |
| III-ការស្វែងរក និង ការសិក្សាពីថនិកសត្វ | ៤ | ខ្លាឃ្មុំតូច | ៥៤ |
| ពង្រូល | ៨ | សំពោចកលឿង | ៥៦ |
| កណ្តុរស្មែះ | ១០ | ជ្រូកពោន | ៥៨ |
| កន្ធីក | ១១ | ឆ្កួក | ៦០ |
| កន្ធីកក្បាលឆ្កួត | ១២ | ភេក្បាលសំប៉ែត | ៦២ |
| ឆ្មាបា | ១៤ | ភេរោមច្រមុះ | ៦៤ |
| ជ្រីងកោះ | ១៦ | ភេខ្លួនរលោង | ៦៦ |
| ជ្រីងមធ្យម | ១៦ | ភេតូច | ៦៨ |
| ជ្រីងធំ | ១៨ | ខ្ទីង | ៧០ |
| ជ្រីងអង្កាម | ២០ | សំពោចធំ | ៧២ |
| ប្រចៀវ | ២២ | សំពោចវល្លិ៍ | ៧៤ |
| រញ្ជី | ៣២ | សំពោចក្រអូប | ៧៦ |
| ស្វាត្រោស | ៣៤ | សំពោចពណ៌លាត | ៧៨ |
| ស្វាក្តាម | ៣៦ | ឈ្មុសប្រេង | ៨០ |
| ស្វាអង្កត់ | ៣៨ | សំពោចអុចខ្នង | ៨២ |
| ស្វាព្រាម | ៤០ | កំពីងជ្ញូង | ៨៤ |
| ស្វាក្រវាត់ ឬស្វាកន្ទុយសេ | ៤២ | ស្កាតូច | ៨៦ |
| ទោចម្ពុង | ៤៤ | ស្កាធំ | ៨៨ |
| ទោចថ្កាល់លឿង | ៤៦ | ឆ្មាព្រៃ | ៩០ |
| ខ្លែងចចក | ៤៨ | ឆ្មាដាវ | ៩២ |

ទំព័រ


ខ្លាត្រី -------------------- ៩៤
ខ្លាលឿងមាស -------------------- ៩៦
ខ្លាភ្ញីថ្មកែវ -------------------- ៩៨
ខ្លាពពក -------------------- ១០០
ខ្លាខិន -------------------- ១០២
ខ្លាធំ -------------------- ១០៤
ផ្សោតពណ៌ផ្កាឈូក -------------------- ១០៦
ផ្សោតបង្គិល -------------------- ១០៨
ផ្សោតខ្មៅ-លឿង -------------------- ១១០
ផ្សោតច្រមុះដប -------------------- ១១២
ផ្សោតទន្លេ -------------------- ១១៤
ផ្សោតគ្មានព្រុយខ្នង -------------------- ១១៦
ជ្រូកទឹក -------------------- ១១៨
ឆ្កែព្រៃ -------------------- ១២០
រមាស -------------------- ១២២
ជ្រូកព្រៃ -------------------- ១២៤
ក្ដាន់ញៀងតូច -------------------- ១២៦
ក្ដាន់ញៀងធំ -------------------- ១២៨
រមាំង -------------------- ១៣០
ប្រើសស្បូវ -------------------- ១៣២
ក្ដាន់ -------------------- ១៣៤
ឈ្លូស -------------------- ១៣៦
ឈ្លូសយក្ស -------------------- ១៣៨
គោព្រៃ -------------------- ១៤០
ខ្ទីង -------------------- ១៤២
ទន្សោង -------------------- ១៤៤
ក្របីព្រៃ -------------------- ១៤៦
ខ្ទីងវល្លិ៍ -------------------- ១៤៨
កែះ -------------------- ១៥០
កំប្រុកធំ -------------------- ១៥២
កំប្រុកឆ្នូតខ្នង -------------------- ១៥៤
កំប្រុកពណ៌ -------------------- ១៥៦
កណ្ដិច -------------------- ១៥៨
កង្ហែន -------------------- ១៦០
កំប្រុកស្លាបធំ -------------------- ១៦២
កំប្រុកថ្ពាល់ក្រហម -------------------- ១៦៤
កំប្រុកស្លាបភ្នំ -------------------- ១៦៤
កណ្ដុរផ្ទះ( ឬកណ្ដុរបង្គង់) -------------------- ១៦៦
កណ្ដុរប្រែង -------------------- ១៦៨
កណ្ដុរភ្នំ -------------------- ១៧០
ប្រមាំ -------------------- ១៧២
ប្រមាំញ -------------------- ១៧៤
ទន្សាយគល់ -------------------- ១៧៦
V- សំរាប់ការអានបន្ថែម -------------------- ១៧៨
VI-វិធីសាស្ត្រមើលបញ្ជីឈ្មោះថនិកសត្វ ១៧៩

# I - សេចក្ដីផ្ដើម :

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលសំបូរទៅដោយធនធាន ធម្មជាតិតាំងពីយូរលង់ណាស់មកហើយ ពិសេសគឺលក្ខណៈជីវចំរុះនៃពពួកសត្វព្រៃដែលមាន ថនិកសត្វ បក្សី ឧរង្គសត្វជាដើម ។ លក្ខណៈខុសគ្នានៃសណ្ឋានដី និង របាយទឹកភ្លៀងបានបង្កលក្ខណៈងាយស្រួលដល់ពពួកសត្វព្រៃ អាចរស់នៅបានយ៉ាងសុខក្សេមក្សាន្តនៅតាមជំរកផ្សេងៗគ្នា ពិសេសគឺនៅតាមជួរភ្នំក្រវាញ ភ្នំដងរែក និង តំបន់ភ្នំក្នុងខេត្តរតនគិរី និង មណ្ឌលគិរី ។ តំបន់ដីសើមដែលមានប្រហែល ៣០% នៃផ្ទៃប្រទេស បានបង្ហាញឱ្យឃើញពីការដុះលូតលាស់ឡើងវិញរបស់រុក្ខជាតិដែលជាចំណី របស់ពពួកថនិកសត្វ និង ជាប្រភពទឹកមួយ ដ៏សំខាន់សំរាប់សត្វទាំងនោះ នៅរដូវប្រាំងផងដែរ ។ ជាក់ស្ដែងដូចជាទន្លេមេគង្គ ដែលហូរកាត់ប្រទេសពីទិសខាងជើងរហូតដល់ខាងត្បូង ទន្លេសាបដែលលាតសន្ធឹងពីទីក្រុងភ្នំពេញទៅទិសពាយ័ព្យ និង ដងស្ទឹង អូរ ព្រែក ជាច្រើនទៀត នៅពាសពេញប្រទេស ។

ជាការពិតណាស់ ការយល់ដឹងអំពីថនិកសត្វនៅប្រទេសកម្ពុជា សព្វថ្ងៃនៅមានកំរិតតិចតួចនៅឡើយ ដោយសារតែការខ្វះខាតនូវឯកសារពីមុនសំរាប់ធ្វើការសិក្សាបន្ត និង ឧបសគ្គនៃសង្គ្រាមស៊ីវិលអស់ជាងពីរទសវត្សកន្លងមកនេះបានរាំងដល់ដំណើរការ ការចុះស្រាវជ្រាវក៏ដូចជា ការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ។ម្យ៉ាងទៀត អ្នកសត្វសាស្ត្រជំនាញៗពីសម័យមុន ក៏បានបាត់បង់ទាំងស្រុងថែមទៀត។ សព្វថ្ងៃនេះ ការខិតខំប្រឹងប្រែងលើការស្រាវជ្រាវ ការអភិរក្ស និង គ្រប់គ្រង បានផ្ដួចផ្ដើមឡើងចាប់ពីឆ្នាំ ១៩៩២ ពីសំណាក់អ្នកសត្វសាស្ត្រជំនាន់ក្រោយៗ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ។

ទោះបីជាមានប្រភេទសត្វមួយចំនួនកំពុងប្រឈមមុខទៅនឹង ស្ថានភាពជិតផុតពូជបំផុតក៏ដោយដូចជា រមាស គោព្រៃ ខ្ទីងវល្លិ៍ ក៏អ្នកសត្វសាស្ត្រយើង

នៅតែមានជំនឿទុកចិត្តថា ដរាបណា យើងនៅតែខិតខំប្រឹងប្រែងលើការស្រាវជ្រាវ អោយបានច្រើន និង កំណត់ឱ្យបានច្បាស់លាស់ពីជំរកពិតប្រាកដរបស់សត្វទាំងនោះគឺ យើងនឹងមានផែនការអភិរក្សសមស្របសំរាប់រារាំងនូវសកម្មភាព គំរាមកំហែងទាំង អម្បាលមាណ ដែលកើតមានឡើង ។

សៀវភៅថនិកសត្វនៅកម្ពុជានេះ បានរៀបចំចងក្រងឡើងក្នុងគោល បំណងសំរាប់ផ្តល់ជាវិភាគទានលើការយល់ដឹងមួយចំនួន អំពីលក្ខណៈសំគាល់របស់ ប្រភេទសត្វនីមួយៗ លក្ខណៈជីវសាស្ត្រ ស្ថានភាពច្បាប់ជាតិ និង អន្តរជាតិ របស់ ថនិកសត្វនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប្រភេទសត្វទាំងអស់នេះមិនមែនគ្រប ដណ្តប់លើ ប្រភេទថនិកសត្វទាំងអស់នៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែនៅមានប្រភេទ និង អនុប្រភេទ ជាច្រើនទៀតដែលយើងពុំទាន់បានសិក្សារកឃើញ និងពុំទានមាន ឯកសារច្បាស់លាស់នៅឡើយ ។ ថនិកសត្វ ដែលមានចំនួន៨៨ប្រភេទ បានបង្ហាញ នូវរូបភាពពណ៌ធម្មជាតិច្បាស់ៗ និងការរៀបរាប់ លំអិតពីលក្ខណៈខុសប្លែកគ្នាពិសេស ដែលធ្វើអោយមនុស្សគ្រប់រូប ងាយស្រួលចំណាំ និងរៀនសូត្របន្ថែមពិសេសគឺសំរាប់ អ្នកសត្វសាស្ត្រប្រើប្រាស់ក្នុងការចុះស្រាវជ្រាវ ។

ប្រសិនបើ សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម អស់លោក លោកស្រី អ្នកនាង កញ្ញា បានរកឃើញនូវពត៌មានថ្មី ឬប្រភេទសត្វថ្មី ដែលមិនមាននៅក្នុងសៀវភៅនេះ ឬក៏មានកំហុសឆ្គងណាមួយនៅក្នុងអត្ថបទដែលបានចងក្រង សូមមេត្តាផ្តល់ពត៌មាន មកដល់នាយកដ្ឋានរុក្ខា-ប្រមាញ់ ទូលព្រះបង្គំ យើងខ្ញុំរីករាយ សូមថ្លែងអំណរគុណ និងស្វាគមន៍ជានិច្ច ចំពោះការទិទៀន កែលំអរទាំងអស់ ។ ការកែប្រែ និង ការផ្តល់ ពត៌មានបន្ថែម នឹងអាចជួយសំរួលដល់ការបោះពុម្ព លើកក្រោយៗទៀត អោយកាន់ តែមានសុក្រិតភាព និង ខ្លឹមសារ បានច្បាស់លាស់ ។

**អាស័យដ្ឋានសំរាប់ទំនាក់ទំនងមានដូចខាងក្រោម :**

**នាយកដ្ឋាន រុក្ខា-ប្រមាញ់ :**

អាគារលេខ ៤០ វិថី ព្រះនរោត្តម សង្កាត់ផ្សារថ្មីទី ២

ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**នាយកដ្ឋានការងារអភិរក្សធម្មជាតិ :**

អាគារ ៤៨ វិថីសម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**អង្គការសមាគមអភិរក្សសត្វព្រៃ :**

ផ្ទះលេខ ៤ ផ្លូវលេខ ៣១២ សង្កាត់ទន្លេបាសាក់

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## II - ថនិកសត្វ និង ការកត់សំគាល់ :

ថនិកសត្វខុសប្លែកពីសត្វដទៃទៀត ដោយលក្ខណៈច្រើនយ៉ាង ។ គ្រប់ប្រភេទសត្វទាំងអស់បង្កើតកូន ហើយចិញ្ចឹមកូន ដោយទឹកដោះ និង មានឈាមក្តៅ ។ ថនិកសត្វភាគច្រើនមានរោម និង មានជើងបួន ។ ចំពោះថនិកសត្វមួយចំនួនអាចបង្កឱ្យយើង មានការភ័ន្តច្រឡំក្នុងការធ្វើចំណាត់ថ្នាក់ ដូចជា ពពួកប្រចៀវ និង ជ្រើង តែងតែយល់ថា វាជាសត្វស្លាប ព្រោះវាអាចហើរ ប៉ុន្តែវាមាន រោម និង ផ្តល់កំណើតជាកូន រីឯផ្សោត និង បាឡែន តែងតែយល់ច្រឡំថាជាត្រី ធាតុពិតវាគឺជាថនិកសត្វដែលមិនមានរោម និង ជើង ប៉ុន្តែវាផ្តល់កំណើតជាកូន និង ចិញ្ចឹមកូនដោយទឹកដោះ ។

កត្តាចំបងដែលមានសារៈសំខាន់ក្នុងការកត់សំគាល់ពពួកថនិកសត្វ ឱ្យបានល្អ គឺរូបរាងរបស់សត្វនីមួយៗ ដែលយើងអាចធ្វើការញែកដាច់យ៉ាងច្បាស់ពីអំបូរ

ផ្សេងៗគ្នា ។ ប៉ុន្តែចំពោះសត្វអំបូរតែមួយ យើងអាចមានការភ័ន្តច្រឡំលើលក្ខណៈរូបរាង ករណីនេះពណ៌សំបុរគឺ មានប្រយោជន៍បំផុតសំរាប់សំគាល់ភាពខុសគ្នានៃប្រភេទនីមួយៗ ។ លើសពីនេះទៅទៀត ទំហំក៏មានសារៈសំខាន់មួយដែរ ដែលអាចឱ្យយើងដឹងពីភាពធំតូចរបស់សត្វ ដូចជាសត្វខ្លះខ្លួនធំជាង កន្ទុយខ្លីជាង ឬជើងខ្លី-វែងជាដើម ។

## III - ការស្វែងរក និងការសិក្សាពីថនិកសត្វ :

ទោះជាថនិកសត្វមានភាពលំបាកស្វែងរកជាងសត្វស្លាបក៏ដោយក៏មានវិធីសាស្ត្រផ្សេងៗគ្នាជាច្រើន ដើម្បីស្វែងរក និង សិក្សា ។ វិធីសាស្ត្រដែលប្រសើរបំផុតនោះគឺ អាស្រ័យទៅលើប្រភេទសត្វ ដែលយើងចង់ស្វែងរក ដោយហេតុថា សត្វនីមួយៗមានជំរក និង ការចូលចិត្តផ្សេងៗគ្នា ។ សត្វខ្លះចូលចិត្តរស់នៅក្នុងព្រៃស្រោងព្រៃល្បោះ នៅវាលតាមមាត់ទឹក វាលស្មៅ ។ល។

យើងក៏ត្រូវយល់ដឹងផងដែរអំពីជីវសាស្ត្ររបស់វា ពពួកសត្វ ស្វា កំប្រុកកង្ហែន នៅពេលថ្ងៃតែងតែ ឃើញនៅលើដើមឈើ រីឯថនិកសត្វផ្សេងទៀតដូចជាជ្រូក ប្រើស ស្កា ខ្លាឃ្មុំ មានសកម្មភាពច្រើនតែនៅលើដី ។ ថនិកសត្វ ធំៗចូលចិត្តរស់នៅដោយស្ងៀមស្ងាត់មិនមានការរំខានពីមនុស្ស ហើយវាជាសត្វដែលពិបាកចូលទៅជិតបាន ដូច្នេះចំពោះប្រភេទសត្វទាំងនោះទាមទារឱ្យមានភាពស្ងៀមស្ងាត់ក្នុងការចុះអង្កេត ។ កែវពង្រីក មានសារប្រយោជន៍ណាស់ សំរាប់ពិនិត្យមើលប្រភេទថនិកសត្វតូចៗ ដែលរស់នៅតាមដើមឈើ និង ការជំនួយឱ្យយើងមើលបានពីចំងាយ ។ ប្រភេទមួយចំនួនរកស៊ីនៅពេលយប់ដូចជា សំពោច ឆ្មាបា កណ្ដុរ ប្រចៀវ ជ្រីង និង ថនិកសត្វមួយចំនួនទៀត ។ ចំពោះការអង្កេតប្រភេទទាំងនេះ យើងត្រូវប្រើពិល ឬ ភ្លើងហ្វា សំរាប់អង្កេត ។

ថនិកសត្វត្រូវបានគេជួបប្រទះភាគច្រើន នៅតាមតំបន់ព្រៃស្រឡះ វាលស្មៅ ហើយកន្លែងដែលចាំបាច់សំរាប់ការអង្កេត គឺនៅតាមជង់ទន្លេ ស្ទឹង ព្រែក ត្រពាំង ជាដើម ។

ការសិក្សាអំពីដានជើង គឺមានប្រយោជន៍បំផុតសំរាប់សំគាល់នូវប្រភេទសត្វនីមួយៗ ប៉ុន្តែការសិក្សានេះ ទាមទារឱ្យមានភាពច្បាស់លាស់ដើម្បីជៀសវាងការច្រាំនស្មានខុស ព្រោះថាដានរបស់វាមានភាពប្រហាក់ប្រហែលគ្នាដែលពិបាកចំណាំ ។ លាមក និង គ្រោងឆ្អឹងរបស់វាក៏មានសារៈសំខាន់ដែរសំរាប់ធ្វើការសិក្សា ។

ចំពោះថនិកសត្វតូចៗដែលយើងមិនអាចធ្វើការកំណត់ប្រភេទបាន យើងត្រូវរៀបចំជាអន្ទាក់ ឬ សំណាញ់សំរាប់ចាប់វាមកសិក្សា ដូចជាពួកប្រចៀវ ជ្រើង កណ្តុរ និង កំប្រុក ជាដើម ។

# ការគំរាមកំហែងទៅលើថនិកសត្វ

កត្តាពីរសំខាន់ដែលកំពុងជំរុញឱ្យធនធានសត្វព្រៃ ក្នុងព្រះរាជាណាចក្រកម្ពុជា កាន់តែវិនាសបាត់បង់ ទៅពីមួយថ្ងៃទៅមួយថ្ងៃគឺ :

## ១. ការប្រមាញ់ :

សកម្មភាពប្រមាញ់បានកើតមានឡើងតាំងពីយូរយារណាស់មកហើយ និងសកម្មភាពនេះនៅតែបន្តជារៀងរហូតដូចជា លក្ខណៈប្រពៃណីមួយរបស់ប្រជាជនដែលរស់នៅពឹងផ្អែកទៅលើធនធានធម្មជាតិក៏ដូចជាសត្វព្រៃជាដើម ។ លើសពីនេះទៅទៀត សព្វថ្ងៃក្រៅពីការប្រើប្រាស់ប្រចាំថ្ងៃ មានឈ្មួញជាច្រើនដែលប្រកបរបរទិញលក់សត្វព្រៃទាំងនេះ ដើម្បីតម្រូវការទៅតាមភោជនីយដ្ឋាន ឬលក់បន្តទៅបរទេស ។ សកម្មភាពបរបាញ់សត្វព្រៃកើតឡើង ភាគច្រើននៅតំបន់ភូមិភាគឥសាន និង និរតីនៃប្រទេស ដោយរួមមានប្រភេទដែលជាតម្រូវការសំខាន់ៗនោះគឺ ជ្រូក ខ្លា

ខ្ទីង កែះ ទន្សោង ប្រើស ឈ្លូស និង ក្តាន់ព្រៃង ជាដើម ។

## ២. ការបាត់បង់ជីវភេ :

ជំរកគឺជាកត្តាចំបងបំផុតសំរាប់ការរស់នៅ និងភាពសុខសាន្ត របស់ពពួកថនិកសត្វ ចរិកលក្ខណៈរបស់ពួកវាចូលចិត្តរស់នៅតាមតំបន់ព្រៃ ដែលមានភាពស្ងៀមស្ងាត់ មិនមានការរំខានពីមនុស្ស ។ បញ្ហាដែលគួរឱ្យព្រួយបារម្ភបំផុតនោះគឺធនធានព្រៃឈើ ដែលមុន ឆ្នាំ១៩៧០ មានប្រមាណ ៧៣% នៃផ្ទៃប្រទេស សព្វថ្ងៃបានធ្លាក់ចុះមកត្រឹម ៥៨% ប៉ុណ្ណោះ ។ ដូច្នេះតួលេខបានបញ្ជាក់ឱ្យឃើញពីការបាត់បង់ព្រៃឈើ ដែលបណ្តាលមកពីកត្តាផ្សេងៗជា ច្រើនរាប់បញ្ចូលទាំងការកាប់ឈើស្របច្បាប់ និង ខុសច្បាប់ ការរានដីព្រៃ ធ្វើដំណាំកសិកម្ម ការសង់លំនៅដ្ឋាន និងតម្រូវការឈើសំរាប់បំរើ សេចក្តីត្រូវការក្នុងស្រុក និង ទៅបរទេស ។

# សកម្មភាពអភិរក្ស :

ដោយយល់ឃើញនូវតំលៃ និង សារប្រយោជន៍នៃធនធានសត្វព្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របពេលដែលសកម្មភាពអាជីវកម្មលើពពួកថនិកសត្វបានរាលដាលក្នុងផ្ទៃប្រទេស សព្វថ្ងៃរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយរិះរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីធ្វើយ៉ាងណាអោយធនធានទាំងនេះបានគង់វង្ស ។

ចាប់តាំងពីឆ្នាំ ១៩៩២ រហូតមកដល់ពេលបច្ចុប្បន្ន ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលមាននាយកដ្ឋាន រុក្ខាប្រមាញ់ ជាអ្នកប្រតិបត្តិ បានខិតខំចុះសិក្សាស្រាវជ្រាវ ស្វែងរកនូវវត្តមានពពួកថនិកសត្វទាំងនេះ ទូទាំងផ្ទៃប្រទេស ដើម្បីជាមូលដ្ឋានលើការធ្វើផែនការអភិរក្សនៅតាមតំបន់ ដែលមានសត្វសំខាន់ៗ និងកំរ ។ ក្រៅពីនេះ យើងបានធ្វើការទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាល និង

អង្គការអន្តរជាតិថែមទៀត ដើម្បីជាជំនួយទៅលើបច្ចេកទេសនៃការងារអនុវត្តក៏ដូចជាថវិកាទ្រទ្រង់ ។

សំខាន់ដូចគ្នានោះដែរ ក្នុងឆ្នាំ១៩៩៣ ក្រសួងបរិស្ថានត្រូវបានបង្កើតនិងមានភារកិច្ចទទួលខុសត្រូវគ្រប់គ្រងតំបន់ការពារដែលមាន ២៣ កន្លែង រួមមានតំបន់ដែន ជំរកសត្វព្រៃ ១០កន្លែង តំបន់ឧទ្យានជាតិ ៧កន្លែង តំបន់ការពារ ទេសភាព ៣កន្លែង និង តំបន់ប្រើប្រាស់ច្រើនយ៉ាង ៣កន្លែង ។ នាយកដ្ឋានការពារ និង អភិរក្សធម្មជាតិជាអ្នកប្រតិបត្តិបានកំពុងខិតខំគ្រប់គ្រងតំបន់ការពារធម្មជាតិទាំង២៣កន្លែង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងអង្គការអន្តរជាតិនានា ដើម្បីដំណើរការ និង ភាពជោគជ័យនៅតាមតំបន់ទាំងនេះ គឺជាសុវត្ថិភាព និងភាពគង់វង្សមួយដ៏ធំបងសំរាប់ថនិកសត្វ ។

សព្វថ្ងៃ រាជរដ្ឋាភិបាល កំពុងមានវិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ឱ្យបាននូវសកម្មភាពជួញដូរសត្វព្រៃគ្រប់រូបភាព ដែលកើតមានឡើងទូទាំងផ្ទៃប្រទេស កន្លែងលក់សត្វព្រៃមួយចំនួនត្រូវបានបំផ្លាញចោល ហើយសត្វព្រៃដែលចាប់បាន ត្រូវបានដោះលែងនៅតាមតំបន់ដែលមានសុវត្ថិភាពបំផុត ។

តម្រូវការចាំបាច់ និង បន្ទាន់បំផុតសំរាប់កិច្ចការពារ អភិរក្សធនធានថនិកសត្វឱ្យកាន់តែមានប្រសិទ្ធភាពនោះគឺ ការរៀបចំធ្វើវិសោធនកម្មច្បាប់សត្វព្រៃបន្ថែមទៀត ដើម្បីមានលក្ខណៈគ្រប់គ្រាន់ បង្ក្រាបរាល់បទល្មើសគ្រប់រូបភាព និងឈានឆ្ពោះទៅរកការគ្រប់គ្រងធនធានសត្វព្រៃឱ្យមាននិរន្តភាព ។

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៤២៥-៥០០ ម.ម កន្ទុយ ៣៤០-៤៧០ ម.ម ទំងន់ ៥-៧ គ.ក្រ ។

**ពិពណ៌នា** : ពង្រូលជាថនិកសត្វគ្មានធ្មេញ មានស្រកា ថ្នាសផត និងជាប្រភេទសត្វវារ ។ ដងខ្លួនទាំងមូលរាប់បញ្ចូល ទាំងជើងផង លើកលែងតែពោះ និងផ្នែកក្រោមក្បាលរបស់វា សុទ្ធសឹងតែគ្របដណ្ដប់ដោយស្រកា ដែលមានពណ៌ស្រអាប់និងពណ៌ដី ។ ជើងមានម្រាមប្រាំ និង មានក្រចកគ្រប់ម្រាមទាំងអស់ ក្រញ៉ាំជើងមុខវែងជាងក្រញ៉ាំជើងក្រោយ ។ ចលនាយឺតៗនិងពត់ពេនក្នុងការវារចុះវារឡើង ហើយវាជាសត្វពូកែឡើងដើមឈើទៀតផង ។

**ជីវសាស្ត្រ** : វាមានជំរកនៅក្នុងប្រភេទព្រៃដែលមានដើមឈើខ្ពស់ៗ ព្រៃក្រោយអាជីវកម្ម និងដីកសិកម្ម ។ ពង្រូល ជាសត្វរកស៊ីលើផ្ទៃដី ឬក្នុងរន្ធឈើ ហើយពេលថ្ងៃវាដេកក្នុងរន្ធដី ។ ចំណីអាហាររបស់វាមាន ស្រមោច សង្កា អង្រ្កង ដុកឌឿ និងកណ្ដៀរដ៏ច្រើនសន្ធឹកសន្ធាប់ ។ ចំពោះពង្រូលញីកើត កូនម្តងបានមួយ ( យូរៗ ម្តងពីរ ) ហើយកូនរបស់វាកើតក្រោយពីមេវាមានគភ៌រយៈពេលពី ២-៣ ខែ ។ វារមូរខ្លួន នៅពេលដែលវាជួបនឹងឧបសគ្គ វាមានអណ្ដាត ស្អិតជាយក្នុងការចាប់ចំណី ។ វាជាប្រភេទសត្វស្លូត មិនបណ្ដាលអោយមានគ្រោះថ្នាក់អ្វីឡើយ ។

**ស្ថានភាព និង ស្ថានភាព** : វាជាប្រភេទសត្វមានជាមធ្យម ស្ទើរតែគ្រប់ទីកន្លែង និងកំពុងរងនូវការបំផ្លិចបំផ្លាញយ៉ាងខ្លាំងពីមនុស្ស ។ ជាប្រភេទហាមបរបាញ់ក្នុងប្រកាសលេខ ៣៥៩ ប្រក.កសក. របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និងចុះក្នុងបញ្ជីក្រហម IVCN(NT) ជាប្រភេទជិតទទួលរងការគំរាមកំហែងលើពិភពលោក និងស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។





# ២.កណ្តុរល្មេះ House Shrew *Suncus murinus*

**ទំហំ** : ក្បាលដងខ្លួន ១០០-១៥០មម កន្ទុយ ៧០-៩៦មម ទម្ងន់ ៣៩-៧៨ ក្រ

**ពិពណ៌** : សំបុរផ្នែកខាងលើមានពណ៌ផ្សេងពីគ្នា កណ្តុរខ្លះពណ៌ខ្មៅ ត្នោត រហូតដល់ប្រផេះ ។ ផ្នែកខាងក្រោមមានសំបុរស្រាលជាង អាស្រ័យដោយប្រភេទ ។ មានគល់កន្ទុយធំមាំ ហើយខ្លី និងមានពណ៌ស្រាលជាងខ្លួន ត្រចៀកមូលស្រួច ជើងទាំងបួនមានពណ៌ប្រហែលនឹងកន្ទុយ ។

**ជីវសាស្ត្រ** : ជាប្រភេទរស់នៅជិតស្និទ្ធជាមួយមនុស្ស ជំរកវាគឺ ទីក្រុង ភូមិករ ជងផ្លូវ ស្មៅក្រាស់ៗ គម្លោតព្រៃ ប្រឡាយ វាលស្រែ ចំការ និង តំបន់មានព្រៃឆ្ងាយពីលំនៅដ្ឋាន ។ វាជាសត្វមានប្រយោជន៍ដល់មនុស្ស ព្រោះវាបានស៊ីសត្វល្អិតចង្រៃ នៅរដូវបន្តពូជ តែងតែមានក្លិនឆ្អួលដែលចេញពីចំហៀងខ្លួន ។ វាជាសត្វរាត្រីចរ ពុំសូវខ្លាចមនុស្សទេ ជួនកាលវាធ្វើសកម្មភាពនៅពេលថ្ងៃ វាពុំចូលចិត្តវារចុះឡើងតាមជញ្ជាំង ប៉ុន្តែវាចូលចិត្តរស់នៅកន្លែង គៀនកោះ ។ ចំណីអាហារ សត្វឥតឆ្អឹងកង សប្បិសត្វ សត្វល្អិត សាច់ បន្លែ ផ្លែឈើ ដំឡូងជ្វា បាយ ជាដើម ។ វាមានគភ៌ស្មើរពេញ ១ឆ្នាំ និង អាចបន្តពូជបាននៅ អាយុ៣៦ ថ្ងៃ អាយុកាលពី ១-២ ឆ្នាំកន្លះ ។

**របាយ និង ស្ថានភាព** : មានជាមធ្យម ដោយកន្លែង និង តាមលំនៅដ្ឋាន ។

# ៣.កន្ទីក Northern Treeshrew *Tupaia belangeri*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ១៣៥-២០៥ ម.ម កន្ទុយ ១២៥-១៩៥ ម.ម

**រូបភាព** : សត្វកន្ទីកមានរូបរាងប្រហាក់ប្រហែលទៅនឹងសត្វកំប្រុក តែមានដងខ្លួន និងច្រមុះវែងហើយស្រួចជាង ។ វាមានដងខ្លួន និងកន្ទុយទាំងមូលគ្របដណ្ដប់ដោយរោមដែលមានសម្បុរពណ៌ត្នោត និង កន្ទុយរាងស្រាវ ។

**ជីវសាស្ត្រ** : កន្ទីកជាសត្វរស់នៅលើដើមឈើ រកស៊ីនៅពេលថ្ងៃ ។ ចំណីអាហាររបស់វាមានពពួកសត្វល្អិត ពងពាង និងផ្លូវ ។ នៅពេលជួបឧបសគ្គម្ដងៗ វាបញ្ចេញសំលេងខ្លាំងៗ ។

**របាយ និង ស្ថានភាព** : ប្រភេទសត្វនេះមានជាមធ្យម ស្ទើរតែគ្រប់ទីកន្លែង ។





# ៤.កន្ធ៊ុកក្បាលឆ្នូត

## Northern Smooth-tailed Treeshrew
*Dendrogale murina*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ១១៥-១៣៥ ម.ម កន្ទុយ ១០៥-១៣០ ម.ម ទម្ងន់ ៣៥-៥៥ ក្រ.

**ភិនភាគ** : វាជាសត្វដែលមានទំហំតូចជាងគេ ក្នុងចំនោមសត្វប្រភេទនេះ ច្រមុះវែងស្រួចកន្ទុយវែង ។ ដងខ្លួនទាំងមូលគ្របដណ្តប់ដោយរោមទន់ហើយខ្លីដែលមានពណ៌ត្នោតចាស់ ។ ផ្នែកក្បាលមានឆ្នូតពណ៌ត្នោតចាស់ លាតចាប់ពីគល់ច្រមុះដោយកាត់តាមភ្នែករហូតដល់គុម្ពត្រចៀក ហើយមានឆ្នូតពណ៌សអមសងខាង ។ផ្នែកខាងខ្នងមានពណ៌ក្រម៉ៅរីឯផ្នែកពោះនិងជើងចំហៀងខាងក្នុងមានពណ៌ត្នោត ។សំបុររបស់សត្វឈ្មោលមានពណ៌ដិត និងច្រើន ជាងសត្វញី ។ កន្ទុយមានពណ៌ចាស់និងលឿងលាយត្នោតភាគច្រើន ។ ចំណែកម្រាមជើងក្រោយរបស់វា វែងជាងម្រាមជើងក្រោយរបស់កន្ធ៊ុក **(Northern Treeshrew)** *Tupaia belangeri* ក្រញ៉ាំខ្លីហើយ ទាល ។ ចំពោះសត្វញីមានដោះមួយគូ ។

**ជីវសាស្ត្រ** : វាជាសត្វចូលចិត្តរស់នៅលើមែកឈើទាប១ គឺមែកទី១នៃព្រៃចាស់ ព្រៃដែលគេធ្វើអាជីវកម្មរួច និង គម្ពោតព្រៃ ។ ចំណីអាហាររបស់វាមានផ្លែឈើ សត្វល្អិតជា ពិសេសអណ្តើកមាស។ វាបញ្ចេញសំលេងនៅពេលឡើងដើមឈើ ។ សត្វឈ្មោលមានសំលេងខ្លាំង និង ធំជាងសត្វញី។

**របាយ និង ស្ថានភាព** : សំបូរជាមធ្យម មាននៅតាមបណ្តោយព្រំប្រទល់ ខ្មែរ ថៃ និង ខាងកើតទន្លេមេគង្គ ។ ជាប្រភេទសត្វមានក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។



# ៥.ឆ្មាបា Sunda Colugo *Cynocephalus variegatus*

**ទំហំ** ៖ ប្រវែងក្បាល-ដងខ្លួន ៣៤០-៤២០ ម.ម កន្ទុយ ១៧៥-២៧០ ម.ម ទំងន់ប្រហែល ១១ គ.ក្រ

**ពិពណ៌ន** ៖ ឆ្មាបាមានក្បាលមូលហើយធំទូលាយ ត្រចៀកខ្លី ច្រមុះមូលហើយទាល ភ្នែកធំមានពណ៌ក្រហម និង អាចមើលឃើញបានច្បាស់ល្អ ដែលផ្តល់នូវការកំណត់ទីកន្លែងសំរាប់ចុះ ដោយធានាបាននូវសុវត្ថិភាព ។ អវៈយវៈមានប្រវែងស្មើគ្នា ដោយមានក្រចកស្រួច ហើយខ្លាំងងាយស្រួលក្នុងការឡើងដើមឈើ វាតោងឡើងដើមឈើតាមសំបកឈើ ។ រោមផ្ទៃលើស្បែកស្លាបរបស់វាមានពណ៌ត្នោតប្រផេះ ហើយផ្នែកខាងក្រោមមានពណ៌ស្រាលជាង ។ សត្វឈ្មោលមានសម្បុរភ្លឺថ្លានិងទំហំតូចជាងសត្វញី ។ ភ្នាសស្លាបរបស់វាភ្ជាប់ពីជើងមុខរហូតដល់កន្ទុយ ។

**ជីវសាស្ត្រ** ៖ ឆ្មាបារស់នៅក្នុងតំបន់ទំនាបនិងជួរភ្នំ ដែលមានប្រភេទព្រៃចាស់ និងព្រៃដែលធ្វើអាជីកម្មរួច ព្រៃចំការដូង និងចំការកៅស៊ូផងដែរ ។ វារស់នៅលើដើមឈើកម្ររស់នៅលើដីណាស់ ។ ការផ្លាស់ទី ពីដើមឈើមួយទៅដើមឈើមួយទៀត អាស្រ័យដោយការហោះសំកាំង ។ ការហោះសំកាំងរបស់វាយឺត និងអាចបានចំងាយរហូតដល់ ១០០ម៉ែត្រ ។ ជាសត្វរាត្រីចរជាធម្មតាវារស់នៅក្នុងរន្ធឈើ ។ ចំណីអាហាររបស់វាមានផ្លែឈើទន់ៗ ដូចជាចេក ល្ហុង ក្រូច ស្វាយ និង រុក្ខជាតិពណ៌បៃតង ដូចជាស្លឹក ជាដើម ។

**រចាយ និង ស្ថានភាព** ៖ វាជាសត្វមានតិចតួច មាននៅភាគឦសាន និង និរតី ។



## ៦.ជ្រឹងកោះ Island Flying-fox *Pteropus hypomelanus*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ១៧០-២០០ ម.ម កំភួនដៃ ១៣០-១៤៤ ម.ម ទំងន់ ៤៥ ក្រ.

**ចំណាំ** : វាជាប្រភេទសត្វជ្រឹងតូចបំផុត ដែលមានកំភួនដៃមិនលើសពី ១៤៥ ម.ម។ រូបរាងរបស់វា ដូចប្រចៀវ និង មានសម្បុរក្រម៉ៅ ។ ផ្នែកកមានពណ៌លឿងទុំទៅត្នោតចាស់ ហើយផ្នែកពោះមានសំបុរភ្លឺថ្លាជាងគេ ។ រោមជុំវិញភ្នែកមានពណ៌ប្រផេះ ។ កន្ទុយមិនសូវដុះដាល និងមានក្លិនឆ្អេះ ។

**ជីវសាស្ត្រ** : វារស់នៅតែលើកោះ និង ស៊ីផ្លែឈើជាអាហារ ។

**របាយ និងស្ថានភាព** : ពុំទាន់មានពត៌មានច្បាស់លាស់ ប៉ុន្តែត្រូវបានចុះក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។

## ៧.ជ្រឹងមធ្យម Lyle's Flying-fox *Pteropus lylei*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ២០០-២៥០ ម.ម កំភួនដៃ ១៤៥-១៦០ ម.ម ទំងន់ ៣៥០-៤៨០ ក្រ.

**ពិពណ៌នា** : ជ្រឹងប្រភេទនេះមានសំបុរពណ៌ត្នោតចាស់ នៅផ្នែកពោះ និងខ្នង ពណ៌លឿងទុំផ្នែកទ្រូងនិងក្រោមក ពណ៌លឿងនៅកផ្នែកខាងលើ ពណ៌លឿងស្រាលនៅចន្លោះស្មា ។ ផ្នែកខ្នងចាប់ពីគល់ស្លាបរហូតដល់ត្រចៀកមានពណ៌លឿងស្រាល ចង្កាពណ៌ក្រម៉ៅ ភ្នាសស្បែកស្លាបមានពណ៌ខ្មៅ និងមានរោមខ្លីៗ រន្ធច្រមុះខ័ណ្ឌដាច់ដោយចង្អូរជ្រៅ ។ ត្រចៀកតូចខ្មៅ នៅចន្លោះត្រចៀកមានពណ៌ត្នោតស្រាល ។

**ជីវសាស្ត្រ** : វារស់នៅជាហ្វូងធំៗ ហើយរកស៊ីនៅពេលយប់ ចំណែកពេលថ្ងៃវាតោងទៅនឹងមែកឈើ ។ ចំណី អាហារ របស់វា មានផ្លែឈើគ្រប់ប្រភេទ ។

**របាយ និងស្ថានភាព** : មានជាមធ្យម ស្ទើរគ្រប់ទីកន្លែង និងត្រូវបានចុះតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។



## ៨.ជ្រើងធំ Large Flying-fox *Pteropus vampyrus*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៣០០-៣៤០ ម.ម កំភួនដៃ១៩០-២១០ ម.ម ទំងន់ ៦៥៤ - ១១០០ ក្រ.

**ភិនភាគ** : វាជាប្រភេទដែលធំជាងគេក្នុងចំណោមពពួកជ្រើងរស់នៅលើពិភពលោក ។ ជ្រើងធំមានសម្បុរល្មើងទុំ ក្រម៉ៅ ស្បែកវាគ្របដណ្តប់ដោយរោមបន្តរហូតដល់ពាក់កណ្តាលកំភួនដៃ ។ ក្បាលមានពណ៌ក្រហមខ្មៅ ឬត្នោតលាយក្រហម ខ្នងពណ៌ខ្មៅ និងមានលាយ រាយប៉ាយដោយពណ៌ស ។ ចង្កាវាមានពណ៌ខ្មៅបន្តចុះទៅដល់បំពង់កដែលមានរោមពណ៌ត្នោតលាយក្រហម នៅអមសងខាង ដោយលាតសន្ធឹងដល់ផ្នែកខាងលើ ហើយក្លាយជាពណ៌ទឹកក្រូច ។

**ជីវសាស្ត្រ** : វារស់នៅតាមដើមឈើធំៗហើយខ្ពស់ និងល្អាងភ្នំ ក្នុងលក្ខណៈជាហ្វូងអាចដល់ ១០០ក្បាល ។ សត្វញី កើតកូនម្តងបានមួយក្បាល នៅចុងខែ មិនា និង មេសា ។ ពេលចេញរកចំណីមេវាបាននាំកូនដែលទើប និងកើតបាន ពីរ ឬបីថ្ងៃទៅជាមួយ ។ កូនវារស់នៅជាមួយមេក្នុងរយៈពេលពីរ ឬបីខែ ។ វាជាសត្វរាត្រីចរ ភ្នែករបស់វាអាចសំលឹងមើលឃើញបានល្អ និង ច្រមុះរបស់វាពូកែស្រង់ក្លិន ។ ចំណីអាហារ របស់វាមានផ្លែឈើទុំ ផ្កា ទឹកដមផ្កា និងលំអងផ្កា ។ វាមានអាយុកាលរហូតដល់១៥ឆ្នាំ ។

**របាយ និង ស្ថានភាព** : មានជាមធ្យម ស្ទើរគ្រប់ទីកន្លែង និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។





# ៩. ជ្រឹងអន្ទាម

## Greater Long-tongued Fruit Bat
*Macroglossus sobrinus*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៦៥-៧៥ ម.ម កន្ទុយ ០-២ ម.ម កំភួនដៃ ៤៤-៥៥ ម.ម ទំងន់ ១៨-២៣ ក្រ.

**ភិតភាព** : វាមានមាត់រាងទ្រវែងស្រាវ អណ្តាតវែង ដែលបង្កលក្ខណៈងាយស្រួលដល់ការចញ្ចឹមជីវិតដោយបឺតយកទឹកដមផ្កា ។ ត្រចៀករបស់វាមាន ទំហំមធ្យម និងមានពណ៌ត្នោត ចុងត្រចៀកមានរាងមូលតូច ។ ដងខ្លួនគ្របដណ្តប់ដោយរោមទន់ ។ ជើង និងកំភួនដៃមានរោម ហើយផ្នែកខ្លះនៃភ្នាសស្បែកក៏មានរោមដែរ ។ ភ្នាសស្បែកដែលនៅចន្លោះជើងក្រោយត្រូវបានគ្របដណ្តប់ដោយរោមខ្លីៗ ហើយក្រាស់ទាំងលើទាំងក្រោម។ ផ្នែកស្មាមានពណ៌ស្រាលជាង ផ្នែកក្បាល ជាទូទៅ មានពណ៌ត្នោតច្រើន-ជាងក្រហម ត្រចៀកនិងស្លាប មានពណ៌ត្នោតចាស់ ។ ចំពោះសត្វឈ្មោលគ្មានរោមភ្លែកទេ ។

**ជីវសាស្ត្រ** : វាចិញ្ចឹមជីវិត ដោយបឺតទឹកដមផ្កា ។

**របាយ និង ស្ថានភាព** : ជាប្រភេទមានដោយសំបូរ គ្រប់ទីកន្លែង ។









## ១០. ប្រចៀវ Tomb Bat *Taphozous theobaldi*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៨៨-៩៥ ម.ម   កន្ទុយ ២៥-៣០ ម.ម  កំភួនដៃ ៧០-៧៥ ម.ម

**ភិនភាគ** : វាជាសត្វមានត្រចៀកធំជាងគេ ក្នុងអំបូររបស់វា និងពណ៌ផ្សេងៗគ្នា ។ ជាទូទៅវាមានពណ៌ត្នោតចាស់ផ្នែកខាងលើ ហើយផ្នែកខាងក្រោមមានពណ៌ស្រាលជាង ។ សត្វឈ្មោលមានពុកមាត់ពណ៌ត្នោត ។ ចំណែកភ្នាសស្បែករបស់វាមាន រោមតិចតួច ស្បែកដែលនៅចន្លោះជើងក្រោយគ្មានរោមទេ ។ ផ្នែកចុងកន្ទុយមានរោម វែងៗខ្លះ ។

**ជីវសាស្ត្រ** : ជំរករបស់វាស្ថិតនៅក្នុងរូងភ្នំ តាមដំបូលផ្ទះ និងស៊ីសត្វល្អិតហើរខ្ពស់ៗ ។ វារស់នៅជាក្រុមរហូតដល់រាប់ពាន់ក្បាល ។

**របាយ និង ស្ថានភាព** : មានជាមធ្យម ដោយកន្លែង ។





# ១១.ប្រចៀវ

## Lesser False Vampire Bat
*Megaderma spasma*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៦៥-១៤០ម.ម    កំភួនដៃ ៥០-១១៥ ម.ម

**ភិនភាគ** : សត្វប្រភេទនេះ សំគាល់ដោយសារវាមានស្លឹកត្រចៀកធំៗពីរ និងមានច្រមុះរាងជាបន្ទះ ។

**ជីវសាស្ត្រ** : វាជាសត្វរស់នៅក្នុងជំរកតែឯកឯង ឬនៅជាហ្វូង ដែលមានចំនួនពី ៥០-១០០ក្បាល ។ ពួកប្រភេទនេះពោរពេញដោយជំនាញ និងស្ទាត់ក្នុងការហោះហើរ ។ វារកស៊ីនៅពេលយប់ ។ ចំណីអាហាររបស់វាមានពពួកសត្វល្អិត និងពពួកសត្វឥតឆ្អឹងកងផ្សេងទៀត ។ វាចាប់ចំណីជាក្រុម ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វសំបូរ មានគ្រប់ទីកន្លែង ។









# ១២. ប្រចៀវ

## Bornean Horseshoe Bat
*Rhinolophus borneensis*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៣៥-១១០ ម.ម  កន្ទុយ ១៥៥៦ ម.ម

កំភួនដៃ ៣០-៧៥ ម.ម

**ភិនភាគ** : សត្វប្រភេទនេះមានពណ៌សំបុរខុសៗពីគ្នា ពីពណ៌ត្នោតក្រហម ទៅពណ៌ក្រម៉ៅ និង ពណ៌ព្រលែតជាង នៅផ្នែកខាងក្រោម ។ ច្រមុះរាងជាសន្លឹក ត្រចៀកធំ ។ វាមានដុំពកពីរ នៅលើពោះ សំរាប់កូនរបស់វាតោង នៅពេលដែលវាហោះហើរ ។

**ជីវសាស្ត្រ** : ប្រភេទនេះមានជំរករស់នៅកន្លែងណា ដែលពួកវាអាចតោងស្នាក់នៅបាន ដោយស្នាបទាំងពីរក្តោបខ្លួន ។ វាស៊ីសត្វល្អិត ពីងពាង ហើយជារឿយៗវាវិលត្រឡប់ទៅកាន់ជំរកវិញ ដើម្បីស៊ីអាហារដែលវាបានចាប់ ។ ប្រភេទនេះហើររោបចំណី នៅរវាង៦ម៉ែត្រ ពីលើផ្ទៃដី និងរកចំណីនៅទីងដីផងដែរ ។ ជាទូទៅវាហោះហើរ ដោយបិទមាត់ និងបញ្ចេញសូរសំលេងតាមច្រមុះ ។ ការបញ្ចេញសំលេងរបស់វា អាចមកពីមានជំនួយ អំពីសន្លឹកបន្ទះច្រមុះរបស់វា ។

**របាយ និង ស្ថានភាព** : ជាប្រភេទសំបូរ មាននៅតំបន់ព្រៃ ។





# ១៣.ប្រចៀវ

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៣៦-៣៨ ម.ម    កន្ទុយ ៣៧-៣៨ ម.ម    កំភួនដៃ ២៧-៣០ ម.ម

**រូបភាព** : ផ្នែកខាងលើមានពណ៌ត្នោតចាស់លាយប្រផេះ ហើយផ្នែកខាងក្រោមមានពណ៌ស្រាលជាង ។ វាមានសាច់ និង ស្បែកក្រាស់ ជ្រួញ នៅនឹងគល់ម្រាមរបស់ស្លាប និងភាពផតនៃស្បែកក្រាស់នេះ នៅស្បែកនៃបាតជើង ។ វាមានត្រចៀករីកខាងចុង និងរួមគល់ ហើយមានប្រវែងវែងដែលអាចទាញសន្ធឹងដល់ចុងមាត់ និងច្រមុះ ។ ភ្នាសស្បែកភ្ជាប់គ្នាទៅនឹងកន្ទុយគឺ វាភ្ជាប់ទៅនឹងកជើងផ្នែកខាងក្រោម និងមានស្លាបភ្ជាប់ទៅនឹងម្រាមទី១ ។

**ជីវសាស្ត្រ** : វា ចូលចិត្តរស់នៅក្នុងបណ្តូលស្លឹកចេក បំពង់ឫស្សី និង ស៊ីមូសជាអាហារ ។

**របាយ និង ស្ថានភាព** : មានជាមធ្យម ស្ទើរគ្រប់ទីកន្លែង ។



## ១៤.ប្រចៀវ Wrinkle-lipped Bat *Tadarida plicata*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៦៥-៧៥ ម.ម ទំងន់ ១៧-៣១ ក្រ. កំភួនដៃ ៤០-៥០ ម.ម

**ភិនភាគ** : ជាប្រភេទសត្វដែលមាន ពណ៌ត្នោតចាស់ នៅផ្នែកខាងលើ និង ប្តូរទៅជាពណ៌ស្រាលបន្តិចម្តងៗ រហូតដល់កន្ទុយ ។ នៅផ្នែកខាងលើនៃស្មាគ្របដណ្តប់ដោយរោមស្តើង ពោះមានរោមខ្លះៗ មានពណ៌ប្រផេះ ឬ ស ។ មុខរបស់វាគ្របដណ្តប់ដោយរោមគ្រង់ខ្លីពណ៌ខ្មៅ ។ ត្រចៀកទាំងគូមូល ក្រាស់ ធំទូលាយ ។ កន្ទុយមានប្រវែងមួយភាគពីរ នៃដងខ្លួន ។ ម្រាមជើងទី១ និងទី៥ មានកំភាស់ក្រាស់ ។

**ជីវសាស្ត្រ** : វាចូលចិត្តរស់នៅតាមដំបូលផ្ទះ ឬ ល្អាងភ្នំជាហ្វូងធំៗរហូតដល់ ២០០.០០០ ក្បាល ឬ ច្រើនជាងនេះ ។ វាហើរចេញពីទ្រនុំនៅពេលដែលព្រះអាទិត្យហៀបលិច និង ចំណាយពេលច្រើនដើម្បីចាប់ចំណី ។ ចំណីរបស់វាមានសត្វល្អិត ។

**របាយ និង ស្ថានភាព** : មានដោយសំបូរ តាមតំបន់ទីប្រជុំជន ។



# ១៥.រញ្ជើ Slow Loris *Nycticebus coucang*

**ទំហំ** : ក្បាល-ដងខ្លួន ១៩៥-២៧៥ ម.ម ទំងន់ : ២៣០-៦១០ ក្រ

**ភិនភាគ** : ជាទូទៅវាមានពណ៌ផ្សេងគ្នាចាប់ពីត្នោតប្រផេះព្រលែតទៅត្នោតក្រហម និងមានឆ្នូតពណ៌ត្នោត ចាប់ពីក្បាលរហូតដល់ពាក់កណ្ដាលខ្នង រឺ ដល់គល់កន្ទុយ ។ មានពណ៌ចាស់ព័ទ្ធជុំវិញភ្នែក ។ មានរោមក្រាស់ ទន់ ។

**ជីវសាស្ត្រ** : ជាសត្វរាត្រីចរ រស់នៅលើដើមឈើតូចៗ និងមធ្យម ។ វាស៊ីសត្វល្អិត ផ្លែឈើ និងកាកាវ ។ ចូលចិត្តរស់នៅព្រៃពាក់កណ្ដាលស្រោង តាមសួនច្បារ ចំការកាកាវ និង ច្រើនរស់នៅតែឯកឯង ។ វាអាច រស់បានដល់អាយុ ១៤ឆ្នាំ ។

**របាយ និង ស្ថានភាព** : មានជាមធ្យម ស្ទើរគ្រប់ទីកន្លែង ។ ជាប្រភេទហាមឃាត់ការបរបាញ់ ដោយប្រកាសក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី២ របស់អនុសញ្ញា CITES ។





# ១៦.ស្វាត្រោស

## Pig-tailed Macaque
*Macaca nemestrina*

**ទំហំ** : ក្បាល-ដងខ្លួន :៤៧០-៥៨៥ មម .កន្ទុយ :១៤០-២៣០ មម . ទំងន់ : ៣.៥-៩ គក្រ ។

**ពិពណ៌នា** : ក្បាល ខ្នង ផ្នែកនៃកន្ទុយមានពណ៌ខ្មៅជាងផ្នែកចំហៀងនៃដងខ្លួន និង ផ្នែកខាងក្រោម នៃដងខ្លួនមានពណ៌ភ្លឺ ។ កន្ទុយមានប្រវែង ៣៥-៤០% នៃប្រវែងក្បាល និង ដងខ្លួន ហើយចុងកន្ទុយ កោងជាទំពក់ ។ នៅចំទទូលក្បាលមានក្រយៅ ពណ៌ត្នោត-ចាស់ឬខ្មៅ ដែលមានរោមខ្លីបះត្រង់ៗមើលទៅវៀងដូចមួកកាតិប ។ នៅជុំវិញក្បាលមានរោមកញ្ចុំពណ៌ត្នោតខ្ចី បះត្រង់ៗដុះព័ទ្ធជុំវិញស្ទើរតែលុបបាត់ ត្រចៀក ។ ពណ៌របស់វាប្រែប្រួលទៅតាមអាយុភេទ ហើយទំងន់ស្វាញីតិចជា ៦៥% នៃស្វាឈ្មោល ។

**ជីវសាស្ត្រ** : រស់នៅព្រៃស្រោង ព្រៃជ្រុះស្លឹក វារស់នៅជាហ្វូងពី ៥-៦ ឬអាចរហូតដល់ ៤០ក្បាល ។ ហ្វូងរបស់វាមិនរស់នៅជាប្រចាំក្នុងកន្លែងណាមួយពិតប្រាកដទេ វាតែងតែ ដើរគ្រប់ទិសទីពេញព្រៃ ។ ចំណីរបស់វាមាន ផ្លែឈើ ផ្កា គ្រាប់ធញ្ញជាតិ សត្វល្អិត ។

**របាយ និង ស្ថានភាព** : ស្វាត្រោសជាប្រភេទមានជាមធ្យម ។ វារស់នៅស្ទើរគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា ។ វាជាប្រភេទ មួយត្រូវហាមឃាត់ការបរបាញ់ និង ធ្វើអាជីវកម្មដោយប្រកាសរបស់ក្រសួង កសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និងត្រូវចុះបញ្ជី IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី២ របស់អនុសញ្ញា CITES ។





# ១៧.ស្វាក្តាម

## Long tailed Macaque
*Macaca fascicularis*

**ទំហំ** : ក្បាល-ដងខ្លួន : ៤៨៥-៥៥០ មម . ទំងន់ : ៣.៥-៦.៥ គក្រ ។

**ភិនភាគ** : មានការផ្លាស់ប្តូរពណ៌ពីដំណាក់កាលសំខាន់ គឺពណ៌ប្រផេះព្រឿងៗសូកូឡា និង ពណ៌ ក្រហមព្រឿងៗ ។ ការផ្លាស់ប្តូរពណ៌នេះ ហាក់ដូចជាផ្លាស់ប្តូរទៅតាមអាយុវដ្តកាល និង ទីតាំង ចំពោះ ពួកស្វាក្តាមដែលរស់នៅតំបន់ព្រៃ ជាទូទៅមានពណ៌ខ្មៅ និង ពណ៌ឆើត ឯពួកស្វាមានលំនៅមាត់សមុទ្រ ភាគច្រើនមានពណ៌ភ្លឺ ។ វាគឺជាស្វាដែលមានកន្ទុយវែងជាងគេនៅប្រទេសយើង ដែលជាទូទៅមានមធ្យមភាគពី ៨០-១១០% នៃប្រវែងក្បាលរួមជាមួយនឹងប្រវែងដងខ្លួន ។ ចំពោះស្វាមិនទាន់ពេញវ័យមានដុះរោមកញ្ចុំលើក្បាលខ្ពស់ ស្វាចាស់វាមានរោមវែងក្រាស់ដុះជុំវិញផ្ទៃមុខ ថ្ពាសត្រដោល ។

**ជីវសាស្ត្រ** : ថ្វីបើលំនៅដ្ឋានពិតប្រាកដនៃស្វាក្តាមគឺវាលភក់ ព្រៃលិចទឹក ព្រៃកោងកាងក៏ដោយ ក៏គេប្រទះឃើញវារស់នៅព្រៃស្រោង និង ពាក់កណ្តាលស្រោង និង តំបន់ធ្វើកសិកម្ម ។ កន្លែងណាដែលពួកវានៅ គឺមានមហន្តរាយយ៉ាងខ្លាំងដល់ដំណាំកសិកម្ម ។ ជាទូទៅស្វាក្តាមភាគច្រើននៅតាមបណ្តោយ ឆ្នេរខ្សាច់ និង មាត់ឆ្នេរកោះ ជាពិសេសវាលភក់ព្រៃកោងកាង ។ វាចិញ្ចឹមជីវិតដោយចាប់ក្តាម សត្វទឹកដែលមានសំបករឹងដូចក្តាមបង្កង និង ខ្យងខ្មៅ គ្រុម លៀស ងាវ ហើយនិងសត្វល្អិត ដែលនាំមកដោយទឹកលំនាច ។ ពួកវាមិនខ្លាចនឹងទឹក ហើយវាហែលយ៉ាង ស្ទាត់ជំនាញ ស្វាឈ្មោលអាចមុជទឹកបានចំងាយ ៥០ម ។ ស្វាក្តាមចូលចិត្តលោតពីដើមឈើចូលក្នុងទឹកម្តង ហើយម្តងទៀត ។ វារស់នៅជាហ្វូងធំច្រើនជាង ១០០ក្បាល ។ ស្វាក្តាមមានទំលាប់លូកដៃរបស់វានៅក្នុង រន្ធតូច ឬប្រហោងដើម្បីរកក្តាម ឬសត្វដទៃ ។

**របាយ និង ស្ថានភាព** : ស្វាក្តាមសំបូរនៅតំបន់ជុំវិញ បឹងទន្លេសាប និង តំបន់ឆ្នេរវាលភក់ព្រៃ កោងកាង ។ ត្រូវបានហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និងត្រូវបានចំណាត់ថ្នាក់ ជាប្រភេទជិតទទួលរងការគំរាមកំហែងលើពិភពលោកក្នុងបញ្ជីក្រហម IUCN (GT) និងស្ថិតក្នុងតារាងឧបសម្ព័ន្ធទី២ របស់អនុសញ្ញា CITES ។





## ១៨.ស្វាអង្កត់

**Stump-tailed Macaque**
***Macaca arctoides***

**ទំហំ** : ក្បាល-ដងខ្លួន :៤៨៥-៦៣៥ មម . ទំងន់ :៨-១២ គក្រ ។

**ភិនភាគ** : ស្វាអង្កត់ មានរូបរាងដូចស្វាគ្រោសបេះបិទ តែវាមានមាឌធំជាងបន្តិច ។ ផ្នែកលើនៃដងខ្លួន វាមានពណ៌ប្រែប្រួលពីខ្មៅស្រាលទៅស្ទូកូឡាស្រាល ទៅជាក្រហមព្រឿងៗ ហើយក្លាយជាពណ៌ប្រផេះ និង ពណ៌ប្រផេះស្រាលនៅពេលវាអាយុ ១ឆ្នាំ ។ រោមចាប់ពីស្មាចុះមកក្រោម និង ផ្នែកខ្នងវែងហើយរឹងក្រាស់ ពិសេសនៅពេលវាចាស់ ។ ផ្ទៃមុខគឺមិនមានរោមក្រាស់ ថ្ពាស់ទំពែកលយទៅមុខរាងចោត ។ រោមដុះពី ក្រោមចង្កាមានលក្ខណៈល្អជាងពុកចង្កា ។ ស្បែកមុខមានពណ៌ក្រហមឆ្នោត ហើយវាមានពណ៌ក្រហមខ្លាំង នៅពេលអាកាសធាតុក្តៅ និង ពេលមានតំរេកកាម ។ កន្ទុយវាមានរោមស្តើង ។

**ជីវសាស្ត្រ** : ស្វាអង្កត់ជាប្រភេទស្វាដែលរស់នៅតំបន់ខ្ពស់វាចំណាយពេលជាច្រើននៅលើដីដើម្បីរកចំណី ។ ពួកវាស៊ីគ្រាប់រុក្ខជាតិ សត្វល្អិត និង សត្វតូចជាអាហារ ។ ពួកវាអាចចូលព្រៃដើម្បីស៊ីផ្លែឈើ ផ្កាឈើ ។ ពួកវារស់នៅជាក្រុមតូចៗ ពេលខ្លះរហូតជាង ៥០ក្បាល ។

**របាយ និង ស្ថានភាព** : មានតិចតួច នៅភាគខាងលិចទន្លេមេគង្គ និងត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។



# ១៩.ស្វាព្រាម

## Silvered Langur
*Semnopithecus cristatus*

**ទំហំ** : ក្បាល-ដងខ្លួន : ៤៩៣-៥៧០ មម .កន្ទុយ :៧២៥-៨៤០ មម . ប្រវែងជើងមុខ : ១៣៨-១៥៦ មម ទំងន់ : ៦០៨គក្រ ។

**ពិពណ៌ន** : ផ្នែកលើនៃដងខ្លួនមានពណ៌ខ្មៅប្រផេះ ឬស្ទើរខ្មៅ និង រោមខ្លួនដែលបះៗមានពណ៌ស ។ រោមនៅផ្នែកក្រោមនៃជើងមានពណ៌ខ្មៅ និង ផ្នែកខាងក្រោយនៃភ្លៅមានពណ៌ប្រផេះ ហើយជើងទាំងអស់ មានពណ៌ប្រាក់ ។ ផ្ទៃមុខមានពណ៌ខ្មៅ ហើយគ្មានរង្វង់កង់ព័ទ្ធជុំវិញភ្នែកទេ និងមួយចំនួនមានច្រមុះមាត់ ពណ៌ស ។ មានដុះកញ្ចុំពុកមាត់វែងពណ៌សព្រឿងៗដុះព័ទ្ធជុំវិញផ្ទៃមុខស្ទើរតែលុបត្រចៀក ។ រោមក្បាល ដុះកញ្ចុំខ្ពស់ ហើយកាន់តែល្អទៅៗចំពោះស្វាចាស់ ។ កូនស្វាតូចមានពណ៌ទឹកក្រូចខ្ចី មានប្រអប់ដៃប្រអប់ ជើងពណ៌ខ្មៅ និង គ្មានរោមកញ្ចុំនៅលើក្បាលដូចស្វាចាស់ទេ ។ នៅពេលវាពេញវ័យ វាមានរោមពណ៌ ប្រផេះដែលដុះលាតសន្ធឹងរាលដល់ប្រអប់ជើងនិងកន្ទុយ ហើយការប្រែពណ៌នេះ វាបានចាប់ផ្តើមក្រោម អាយុ ៣ខែមកម្ល៉េះ ។

**ជីវសាស្ត្រ** : ស្វាព្រាមត្រូវបានគេប្រទះឃើញនៅព្រៃស្រោង និង តំបន់ឆ្នេរវាលភក់ព្រៃកោងកាង ។ ពួកវារស់នៅលើដីច្រើនជាងលើដើមឈើ ។ វាស៊ីផ្លែឈើ ស្លឹកឈើ ផ្កាឈើ ហើយនឹងសត្វល្អិត ។ វារស់នៅ ជាក្រុមដែលមានពី ១០-៤០ក្បាលឬច្រើនជាងនេះ ។ វាជាសត្វស្វាដែលស្ងៀមស្ងាត់បំផុត ។ វាមានពណ៌ប្លែកគ្នាជាច្រើនអាស្រ័យតាមតំបន់ដូចជាតំបន់ក្បែរឆ្នេរ តំបន់ទន្លេឬស្ទឹង តំបន់វាលភក់ តំបន់ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ។ ស្វាព្រាមកើតកូនក្នុងកំឡុងខែ ធ្នូ រហូតដល់ខែឧសភា ។

**របាយ និង ស្ថានភាព** : វាជាសត្វមិនសូវសំបូរ ។ ទីតាំងដែលសំខាន់ជាងគេ មាននៅព្រៃភ្នំក្រវាញ (ខេត្តកោះកុង-ពោធិសាត់) ភ្នំខាងជើងបឹងទន្លេសាប និង ព្រំប្រទល់កម្ពុជា-វៀតណាម ។ ត្រូវបានហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ត្រូវបានចំណាត់ថ្នាក់ ជាប្រភេទជិតទទួលរងការគំរាមកំហែងលើពិភព លោកក្នុងបញ្ជីក្រហម IVCN (NT) និង ស្ថិតក្នុងតារាង ឧបសម្ព័ន្ធ ទី១ របស់អនុសញ្ញា CITES ។





# ២០.ស្វាក្រទាត់ ឬស្វាកន្ទុយស

**Douc Langur**
*Pygathrix nemaeus*

**ទំហំ** :

**រូបភាព** : ជាស្វាមួយប្រភេទដែលមានលក្ខណៈខុសប្លែកពីគេ វាមានលក្ខណៈងាយស្រួលចំណាំដោយ សារពណ៌របស់វាមានច្រើន និងរោមវែងៗ រីឯស្វាដទៃមានពណ៌តែ-មួយប៉ុណ្ណោះ ។ នៅលើក្បាលមានរោម ពណ៌ខ្មៅដុះវែងបះទៅក្រោយ រោមដុះជុំវិញផ្ទៃមុខមានពណ៌ស ។ នៅលើផ្ទៃមុខ និង ប្រឡោកមាន ពណ៌ត្នោតខ្ចី ហើយព័ទ្ធជុំវិញបន្ថែមមួយជាន់ទៀតដោយពណ៌ត្នោតចាស់ ។ ផ្ទៃទាំងអស់នៃដងខ្លួនមាន ពណ៌ប្រផេះភ្លឺ លើកលែងតែផ្នែកចង្កេះ ប្រឡោះភ្លៅពណ៌ស ។ កន្ទុយពណ៌ប្រផេះ ជើងក្រោយមានពណ៌ក្រម៉ៅ ។

**ជីវសាស្ត្រ** : រស់នៅតំបន់ព្រៃស្រោង ហ្វូងរបស់វាពី ៤-៥ក្បាល ។ ជាពិសេសត្រង់ព្រំប្រទល់កម្ពុជា-ឡាវ-វៀតណាម ។ វាស៊ីផ្លែឈើ ផ្កា ស្លឹក ដូចប្រភេទស្វាដទៃ ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វកំរ វារស់នៅភាគខាងជើង និរតី និង ឥសាន នៃប្រទេស ។ ត្រូវបានចាត់ចូលក្នុងប្រភេទ ហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។ត្រូវបានចុះក្នុងបញ្ជីក្រហម IUCN(GT) ជាប្រភេទសត្វទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី១ របស់អនុសញ្ញា CITES ។





**ទំហំ** : ក្បាល-ដងខ្លួន :៤៧០-៤៩៥ មម . ទំងន់ :៤-៧ គក្រ ។

**ភិនភាគ** : មានរោម ស វែងដុះត្រង់ចេញក្រៅជុំវិញក្បាល ។ មានពណ៌សំគាល់ភេទដោយឡែកពីគ្នា គឺញីពណ៌ភ្លឺឬស្រាល ឯឈ្មោលពណ៌ខ្មៅ (ក្រម៉ៅ) ។ កូនទើបនឹងកើតមានពណ៌ប្រផេះស្រាល ។ នៅពេលវាមានអាយុពី ៤-៦ខែ មានដុះចេញនូវដុំខ្មៅពីរដុំ ។ ដុំនៅលើពំនូលក្បាលរាងដូចម្កុដ និង មួយទៀត នៅនឹងទ្រូង ។ នៅពេលវាមានអាយុ ៣-៤ឆ្នាំ ទោចឈ្មោលមានពណ៌ខ្មៅលើកលែងតែរង្វង់ផ្ទៃមុខ អង្គជាតិ និង ម្កុដដែលស្ថិតលើត្រចៀក ហើយពេលខ្លះនៅលើខ្នងនៃប្រអប់ជើង ជើងមានពណ៌ស ។ ទោចញីប្រែពណ៌ខ្មៅនៅពេលអាយុបាន ២ ឬ ៣ឆ្នាំ ហើយក្រោយមកប្រែពណ៌ទៅជាត្នោតភ្លឺវិញ ពេលវា ពេញវ័យមានដុំខ្មៅរាងត្រីកោណលើទ្រូង និងម្កុដខ្មៅលើក្បាល ។ ការប្តូរពណ៌នេះ ហាក់ដូចជាអាស្រ័យដោយសារអ័រម៉ូន ។

**ជីវសាស្ត្រ** : ទោចម្កុដ ត្រូវបានគេប្រទះឃើញនៅព្រៃស្រោង ។ ជាធម្មតាវារស់នៅជាក្រុមតូចៗ ពី ២-៦ក្បាល ។ ពួកវាចំណាយពេលជាច្រើននៅលើដើមឈើខ្ពស់ៗ ជារឿយៗវាតែងតែហក់លោតលើមែក ឈើមួយទៅមួយនៅពេលព្រឹក ។ អាហាររបស់វារួមមាន ផ្លែឈើ ស្លឹកឈើ ផ្កា សត្វល្អិត ពងសត្វស្លាប ។ ទោចញីមានកូនតែមួយគត់ បន្ទាប់ពីពរពោះ ២១០ថ្ងៃ ។ រយៈពេលមានកូន ពីមួយទៅមួយ (ចន្លោះ មានកូន) ២-៣ឆ្នាំ ។ នៅពេលកូនទោចអាយុប្រហែលមួយឆ្នាំ វាចាប់ផ្តើមរៀនលោតតោងដើមឈើជិតៗមេវា ។

**របាយ និង ស្ថានភាព** : ជាមធ្យមមាននៅតំបន់ភាគខាងជើង និង និរតី ។ ត្រូវបានហាមឃាត់ការ បរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ជាប្រភេទសត្វត្រូវបានចំណាត់ថ្នាក់ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោកក្នុងបញ្ជីក្រហម IVCN(GT) និងស្ថិតក្នុង តារាងឧបសម្ព័ន្ធទី១ របស់អនុសញ្ញា CITES ។





# ២២.ទោចថ្ពាល់លឿង Yellow-cheeked Gibbon *Hylobates gabriellae*

**ទំហំ** : វាមានទំហំ ប្រហាក់ប្រហែល ឬតូចជាង ទោចម្កុដបន្តិច ។

**ពិពណ៌នា** : ចំពោះប្រភេទនេះមានរូបរាង និងពណ៌ប្រហាក់ប្រហែលគ្នានឹងទោចម្កុដដែរ រួមទាំងការប្រែ ពណ៌ផង ។ ប៉ុន្តែគេអាចកត់សំគាល់បានដោយសារសត្វឈ្មោលមានសំបុរ ខ្លួន ដៃ ជើង ពណ៌ខ្មៅ និងមានរោមថ្ពាល់ពណ៌លឿង ។ ចំណែកសត្វញីវិញ ពេល វាពេញវ័យមានសំបុរត្នោត ពុំមានពណ៌ខ្មៅលើទ្រូងទេ ប៉ុន្តែមានដុំខ្មៅនៅលើទទួលក្បាល និងថ្ពាល់មានរោមលឿងរាងដូចធ្មិត ។ ការប្តូរពណ៌នេះ ហាក់ដូចជាអាស្រ័យដោយសារ អ័រម៉ូន ។

**ជីវសាស្ត្រ** : ទោចថ្ពាល់លឿងត្រូវបានគេប្រទះឃើញនៅព្រៃស្រោង ។ ជាធម្មតាវា រស់នៅជាក្រុមតូចៗ ពី២-៦ក្បាល ។ ពួកវាចំណាយពេលជាច្រើននៅលើដើមឈើខ្ពស់ៗ ជារឿយៗវាតែងតែហក់លោតលើមែកឈើមួយទៅមួយនៅពេលព្រឹក ។ អាហាររបស់ វារួមមាន ផ្លែឈើ ស្លឹកឈើ ផ្កា សត្វល្អិត ពងសត្វស្លាប ។ ទោចញីមានកូនតែមួយគត់ បន្ទាប់ពីពរពោះ ២១០ថ្ងៃ ។ រយៈពេលមានកូន ពីមួយទៅមួយ (ចន្លោះ មានកូន) ២-៣ឆ្នាំ ។ នៅពេលកូនទោចអាយុប្រហែលមួយឆ្នាំ វាចាប់ផ្តើមរៀនលោតតោងដើមឈើ ជិតៗមេវា ។

**របាយ និង ស្ថានភាព** : មានជាមធ្យម នៅតំបន់ភាគខាងកើតទន្លេមេគង្គ ។ ត្រូវបានហាមឃាត់ការ បរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និង នេសាទ និង ជាប្រភេទសត្វទទួលរងការ គំរាមកំហែងលើពិភពលោកដែលបានចុះក្នុង បញ្ជីក្រហម IUCN(DD) និងស្ថិតក្នុងតារាងឧបសម្ព័ន្ធទី១របស់អនុសញ្ញា CITES ។







## ២៣.ឆ្កែចចក Asiatic Jackal *Canis aureus*

**ទំហំ** : ក្បាល-ដងខ្លួន : ៦០០-៧៥០ មម . កន្ទុយ : ២០០-២.៥០០ មម . ទំងន់ : ៨-៩ គក្រ

**ពិពណ៌ន** : ឆ្កែចចកមានរូបរាងស្រដៀងនឹងឆ្កែស្រុកដែរ តែវាមានកន្ទុយដែលមានរោមក្រាស់ឡើងសំពោង ហើយវែង១ ភាគច្រើនមានសំបុរពណ៌ប្រផេះត្នោតឬប្រផេះលឿង ។ មានកន្ទុយត្រង់មិនឡើនដូចឆ្កែស្រុក ។

**ជីវសាស្ត្រ** : ហើយជាទូទៅសត្វឈ្មោលជា អ្នកមើលថែរក្សាកូនតូច១ច្រើន ជាងសត្វញី ។ ចចកជាសត្វរកស៊ីនៅពេលយប់ ពួកវាតែងបញ្ចេញសំលេងលូនៅពេលយប់ងងឹតនិង នៅពេលព្រលឹមស្រាង១ ។ ឆ្កែចចកចូលចិត្តរស់នៅជាក្រុម ដែលក្នុងមួយហ្វូងមានចចកដល់ទៅ ២០ក្បាល ហើយ ដែនដីរបស់ពួកវាត្រូវកំណត់ដោយក្លិនទឹកនោម ។ ឆ្កែចចកច្រើនរស់នៅតាមតំបន់ព្រៃល្បោះ តាមវាលស្មៅ ហើយជាញឹកញាប់វាចេញរកស៊ីនៅក្បែរ១ ភូមិដ្ឋានរបស់អ្នកស្រុក ដែលសំបូរដោយអាហារផងដែរ ។ ឆ្កែចចកស៊ីសាច់ជាអាហារ ដូចជា ទន្សាយ ឈ្លូស ប្រើស បក្សី ល្មូន កង្កែប និងផ្លែឈើ ។ ឆ្កែចចកតែងតែព្រួតគ្នាដេញចាប់សត្វ ព្រោះការដេញ ចាប់តែឯកឯង មិនសូវជាទទួលបានជោគជ័យទេ ជួនកាលពួកវាក៏នាំគ្នាដណ្តើមយកសាច់ពីខ្លា ឬម៉សាសត្វ ផ្សេង១ដែលចាប់សត្វបានផងដែរ ។ វាអាចមានជីវិតរស់រហូតដល់ ១៦ឆ្នាំ ។ ឆ្កែចចកមេផ្តល់កំណើត ក្នុងមួយលើកបានកូនពី ២-៧ក្បាល ។ ហើយជាទូទៅសត្វឈ្មោលជាអ្នកមើលថែរក្សាកូនតូច១ច្រើនជាង សត្វញី ។

**របាយ និង ស្ថានភាព** : គេប្រទះឃើញឆ្កែចចកសំបូរជាមធ្យមនៅប្រទេសកម្ពុជា ។ វាមានស្ទើរតែ គ្រប់ទីកន្លែង ។ ឆ្កែចចកត្រូវបានហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និងស្ថិតក្នុងតារាងឧបសម្ព័ន្ធទី៣ របស់អនុសញ្ញា CITES ។





# ២៤.ឆ្កែព្រៃ Dhole *Cuon alpinus*

**ទំហំ** : ក្បាល-ដងខ្លួន : ៨០០-៩០០ ម , ទំងន់ :១០-២០ គក្រ ។

**ពិពណ៌ន** : ឆ្កែព្រៃមានមាឌធំជាងឆ្កែចចក មានសំបុរក្រហមត្នោត និង កន្ទុយសំពោងវែងជាងកន្ទុយឆ្កែ ចចក ។

**ជីវសាស្ត្រ** : ឆ្កែព្រៃចូលចិត្តរស់នៅជាហ្វូង ។ វាចូលចិត្តរស់នៅតំបន់ព្រៃភ្នំក្រាស់ៗ តាមក្រហែងថ្ម ម្លប់ឈើស៊ុបទ្រុប ។ ឆ្កែព្រៃមានលទ្ធភាពចាប់សត្វដែលមានមាឌធំជាងខ្លួនវាមកធ្វើជាចំណីដូចជា សត្វ ឈ្លូស ប្រើស ជាដើម ។ នៅពេលហោមព័ទ្ធចាប់សត្វជាចំណី ពួកឆ្កែព្រៃតែងដេញបណ្តាក់គ្នាដើម្បីឱ្យ សត្វនោះអស់កំលាំង ។ ឆ្កែព្រៃចូលចិត្តចេញទៅរកចំណីនៅ ពេលព្រលប់ងងឹតព្រាលៗ និង ពេលព្រឹក ព្រលឹមស្រាងៗ ។ វារត់បានលឿន អាចលោតផ្លោះបានចំងាយ ដល់ ៦ម និងអាចហក់បានកំពស់ដល់ទៅ ៣.៥ម ។ ឆ្កែព្រៃអាចមានជីវិតរស់នៅរហូតដល់អាយុ ១៥ឆ្នាំ។ ឆ្កែព្រៃមច្រើនផ្តល់កំណើតឱ្យកូននៅខែ វិច្ឆិកា-កុម្ភៈ វាអាចបង្កើតកូនមួយលើកបានពី ១-៤ក្បាល ។

**របាយ និង ស្ថានភាព** : ឆ្កែព្រៃមានជាមធ្យម និង មាននៅស្ទើរគ្រប់ទីកន្លែងដូចជា តំបន់ភាគឥសាន្ត ភាគនិរតី និង ភាគខាងជើងនៃប្រទេស និង ជាប្រភេទត្រូវបានហាមឃាត់ការបរបាញ់ដោយប្រកាស របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទ ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី២ របស់អនុសញ្ញា CITES ។





# ២៥.ខ្លាឃ្មុំធំ Asiatic Black Bear *Ursus thibetanus*

**ទំហំ** : ក្បាល-ដងខ្លួន :១.២០០-១.៥០០ មម . ទំងន់ : ១០០-២០០ គក្រ ។

**រូបភាព** : ខ្លាឃ្មុំធំមានមាឌធំជាងគេក្នុងចំណោមប្រភេទសត្វខ្លាឃ្មុំ ដងខ្លួនរបស់វាគ្របដណ្តប់ដោយរោម ក្រាស់វែងៗ ពណ៌ត្នោត ឬខ្មៅ និងមានឆ្នូតពណ៌លឿងខ្ចី រាងជាអក្សរវេ (V) នៅក្រោម ក ។ មានស្លឹកត្រចៀកវែងធំជាងខ្លាឃ្មុំតូច ។

**ជីវសាស្ត្រ** : វាច្រើនចេញរកចំណីនៅពេលយប់ ចូលចិត្តរស់នៅតាមតំបន់ព្រៃភ្នំ និងនៅតាមវាល ស្មៅនៃតំបន់ខ្ពង់រាប ។ វាចូលចិត្តឡើងដើមឈើធំៗ ដើម្បីរកចាប់ចំណីអាហារ ហើយវាក៏ចូលចិត្តដេក ននៀលលេងភក់នៅតាមថ្លុកនានា កាលណាវាលេងភក់អស់ចិត្ត វាក៏ឡើងមកសំងិលខ្លួនឱ្យស្ងួត ។ វាក៏ ចូលចិត្តកាច់មែកឈើ យកមកធ្វើជាជំរក ឬដកកូនឈើតូចៗ ដើម្បីស៊ីឬសផងដែរ ។ វាចូលចិត្តដេក នៅលើបង្គាបឈើក្រោមចន្លោះឬសឈើធំៗ ឬ ក្នុងរូងថ្ម ហើយ វាដេកលក់ស្កប់ស្កល់ និងស្រមុកឮខ្លាំងៗ វាមិនងាយភ្ញាក់ពីដេក ដោយសំលេងក្តុងក្តាំងឡើយ ។

ខ្លាឃ្មុំធំចូលចិត្តស៊ីផ្លែឈើ សត្វល្អិត បក្សី គមង្វង (តមង្វងប្រេង) ផ្លែពោត និង ត្រី ជាអាហារ។ សត្វខ្លាឃ្មុំមេ អាចបង្កើតកូនបានម្តងពី ១-៣ក្បាល ហើយដោយកម្រ អាចកើតបាន ៤-៦ក្បាល សត្វញីពរពោះក្នុងរយៈពេល ៨ខែ ។ សត្វខ្លាឃ្មុំធំវាមានជីវិតរស់នៅរហូតដល់ ៣៧ឆ្នាំ ។

**របាយ និង ស្ថានភាព** : បច្ចុប្បន្ននេះ នៅប្រទេសកម្ពុជា គេប្រទះឃើញខ្លាឃ្មុំធំដោយកម្រ ។ ខ្លាឃ្មុំធំត្រូវបានហាមឃាត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងត្រូវចុះក្នុង បញ្ជីក្រហម IUCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាង ឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។





# ២៦.ខ្លាឃ្មុំតូច Sun Bear *Vrsus malayanus*

**ទំហំ** : ក្បាល-ដងខ្លួន :១.០០០-១.៤០០ មម . ទំងន់ : ២៧-៦៥ គក្រ ។

**ពិពណ៌ន** : ខ្លាឃ្មុំតូចមានមាឌតូចជាងគេក្នុងចំណោមប្រភេទខ្លាឃ្មុំលើពិភពលោក ។ ដងខ្លួនរបស់វាគ្រប ដណ្ដប់ដោយរោមក្រាស់ខ្លីៗ ពណ៌ខ្មៅរលោង និង មានស្នាមឆ្នូតពណ៌លឿងខ្ចីរាងជាអក្សរអ៊ុយ (V) នៅក្រោម ក របស់វា ។

**ជីវសាស្ត្រ** : ខ្លាឃ្មុំតូចចូលចិត្តរស់នៅតំបន់ព្រៃស្គុក ភាគច្រើនពួកវាចេញរកចំណីនៅពេលយប់ ។ វាស៊ី ចំណីដូចជា ឃ្មុំ ពង្រូត ស្រមោច សត្វល្អិតផ្សេងៗ ពពួកបក្សី ត្រី ផ្លែឈើ គបដូងជាអាហារ ។ ខ្លាឃ្មុំតូច វាអាចវាយប្រហារសត្រូវ និងចាប់សត្វជាចំណីដោយប្រើជើងមុខទាំងគូរបស់វាដែលមានក្រចកដ៏រឹងមាំ ។ សត្វមេបង្កើតកូនម្ដងបាន ១-២ក្បាល ដោយកម្រអាចកើតបានកូនពី ៤-៦ក្បាល វាមានគភ៌រយៈពេល ៨ខែ ។ ខ្លាឃ្មុំតូចជាសត្វពូកែឡើងដើមឈើដើម្បីរកអាហារជាងគេក្នុងចំណោមសត្វខ្លាឃ្មុំគ្រប់ប្រភេទ ។ វា ដេក មិនរើសកន្លែង និង ស្រមុកឮខ្លាំងៗផងដែរ ។ វាជាសត្វដែលមានការប្រុងប្រយ័ត្ន ហើយឆ្លាតវាងវៃ តែវាចូលចិត្តរស់នៅដោយស្ងៀមស្ងាត់ ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វមានជាមធ្យមដែលមាននៅតំបន់ភូមិភាគឥសាន្ត និរតី និង ភាគខាងជើងនៃប្រទេស ។ ប្រភេទនេះត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (DD) ជាប្រភេទពុំទាន់មានទិន្នន័យ គ្រប់គ្រាន់ និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។





# ២៧.សំពោចកលឿង

**Yellow-throated Marten**
*Martes flavigula*

**ទំហំ** : ក្បាល-ដងខ្លួន :៤៥០-៦០០ មម , កន្ទុយ :៣៨០-៤៣០ មម , ទំងន់ :២-៣ គក្រ ។

**ភិនភាគ** : សត្វនេះមានរាងរៅប្រហាក់ប្រហែលនឹងសត្វសំពោច មានរាងស្តើងទ្រវែង ។ វាមានខ្លួន ពណ៌ត្នោត រីឯក្បាលផ្នែកខាងលើកន្ទុយ និង ជើង ពណ៌ខ្មៅ លក្ខណៈពិសេសងាយស្រួលសំគាល់នោះ គឺ ចាប់ពីចង្កាដល់ទ្រូងមានពណ៌លឿងខ្ចី ។

**ជីវសាស្ត្រ** : ជាសត្វអាចរស់នៅក្នុងជំរកគ្រប់ប្រភេទជំរក ប៉ុន្តែវាចូលចិត្តរស់នៅក្នុងព្រៃជាង ជាសត្វដែល អាចឡើងចុះដើមឈើបានលឿន ជាញឹកញាប់វាចុះមកក្រោមដើម្បីរកចំណី។ វាច្រើនរកស៊ីនៅពេលថ្ងៃជាគូៗ ឬក្រុម ជួនកាលពេលយប់ផងដែរ ។ ចំណីរបស់វាមានដូចជា កំប្រុក សត្វស្លាប ពស់ អំបូរបង្គួយ សត្វល្អិត ស៊ុត កង្កែប ផ្លែឈើ ឬទឹកឃ្មុំផងដែរ ។ សត្វនេះមានកូនជា មធ្យម ៣ ប៉ុន្តែអាចមានដល់ ៥ ហើយកូនរបស់វាមានទំងន់ស្មើនឹងសត្វពេញវ័យក្នុងរយៈពេល ៣ខែ ។ អាយុកាលរបស់វាគឺ ១៤ឆ្នាំ ។

**របាយ និង ស្ថានភាព** : មាននៅប៉ែកឥសាន្តប្រទេសកម្ពុជា និងពុំទាន់មានទិន្នន័យច្បាស់លាស់នៅឡើយ ។ មិនទាន់បានបែងចែកជាប្រភេទការពារនៅក្នុងប្រកាសនៅឡើយ ប៉ុន្តែវាបានចាត់ចូលក្នុងបញ្ជី ឧបសម្ព័ន្ធទី ៣ របស់អនុសញ្ញា **CITES** ។





# ២៨. ជ្រូកពោន(ជ្រូកព្រុល)

**Hog Badger**
***Arctonyx collaris***

**ទំហំ** : ក្បាល-ដងខ្លួន : ៦៥០-១.០៤០ មម. កន្ទុយ : ១២០-១៧០ មម. ទំងន់ : ៧-១៤ គក្រ ។

**ពិពណ៌នា** : មានរាងរៅដូចខ្លាឃ្មុំ ប៉ុន្តែតូចហើយធាត់ ជើងរបស់វាធំៗ និង មានក្រចកកោងវែងៗពណ៌ស ច្រមុះដូចជ្រូករាងទ្រវែង ។ វាមានសម្បុររាងប្រផេះលឿងបន្តិចឬខ្មៅប្រែប្រួលទៅតាមរដូវ ផ្នែកខ្នង ខាងលើពណ៌ក្រម៉ៅជាងផ្នែកខាងក្រោម ។ នៅលើក្បាលមានឆ្នូតពណ៌ស ពីចុងច្រមុះរហូតដល់ថ្ងាស ឆ្នូត ខ្មៅនៅសងខាងភ្នែកដល់ត្រចៀក បន្ទាប់មកមានឆ្នូតសកាត់តាមថ្ពាល់ ផ្នែកខាងលើ ទ្រូង ត្រចៀក ពណ៌ស ។

**ជីវសាស្ត្រ** : រស់នៅតែលើដី តាមរូង ឬក្រហែង និងរកស៊ីនៅពេលយប់ ។ វាមិនសូវពូកែភ្នែក និង ត្រចៀកទេ វាប្រើច្រមុះហិតក្លិនច្រើនជាង ការរកចំណីចាប់ផ្តើមចេញនៅពេលព្រលប់នៅតាមតំបន់ព្រៃ ចំណីរបស់វាគឺមើមរុក្ខជាតិ ឫសឈើ ជន្លេន សត្វ ល្អិត និង សត្វតូចៗ ។ វាអាចមានកូនពី ២-៣ក្បាល និងមានអាយុកាលទៅដល់ ១៤ ឆ្នាំ (ការចិញ្ចឹម) ។

**របាយ និង ស្ថានភាព** : មាននៅតាមតំបន់ព្រៃស្ទើរទូទាំងផ្ទៃប្រទេស ពិសេសគឺនៅភាគឥសាន្ត ប្រទេស ។ ជាប្រភេទដែលត្រូវការពារ ដែលបានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។


13 1



# ២៩.ស្អក

## Large-toothed Ferret Badger
*Melogale personata*

**ទំហំ** : ក្បាល-ដងខ្លួន : ៣៣០-៣៩០ មម. កន្ទុយ : ១៤៥-២១០ មម. ទំងន់ : ១-៣ គក្រ ។

**ពិពណ៌ន** : មានរូបរាងប្រហាក់ប្រហែលនឹងជ្រូកពោន ប៉ុន្តែវាមានមាឌតូចជាងច្រើន ជើងរបស់វាខ្លីមាន ម្រាមឃ្លាត១ពីគ្នា និង ក្រចកវែងហើយខ្លាំង ។ វាមានសម្បុរត្នោតខ្ចីរហូតដល់ខ្មៅ និង ប្រែប្រួល ទៅតាមរដូវ នៅចន្លោះភ្នែកទាំងពីរមានកញ្ចុំសមួយជុំមានឆ្នូតសចាប់ពីក្បាលរហូតដល់ពាក់កណ្តាលដងខ្លួន ។ នៅផ្នែកខាងក្នុងត្រចៀក បំពង់ក និង សៀតថ្ពាពណ៌ស រីឯផ្នែកក្បាលក្រៅពីនេះពណ៌ខ្មៅ ។

**ជីវសាស្ត្រ** : ការរស់នៅដូចជ្រូកពោន គឺរកស៊ីនៅពេលយប់ និង ចំណាយពេលច្រើននៅក្នុងក្រហែង ឬ រូង ។ ទីជំរករបស់វាអាចមានពីតំបន់ព្រៃរហូតដល់វាលស្រែ ហើយវាក៏អាចឡើងដើមឈើផងដែរ ដើម្បីរកចំណីដូចជា ខ្លង និង សត្វល្អិតនៅតាមដើមឈើ វាចូលចិត្តស៊ីតែសត្វមានជីវិតដូចជា ក្រឡាត កណ្តូប និង ជន្លេន ដោយប្រើក្រចកវែងកាយដី ។ ការបន្តពូជរបស់វាគឺនៅចុងរដូវប្រាំង កូនរបស់វាធាប់ធំ ប៉ុន្តែត្រូវពឹងផ្អែកទៅលើទឹកដោះមេរហូតស្ទើរតែពេញវ័យ ។ វាអាចមានកូនដល់ទៅ ៣ក្បាល ។

**របាយ និង ស្ថានភាព** : មិនទាន់មានពត៌មានច្បាស់លាស់នៅឡើយ ។







## ៣០.ភេខ្យាលសំប៉ែត Eurasian Otter *Lutra lutra*

**ទំហំ** : ប្រវែងក្បាល ដងខ្លួន ៥៥០-៧២០ ម.ម កន្ទុយ ៣៥០-៤០០ ម.ម ទំងន់ ៣-៥ គ.ក្រ

**ភិនភាគ** : វាមានក្បាលសំប៉ែតធំទូលាយ ត្រចៀកតូចមូល ច្រមុះក្រាស់ដងខ្លួនស្រាវ កន្ទុយវែង និង មានគល់កន្ទុយ ធំ ព្រមទាំងមានសាច់ដុំអាចបត់បែនបាន។ ដងខ្លួនគ្រប ដណ្តប់ដោយរោមពណ៌ខ្មៅរលោង និង មានស្លាប មួយ១ផង ។ វាមានរោមខ្លីហើយក្រាស់ ផ្នែកពោះមានសម្បុរត្នោតភ្លឺ ។ សត្វ ឈ្មោលធំជាងសត្វញី ។

**ជីវសាស្ត្រ** : វារស់នៅជាក្រុមឬជាគូរតាមតំបន់មាត់ទឹកក្បែរភ្នំ មាត់ស្ទឹង បឹង ត្រពាំង និងទន្លេ ដែលជាកន្លែងសំបូរត្រី សំរាប់ធ្វើជាអាហាររបស់វា ។ សំបុករបស់វាស្ថិតក្នុងរូង ក្រោមដី ក្រោមផ្ទាំងថ្មធំៗ ក្រោមឫសឈើ ឬ ក្នុងគម្ពោតព្រៃក្បែរមាត់ទឹក ។ ជាទូទៅ វារកចំណីតែម្នាក់ឯង ពេលខ្លះជាក្រុមគ្រួសារតូចៗ ដោយតៀងត្រីពី ទឹកជ្រៅមកទឹករាក់ ដើម្បីងាយស្រួលក្នុងការចាប់ធ្វើជាចំណី ។ វាចូលចិត្តរកចំណីនៅពេលយប់ ហើយពេល ខ្លះក៏ឃើញវារកនៅពេលថ្ងៃដែរ ។ ចំណីអាហាររបស់វាមាន ត្រី ក្តាម កង្កែប កំពឹស មាន់ ទា កណ្តុរប្រែង បក្សី បង្កង និងសត្វឥតឆ្អឹងកង ។ វាអាចដើរបានឆ្ងាយពីស្ទឹងមួយ ទៅ ស្ទឹងមួយទៀត ។ ភេញីមានគភ៌រយៈពេល៦១ថ្ងៃ កូនម្តងបានពី ២-៣ក្បាល ហើយ វាចញ្ចឹមកូនដោយទឹក ដោះរហូតដល់កូនវាមានអាយុជិតពេញវ័យ ។ អាយុកាលរបស់ វាអាចរហូតដល់ ១៥ឆ្នាំ ។

**របាយ និង ស្ថានភាព** : ពុំទាន់មានពត៌មានច្បាស់លាស់ ប៉ុន្តែត្រូវបានចុះក្នុង តារាងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។



# ៣១.ភេរោមច្រមុះ

**ទំហំ** : ប្រវែងក្បាល ដងខ្លួន ៥០០-៨២០ ម.ម    កន្ទុយ ៣៥០-៥០០ ម.ម

ទំងន់ ៧-១១ គ.ក្រ

**រូបភាព** : រោមនៅផ្នែកខាងលើ ក មានពណ៌ក្រម៉ៅរលោង ជួនកាលផ្នែកខ្លះ មានពណ៌ស និង មានរោមនៅលើចុងច្រមុះ ។ ផ្នែកពោះ ចុងជើង និង ក្រោមចង្កា មានពណ៌សភ្លឺថ្លាជាងផ្នែកខាងខ្នង ។ បបូរមាត់ខាងលើ និងចង្កាមានពណ៌ស ។ ម្រាមជើង មានភ្នាសក្រាស និងក្រចកមាំ បំពង់កពេលខ្លះមានពណ៌ស ផ្នែកខាងខ្នងមានសម្បុរត្នោតក្រម៉ៅ ។

**ជីវសាស្ត្រ** : វារស់នៅជាក្រុមមានពី៥-១០ក្បាល ។

**របាយ និង ស្ថានភាព** :ជាប្រភេទសត្វកម្រ មាននៅតំបន់ព្រៃលិចទឹកបឹងទន្លេសាប និង ត្រូវបានចុះក្នុងបញ្ជីក្រហម IUCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ២ របស់ អនុសញ្ញា CITES ។



# ៣២.ភេខ្លួនរលោង

**Smooth Otter**
*Lutrogale perspicillata*

**ទំហំ** : ប្រវែងក្បាល ដងខ្លួន ៦៥៥-៧៥០ ម.ម កន្ទុយ ៤០៦-៥០៥ ម.ម ទំងន់ ៧-១១ គ.ក្រ

**ភិនភាគ** : ជាប្រភេទភេដែលធំជាងគេនៅអាស៊ីអាគ្នេយ៍ ។ មានក្បាលរាងមូល ហើយរោមរបស់វារលោង ខ្វីផ្នែកខ្នងមានសម្បុរពណ៌ត្នោតក្រម៉ៅផ្នែកពោះមានសម្បុរ ស ជាងខ្នងហើយផ្នែកខាងក្រោមក មានសម្បុរស្រាលជាងផ្នែកពោះ ។ កន្ទុយសំប៉ែត ក្រចកមាំហើយធំ និងមានម្រាមជើងជាប់គ្នាដោយភ្នាសស្បែកដូចជើងទា ។ សត្វឈ្មោលធំជាងញី ។

**ជីវសាស្ត្រ** : វារស់នៅក្នុងរយៈកំពស់ទាប តាមដងអូរ បឹង ត្រពាំង ព្រែក ។ ចំណីអាហាររបស់វាមានកង្កែប កណ្ដុរ ត្រី បក្សី ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វសំបូរជាមធ្យម មានស្ទើរគ្រប់ទីកន្លែង និងតាមបណ្ដោយឆ្នេរសមុទ្រ ព្រៃកោងកាង។ ជាប្រភេទដែលត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទដែលទទួលរងការ គំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។





# ៣៣.ភេតូច

## Oriental Small-clawed Otter
*Aonyx cinerea*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៤០៦-៦៣៥ ម.ម   កន្ទុយ ២៤៥-៣៥០ ម.ម

ទំងន់ ១-៣ គ.ក្រ

**រូបភាព** : វាជាប្រភេទភេ ដែលមានមាឌតូចជាងគេ ។ ផ្នែកបំពង់ក មានពណ៌ប្រផេះក្រម៉ៅ ផ្នែកពោះមានពណ៌ស ថ្លាភ្លឺជាងផ្នែកឯទៀត ។ សម្បុរផ្នែកបំពង់កផ្លាស់ប្តូរទៅតាមរដូវកាល ។ ម្រាមជើងជាប់គ្នាដោយភ្នាសស្បែក ដូចជើងទា ។ កន្ទុយធំមាំហើយខ្លី ។

**ជីវសាស្ត្រ** : វារស់នៅជាក្រុមតូចៗពី៤-១២ក្បាលក្នុងរូងដី ត្រពាំង ភក់ និងក្នុងតំបន់ដីសើម ។ សត្វឈ្មោលធំជាង ញី ។ ភេញីកើត កូនម្តងបានពីរឬបីក្បាល ហើយអាចកើតកូនបានពីរដងក្នុងមួយឆ្នាំ ។ ក្រោយពេលកើតបាន ៤០ថ្ងៃ ទើបកូនភេអាចបើកភ្នែកបាន ។ ចំណី អាហាររបស់វាមាន ត្រី បង្គា ក្តាម ងៀវ គ្រំ ។

**របាយ និង ស្ថានភាព** : មានជាប្រភេទសត្វមិនសូវសំបូរ ត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (NT) ជាប្រភេទជិត ទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។







## ៣៤.ខ្ទីន Large Indian Civet *Viverra zibetha*

**ទំហំ** : ក្បាល-ដងខ្លួន : ៧៥០-៨៥០ មម. កន្ទុយ ៣៥០-៤៦០ មម. ទំងន់ ៨-៩ គក្រ ។

**រូបភាព** : ជាសត្វសំពោចដែលមានមាឌធំ មានលក្ខណៈសំគាល់ពិសេសដោយបំពង់កមានឆ្នូតស-ខ្មៅធំៗ កន្ទុយមានបង្កង់ស-ខ្មៅពី ៦-៧ ។ ចាប់ពីករហូតដល់ចុងខ្នងមានរោមប្រែងពណ៌ខ្មៅ ភ្លៅ និង ផ្នែក ចំហៀងខ្លួនមានឆ្នូតពពាលៗខ្មៅ-ស ពណ៌ជើងមុខរាងត្នោតចាស់ ឯជើងក្រោយពណ៌ត្នោតខ្ចី នៅបបូរមាត់ លើ និង ក្នុងត្រចៀកពណ៌ស ។ កូនទើបនឹងកើតភាគច្រើនមានសម្បុរខ្មៅ ។

**ជីវសាស្ត្រ** : វារស់នៅតាមព្រៃល្បោះ ពិសេសគឺស្ថិតនៅក្បែរៗភូមិប្រជាជន ។ វាជាសត្វចេញរកស៊ី ពេលយប់ រីឯពេលថ្ងៃវានៅក្នុងក្រោមព្រៃគម្ពោតដែលមានស្មៅក្រាស់ៗ ឬក៏ក្នុងរន្ធ ។ វាជាសត្វរស់នៅ លើដី ហើយចំណីរបស់វាគឺ ត្រី សត្វស្លាប ស៊ុត ថ្លែនបង្កួយ ពស់ កង្កែប សត្វល្អិត កណ្តុរ ផ្លែឈើ និង ឫសឈើផងដែរ ។ ជាសត្វដែលចូលចិត្តលបចាប់មាន់ និង រកស៊ីនៅតាមគំនរសំរាម ។ ខ្ទីនអាច បង្កើតកូនបានពីរលើកក្នុងមួយឆ្នាំ វាអាចកើតកូនម្តងបានពី ២-៤ក្បាល ។ ក្នុងរយៈពេល ១០ថ្ងៃទើបកូន វាអាចបើកភ្នែកបាន អាយុកាលរបស់វា ១៥ឆ្នាំ (ការចិញ្ចឹម) ។

**របាយ និង ស្ថានភាព** : មានតិចតួច ។ ស្ថិតក្នុងបញ្ជីឧបសម្ព័ន្ធទី ៣ របស់អនុសញ្ញា CITES ។







# ៣៥.សំពោចធំ

**Large-spotted Civet**
*Viverra megaspila*

**ទំហំ** : ក្បាល-ដងខ្លួន : ៧២០-៨៥០ មម. កន្ទុយ : ៣០០-៣៦៩ មម. ទំងន់ : ៥-៩ គក្រ ។

**ភិនភាគ** : មានរូបរាងប្រហាក់ប្រហែលនឹងសត្វឈ្មើន ប៉ុន្តែវាខុសគ្នាត្រង់សត្វនេះមានជុំខ្មៅអុចៗនៅតាម ផ្នែកចំហៀងខ្លួន ភ្លៅនឹងជើងក្រោយ ។ រោមប្រែងដែលមាននៅលើឈ្មើនបានបញ្ចប់នៅត្រឹមចុងខ្នង ប៉ុន្តែសត្វនេះមានរោមប្រែងអូសបន្លាយរហូតដល់ចុងកន្ទុយ ។ ដូច្នេះកន្ទុយរបស់វាមិនមានវ័ណ្ឌពណ៌សព័ទ្ធ ជុំវិញទាំងស្រុងឡើយ ។ សំបុររបស់វាមានពីប្រផេះរហូតដល់ត្នោត ។ ក្បាល មាត់ របស់វាធំជាងឈ្មើន ។ ផ្នែកខាងក្រោមខ្លួនមានពណ៌ពី ប្រផេះរហូតដល់ត្នោត ជើងទាំង ៤ ពណ៌ត្នោតសុទ្ធ ។

**ជីវសាស្ត្រ** : រស់នៅតាមតំបន់ព្រៃផ្សេងៗ ពិសេសនៅតាមក្បែរៗភូមិ ឬតាមត្រពាំងនៅក្នុងព្រៃល្បោះ ។ វាតែងតែរកចំណីតែឯងនៅតាមគម្ពោតព្រៃតូចៗឬធំ វាអាចឡើងដើមឈើបាន ។ ការរកចំណី ប្រព្រឹត្តទៅនៅពេលយប់ ហើយចំណីទាំងនោះរួមមានកណ្តុរ មាន់ និង ផ្លែឈើ ។

**រោយ និង ស្ថានភាព** : មានតិចតួច ។



# ៣៦.សំពោចខ្លី(ឈ្មុសខ្លី)

**ទំហំ** : ក្បាល-ដងខ្លួន : ៥៤០-៦៣០ មម. កន្ទុយ : ៣០០-៤៣០ មម. ទំងន់ : ២-៤ គក្រ ។

**ពិពណ៌នា** : វាមានរូបរាងតូច ជើងរបស់វាខ្លីជាងសត្វខ្ទីន កន្ទុយមានបង្កង់ខ្មៅ-ស ពី ៦-៩ នៅខាងចុង គឺពណ៌ស ។ ខ្លួនរបស់វាមានដុំខ្មៅតូចៗ ហើយមានរោមស-ខ្មៅនៅក មិនបង្ហាញឱ្យច្បាស់ដូចរោមសត្វ ខ្ទីនទេ ។ ខាងលើខ្នងមានឆ្នូតខ្មៅពីរ ឬបី ។ ក្បាលតូច និង ក គ្មានរោមប្រែងដូចសត្វខ្ទីនទេ ។ វាជា សត្វមានក្រពេញក្លិន ។

**ជីវសាស្ត្រ** : ច្រើនរស់នៅឯកោតាមតំបន់ព្រៃល្បោះ និង ជាសត្វរាត្រីចរ រកចំណីនៅលើដី ។ ជួនកាលវារស់នៅជាក្រុមក្បែរភូមិ ។ ចំណីអាហាររបស់វាមានដូចជា កណ្តុរ បក្សី ពស់ ផ្លែឈើ ឫសឈើ និង បន្លែ មាន់ ទា ជាដើម ។ វាកើតកូននៅតាមរូងខាងក្រោមផ្ទាំងថ្ម ឬតាមគល់ឈើ កើតកូនម្តងបានពី ៣-៥ក្បាល សត្វញីនិងឈ្មោលរស់នៅជាមួយគ្នាតែនៅរដូវបង្កាត់ពូជ បន្ទាប់មកសត្វ ឈ្មោលចាកចេញដោយទុកឱ្យសត្វមេចិញ្ចឹមកូន ។ អាយុកាលរបស់វាមានពី ៨-៩ឆ្នាំ ។

**របាយ និង ស្ថានភាព** : មានជាមធ្យមស្ទើរគ្រប់ទីកន្លែង ។ និងត្រូវបានចាត់ចូលក្នុងឧបសម្ព័ន្ធទី ៣ របស់អនុសញ្ញា CITES ។







# ៣៧.សំពោចក្រអូប (សំពោចត្នោត)

## Common Palm Civet *Paradoxurus hermaphroditus*

**ទំហំ** : ក្បាល-ដងខ្លួន :៤៣២-៧១០ មម . កន្ទុយ :៤០៦-៦៦០ម ម . ទំងន់ :២-៥ គក្រ ។

**រូបភាព** : វាគឺជាសំពោចតូចមួយដែលមានពណ៌ប្រផេះ ឬត្នោត ត្រចៀក ជើង និង ផ្នែកចុងកន្ទុយ ពណ៌ខ្មៅ ថ្ពាស់ពណ៌ស ដោយមានឆ្នូតខ្មៅនៅចំកណ្តាល ផ្ទៃមុខខ្មៅ ប៉ុន្តែ មានឆ្នូតសនៅខាងក្រោមភ្នែក និង សងខាងច្រមុះ ។ នៅលើខ្នងមានឆ្នូតខ្មៅ ៣ និងនៅ សងខាងខ្លួនមានអុចៗខ្មៅ ។ រោមនៅ ក មានច្រើន បង្កើតបានជាគន្លាក់ ។ សំពោចក្រអូបនេះ មានក្លិនឈ្ងួលខ្លាំងនៅពេលដែលវាមានការភ័យខ្លាចអ្វីមួយ ជាធម្មតាវាមានក្លិន ក្រអូប ។

**ជីវសាស្ត្រ** : វាអាចរស់នៅតាមជំរកព្រៃគ្រប់ប្រភេទរួមទាំងវាលស្រែ ឬវាលដាំដំណាំ ក្បែរភូមិ ។ វាចូល ចិត្តរស់នៅកន្លែងងងឹតៗតាមជង្រុក ទបង្ហូរទឹក ឬដំបូលផ្ទះ សំរាប់ ពេលថ្ងៃ ។ ពេលយប់ឡើងចេញរក ចំណី ដូចជាកណ្តុរ ស្វាយ កាហ្វេ ម្នាស់ គ្រសក់ស្រូវ និង ចេក ។ សំពោចនេះបន្តពូជពេញមួយឆ្នាំ ដោយមានកូននៅខែ តុលា និង ខែធ្នូ ក្នុង មួយលើកៗអាចមានកូនពី ២-៤ក្បាល នៅតាមរូងថ្ម ឬប្រហោងឈើ ។ អាយុកាល របស់វាប្រហែល ១៤ឆ្នាំ ។

**រាយ និង ស្ថានភាព** : មានជាមធ្យមស្មើរគ្រប់ទីកន្លែង ។ ជាប្រភេទសត្វត្រូវ ការពារដែលបានចែង ក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង មានចុះក្នុងបញ្ជី.ឧបសម្ព័ន្ធទី ៣ របស់អនុសញ្ញា CITES ។





# ៣៨.សំពោចពណ៌លាត

**Masked Palm Civet**
***Paguma larvata***

**ទំហំ** : ក្បាល-ដងខ្លួន : ៥០៨-៧៦២ មម . កន្ទុយ : ៥០៨-៦៣៦ មម . ទំងន់ : ៣-៥ គក្រ ។

**ភិនភាគ** : ជាសំពោចមួយប្រភេទដែលមានពណ៌លាត គ្មានឆ្នូត ឬ ស្នាមអុចនៅលើដងខ្លួន ។ ពណ៌ខ្លួន ខុសប្លែកគ្នាខ្លាំងរវាងសត្វនីមួយៗ ពណ៌របស់វាមានពីត្នោតខ្ចីរហូតដល់ត្នោតចាស់ ថ្ងាសពណ៌ស បង្ហួស ដល់ច្រមុះ និង នៅសងខាងក្បាលពណ៌ស ។ កន្ទុយវែងសឹងស្មើទៅនឹងខ្លួន នៅចុងកន្ទុយភាគច្រើន គឺពណ៌ស ។ នៅផ្នែកក្រោមពោះមានពណ៌ភ្លឺជាងផ្នែកខាងលើ ។ វាមានក្លិនឈ្ងួលខ្លាំង ។

**ជីវសាស្ត្រ** : រស់នៅតាមគ្រប់ប្រភេទព្រៃ និងនៅក្បែរភូមិ ។ វាចូលចិត្តនៅលើដើមឈើ និង រកចំណី នៅពេលយប់ ចំណីភាគច្រើនគឺជាផ្លែឈើ ដូចជា ផ្លែល្វា ចេក ស្វាយ និង ស្លឹកឈើ ។ វាពូកែចាប់ កណ្ដុរ ហើយកម្រស៊ីមាន់ទាណាស់ ។ សត្វនេះកើតកូននៅតាមប្រហោងឈើ កូនក្នុងមួយលើកអាចមានដល់ ៤ក្បាល ហើយកូននេះនឹងមានរូបរាងប៉ុនសត្វពេញវ័យក្នុងរយៈពេល ៣ខែ ។ អាយុកាលសត្វចិញ្ចឹម មានដល់ ១៥ឆ្នាំ ។

**របាយ និង ស្ថានភាព** : មាននៅក្នុងឧបសម្ព័ន្ធទី ៣ របស់អនុសញ្ញា CITES ។





# ៣៩.ឈ្មុសប្រែង Binturong *Arctictis binturong*

**ទំហំ** : ក្បាល-ដងខ្លួន : ៦១០-៩៦៥ មម , កន្ទុយ : ៥០០-៨៤០ មម , ទំងន់ : ៩-២០ គក្រ ។

**ពិពណ៌** : ជាប្រភេទសំពោចដែលមានមាឌធំជាងគេ មានសម្បុរក្រម៉ៅសុទ្ធ រាងរៅ ដូចសត្វខ្លាឃ្មុំធំ រោម របស់វាវែងៗហើយក្រាស់ កន្ទុយវែងហើយអាចទប់ខ្លួនដោយផ្ដក់ នឹងមែកឈើ សត្វខ្លះមានរោមក្បាលពណ៌ ប្រផេះ ត្រចៀកមូល ហើយចុងពណ៌ស ។ សត្វញីមានដោះពីគូរ ។

**ជីវសាស្ត្រ** : ចូលចិត្តរស់នៅតំបន់ព្រៃដែលមានដើមឈើខ្ពស់ៗ ជាសត្វរស់នៅតាម ដើមឈើ រកចំណីនៅ ពេលយប់ ។ នៅពេលថ្ងៃវាដេកនៅតាមប្រហោងឈើ ដោយប្រើ កន្ទុយរបស់វាហ៊ុំព័ទ្ធក្បាល ។ ឈ្មុស ប្រែង ឡើងដើមឈើមួយៗ ហើយប្រើកន្ទុយដើម្បី ទប់លំនឹងខ្លួន និង សំរាប់ជួយទប់ទំងន់ខ្លួនផងដែរ ។ ចំណី របស់វាមានផ្លែឈើ និង សត្វរស់នៅតាមដើមឈើដូចជា បក្សី កណ្ដុរ សត្វល្អិត ពួកអំបូរបង្កួយ និង ត្រី ។ វា អាចហែលទឹកបាន ។ វាបន្តពូជពេញមួយឆ្នាំ ដោយសត្វមេមាន កូនពី ១-៣ក្បាលក្នុង រយៈពេលមួយឆ្នាំ ។ អាយុកាលរបស់វាប្រហែល ១៨ឆ្នាំ ។

**របាយ និង ស្ថានភាព** : មានដោយកម្រ នៅខេត្តព្រះវិហារ ពោធិសាត់ កោះកុង កំពង់ស្ពឺ ។ មាននៅក្នុងបញ្ជីឧបសម្ព័ន្ធទី ៣ របស់អនុសញ្ញា CITES ។





**ទំហំ** : ក្បាល-ដងខ្លួន : ៤៣២-៥៣២ មម កន្ទុយ : ៥១០-៦៦០ មម ទំងន់ : ២-៥ គក្រ ។

**រូបភាព** : ជាសំពោចដែលមានពណ៌ត្នោតខ្ចី និង នៅក្រោមពោះពណ៌លឿង ។ ដុំខ្មៅអុចៗលើខ្នង បង្កើតបានជាឆ្នូត ៣ លើដងខ្លួន និងកន្ទុយវែងជាងដងខ្លួន ហើយនៅពាក់កណ្តាលខាងចុងមានពណ៌ ក្រម៉ៅ ។ មានឆ្នូតសចាប់ពីថ្ងាសរហូតដល់ច្រមុះ ។ ជើងមុខមានលក្ខណៈចង្អៀតហើយវែងជាងសំពោច ក្រអូប ។ សត្វញីមានក្រពេញក្លិន និង មានដោះពីរគូ ។

**ជីវសាស្ត្រ** : ចូលចិត្តរស់នៅតាមព្រៃដែលមានដើមឈើខ្ពស់ៗស្ថិតនៅឆ្ងាយពីភូមិ ។ រកស៊ីនៅពេលយប់ និង ចូលចិត្តរស់នៅលើដើមឈើ ហើយវាពូកែឡើងដើមឈើណាស់ ។ ចំណីរបស់វាគឺ កំប្រុក សត្វស្លាប ផ្លែឈើផ្សេងៗ សត្វល្អិត និង កង្កែប ។ បន្តពូជពេញមួយឆ្នាំ ក្នុងមួយលើកបានកូន ២-៣ក្បាល ហើយរយៈពេលផើមគភ៌ ១៤៥ថ្ងៃ កូនវាផ្តាច់ដោះនៅអាយុ ២ខែ អាយុកាលរបស់វាពី ១០-១២ឆ្នាំ ។

**របាយ និង ស្ថានភាព** : មិនទាន់ដឹងទីកន្លែងច្បាស់លាស់ ហើយប្រហែលជាប្រភេទកម្រ ។



# ៩១.តំពីងឆ្នូត Owston's Civet *Hemigalus owstoni*

**ទំហំ** : ក្បាល-ដងខ្លួន :៥០០-៦៤០ មម . កន្ទុយ :៣៨០-៤៥០ មម . ទំងន់ :២-៣ គក្រ ។

**រូបភាព** : ជាសំពោចមានរាងស្តើង ក្បាលរបស់វាតូចវែង មានក្រឡាបង្ហង់ៗលើដងខ្លួន និង មានអុចៗក្រម៉ៅនៅតាមពោះ ចំហៀង និង លើជើងទាំង ៤ ។ សម្បុររបស់វាគឺប្រផេះលឿង ។

**ជីវសាស្ត្រ** : ច្រមុះរបស់វាមានគុណៈល្អប្រសើរសំរាប់ឈ្ងុសជីករកសត្វល្អិត ជីកជើ ពីង ពាង ដង្កូវ និង សត្វគ្មានឆ្អឹងកងផ្សេងៗទៀត និង អាចកាយដីដោយប្រើក្រញ៉ាំមុខ ។

**របាយ និង ស្ថានភាព** : ជាប្រភេទកំរ និង មាននៅតំបន់ភូមិភាគឥសាន្ត ។ ជាប្រភេទទទួលការគំរាមកំហែងលើពិភពលោក តាមការចាត់ថ្នាក់របស់អង្គការ IVCN (GT) ។





# ៤២.ស្កាតូច

## Small Asian Mongoose
## *Herpestes javanicus*

**ទំហំ** : ក្បាល-ដងខ្លួន : ៣៥០-៤១០ មម. កន្ទុយ : ២៥០-២៩០ មម. ទំងន់ : ០.៥-១ គក្រ ។

**រូបភាព** : មានមាឌតូច ខ្លួនទាំងមូលមានសម្បុរត្នោតចាស់ ឯក្បាលភាគច្រើនរាងក្រហម ។ រោមរបស់មានពណ៌ ស និង ខ្មៅ ឆ្លាស់គ្នាមួយៗ ។ ជើងរបស់វាមានសម្បុរដូចខ្លួន ជួនកាលក្រម៉ៅជាង ។ កន្ទុយរបស់វាមានប្រវែង ២ភាគ៣ នៃដងខ្លួន និងក្បាល ។ ពេលជួបនឹងសត្រូវ រោមរបស់វាបះត្រង់ ។ សត្វញីមានដោះ ៣គូ ។

**ជីវសាស្ត្រ** : ចូលចិត្តរស់នៅតាមតំបន់ព្រៃល្បោះ ស្រែភូមិ និងតែងតែអង្កេតឃើញរត់កាត់ផ្លូវនៅពេលថ្ងៃ ។ វារកចំណីទាំងយប់ទាំងថ្ងៃនៅលើដី ហើយវាក៏វារឡើងដើមឈើ ច្រមុះវាអាចស្រង់ក្លិនបានល្អ ហើយអាចតាមដានសត្វជាចំណីរហូតដល់រូង ។ ចំណីរបស់វាគឺកណ្ដុរ សត្វស្លាប កង្កែប ក្ដាម សត្វល្អិត ។ល។ វាក៏ចូលចិត្តស៊ីពងវែកផងដែរ ។ សត្វញីអាចកើតកូនបានពី ២-៤ក្បាល រយៈពេលគភ៌ ៦សប្ដាហ៍ ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វសំបូរមានគ្រប់ទីកន្លែង ។







## ៤៣.ស្កាវឈី Crab-eating Mongoose *Herpestes urva*

**ទំហំ** : ក្បាល-ដងខ្លួន : ៤៤០-៤៨០ មម. កន្ទុយ : ២៦០-៣១០ មម. ទំងន់ : ៣-៤ គក្រ ។

**ភិនភាគ** : ជាប្រភេទសត្វស្កាវធំមួយមានកន្ទុយខ្លី និង មានឆ្នូតសចាប់ពីមាត់រហូតដល់ស្មា ។ ចង្កា ស ក ពណ៌ខ្មៅ ទ្រូងពណ៌ត្នោតចាស់ ពោះត្នោតខ្ចី ។ សម្បុរខ្លួនទាំងមូលគឺប្រផេះ ឬត្នោតចាស់ ជើងទាំងបួន មានពណ៌ ក្រម៉ៅ ។

**ជីវសាស្ត្រ** : ចូលចិត្តរស់នៅដោយឯកោ ហើយរកស៊ីពេលយប់ វាអាចរស់នៅតាមតំបន់ផ្សេងៗ ។ ចំណីរបស់វាភាគច្រើន ក្តាម ត្រី កង្កែប និយាយរួមគឺសត្វដែលរស់នៅអាស្រ័យនឹងទឹក ។ វាជាសត្វអាចហែលទឹកយ៉ាងចំណាន ។ សត្វចិញ្ចឹមអាចរស់នៅបានដល់ទៅ ១០ឆ្នាំ ។

**របាយ និង ស្ថានភាព** : មិនទាន់មានទិន្នន័យច្បាស់លាស់សំរាប់វាយតំលៃ ។ មានចែងក្នុង ឧបសម្ព័ន្ធទី ៣ របស់ CITES ។





# ៤៤.ឆ្មាព្រៃ Jungle Cat *Felis chaus*

**ទំហំ** : ក្បាល-ដងខ្លួន : ៥០០-៦៥០ មម . ទំងន់ : ៤-៦ គក្រ ។

**ពិពណ៌នា** : ឆ្មាព្រៃមានមាឌធំជាងឆ្មាស្រុក ។ ត្រចៀករបស់វាខ្ពស់ហើយត្រង់ឡើងលើ ។ កន្ទុយមាន បង្កង់ក្រម៉ៅ ហើយខាងចុងមានពណ៌ខ្មៅ ។ ដងខ្លួនពណ៌ប្រផេះ ឬត្នោតលឿង ផ្ទៃកពោះរាងព្រលែត និង មានរោមវែងជាង ។ កន្ទុយរបស់វាខ្លីជាងប្រវែងដងខ្លួន និង ក្បាល ។

**ជីវសាស្ត្រ** : ឆ្មាព្រៃចូលចិត្តរស់នៅតាមវាលស្មៅក្រាស់ខ្ពស់ៗ ព្រៃជ្រុះស្លឹក ព្រៃគម្ពោត គេពុំដែលបាន ជួបប្រទះវានៅព្រៃស្រោងក្រាស់ទេ ។ វាចូលចិត្តចាប់ចំណីដូចជាពពួកសត្វកកេរ ត្រកួត អន្សង កង្កែប បក្សី ជាដើម ។ ឆ្មាព្រៃមានគភ៌រយៈពេលពី ៦៥-៦៧ថ្ងៃ ហើយអាចបង្កើតកូនបានពី ២-៥ក្បាល ។

**រចាយ និង ស្ថានភាព** : ឆ្មាព្រៃជាប្រភេទមួយមានដោយកម្រ ។ គេពុំមានការអះអាងថាមានរស់នៅ តំបន់ណាមួយទេ ។ វាជាប្រភេទសត្វត្រូវបានហាមឃាត់ការបរបាញ់ និង ធ្វើ អាជីវកម្ម ដោយប្រកាស របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ជាប្រភេទដែលស្ថិតនៅ ក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។



# ៤៥.ឆ្មាដាវ Leopard Cat *Prionailurus bengalensis*

**ទំហំ** : ក្បាល-ដងខ្លួន : ៤៤៥-៥៥០ មម . ទំងន់ : ៣-៥ គក្រ ។

**រូបភាព** : ឆ្មាដាវមានសម្បុរពណ៌ដី មានរោមខ្លីស្តើង ។ មានឆ្នូត ៤-៥ សម្បុរខ្មៅចាស់ ចាប់ផ្តើមចេញពីលើក្បាល ហើយរីកធំនៅចន្លោះស្មា ដាច់ជាដុំអុចៗទៅពាក់កណ្តាលខ្នង ។ ផ្ទៃកចំហៀងនិងជើងទាំង ៤ មានដុំអុចៗក្រម៉ៅចាស់ក្នុងទំហំនិងរាងខុសៗគ្នា ។ កន្ទុយមានអុចផ្នែកខាងលើ និង ពណ៌ប្រផេះ ផ្នែកក្រោមមានប្រវែងវែងជាងដងខ្លួន និង ក្បាល ។ ផ្ទៃកខាងក្រោយ និង ក្រោមភ្នែកមានឆ្នូតក្រម៉ៅ ខ័ណ្ឌចែកដោយបន្ទះពណ៌ ស ។

**ជីវសាស្ត្រ** : ឆ្មាដាវរស់នៅក្នុងព្រៃស្ទើរគ្រប់ប្រភេទព្រៃ ។ វាមិនកាចសាហាវចំពោះមនុស្សទេ ហើយជារឿយៗគេអាចជួបប្រទះវានៅក្បែរៗភូមិ ។ អាហាររបស់វាមានបក្សី សត្វកកេរ ត្រកួត អន្សង ក្តាន់ព្រៀងជាដើម ។ វាឡើងដើមឈើ រួចហើយអាចចាប់ចំណីរបស់វាដោយលោតចុះពីលើដើមឈើមកវិញ ។ វាជាសត្វពូកែហែលទឹកណាស់ ។ វាអាចបន្តពូជបានពេញមួយឆ្នាំ រយៈពេលមានគភ៌ពី៦៥-៧២ថ្ងៃ អាចបង្កើតកូនបានពី ១-៤ក្បាល ។ កូនរបស់វាអាចបើកភ្នែកបានក្នុងរយៈពេលប្រហែល ១០ថ្ងៃ ក្រោយពេលកើត ។

វាអាចបន្តពូជបាននៅអាយុប្រមាណ ១៨ខែ និង អាចរស់បានពី ១២-១៣ ឆ្នាំ បើសិនជាយើងចិញ្ចឹមវា ។

**រចាយ និង ស្ថានភាព** : ឆ្មាដាវជាប្រភេទមានជាមធ្យមនៅភាគឥសាន និង និរតី។ ប្រភេទសត្វនេះត្រូវបានហាមឃាត់ការបរបាញ់ និង ធ្វើអាជីវកម្ម ដោយប្រកាសរបស់ក្រសួង កសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ជាប្រភេទដែលស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។





# ៩៦.ខ្លាត្រី Fishing Cat *Prionailurus viverrinus*

**ទំហំ** : ក្បាល-ដងខ្លួន : ៧២៥-៧៨០ មម . ទំងន់ : ៧-១១ គក្រ ។

**ភិនភាគ** : ខ្លាត្រីមានសម្បុរប្រផេះ ឬត្នោតប្រេង រោមទន់មានស្នាមអុចៗ ។ មានជើងខ្លី ត្រចៀកទាប មានស្នាមអុចតូចនៅផ្នែកត្រចៀក ។ ក្បាលរាងវែងស្ដួច កន្ទុយខ្លីជាងក្បាល និង ដងខ្លួន រោមទន់មាន ស្នាមអុចៗ រាងឆ្នូតខ្លីនៅលើខ្នង ។ កន្ទុយមានសម្បុរប្រផេះ មានអុចខ្មៅៗផ្នែកខាងគល់ និង មានបង្កង់ ខ្មៅផ្នែកខាងចុង ។ ថ្ពាល់ និង ក្ដោងច្រមុះមានពណ៌សប្រផេះ ដែលមានឆ្នូតពីរចាប់ពីភ្នែកមកក្រោម ត្រចៀក ។

**ជីវសាស្ត្រ** : ខ្លាត្រីចូលចិត្តរស់នៅក្នុងព្រៃគម្ពោត ព្រៃល្បោះក្បែរទឹក ដែលនៅទីនោះវាអាចចាប់ត្រី ក្ដាម បក្សី ត្រុំ និង សត្វដទៃទៀតបាន ។ វាចាប់ត្រីដោយក្រាបលើផ្ទាំងថ្មដែលលយចូលក្នុងទឹក ហើយយក ក្រញ៉ាំជើងរបស់វាចូកបាចត្រីឡើងមកគោក គឺវាមិនចុះទៅក្នុងទឹកចាប់ត្រីដូចសត្វភេទេ ។ វាអាចបង្កើត កូនបានពី ២-៣ក្បាល បន្ទាប់ពីមានគភ៌អស់ពេលពី ៩០-៩៥ ថ្ងៃ ហើយកូនវាអាចបន្តពូជបាននៅអាយុចាប់ពី ៨ខែកន្លះ ។

**របាយ និង ស្ថានភាព** : ខ្លាត្រីជាប្រភេទមួយមានជាមធ្យម ។ វារស់នៅស្ទើរគ្រប់ទីកន្លែង ពិសេស តំបន់ភូមិភាគឥសាន្ត ខាងជើង និង និរតី នៃ ប្រទេសកម្ពុជា ។ វាជាប្រភេទមួយត្រូវហាមឃាត់ ការបរបាញ់ និង ធ្វើអាជីវកម្ម ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ត្រូវចុះក្នុងបញ្ជីក្រហម IVCN (NT) ជាប្រភេទសត្វជិតទទួលរងការ គំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុសញ្ញា CITES ។





# ៤៧.ខ្លាលឿងមាស



**ទំហំ** : ក្បាល-ដងខ្លួន : ៧៦០-៨១៥ មម , ទំងន់ : ១២-១៥ គក្រ ។

**ពិពណ៌ន** : ខ្លាលឿងមាសជាប្រភេទសត្វធំជាងគេក្នុងចំណោមត្រកូលខ្លាតូចៗ ។ វាមានពណ៌ត្នោតលឿង ទៅត្នោតប្រផេះ វាពុំមានស្នាមអុច និង ឆ្នូតនៅលើដងខ្លួនទេ ។ ផ្នែកខាងក្រោមមានពណ៌ព្រលែត ជាងផ្នែកខាងលើនៃដងខ្លួន ។

**ជីវសាស្ត្រ** : ខ្លាលឿងមាសរស់នៅតាមព្រៃជ្រុះស្លឹក និង តាមព្រៃស្រោងផងដែរ ជាធម្មតាវាជាសត្វ ដើរលើដី ប៉ុន្តែវាអាចឡើងដើមឈើបានយ៉ាងរហ័សនៅពេលវាមានអាសន្ន អាហាររបស់វាមាន ទន្សាយ ក្តាន់ពៀង បក្សី ជាពិសេសពពួកមាន់ទោ ត្រកូតអន្សង និងសត្វតូចៗដទៃទៀត ។ ជាធម្មតាវាចាប់ចំណីជាគូ ។ វាបង្កើតកូនក្នុងរន្ធឈើរងដី ឬក្នុងចន្លោះថ្មាំងថ្មជាដើម ។ វាអាចបង្កើតកូនបានពី ១-២ក្បាល បន្ទាប់ពីគភ៌បានប្រហែលជាង ៩០ថ្ងៃ ។ សត្វឈ្មោលមានតួនាទីសំខាន់ក្នុងការថែរក្សាកូន ។ បើសិនជាកូនបាត់បង់ទៅ មេអាចបន្តពូជទៀតបានក្នុងរយៈពេល ៤ខែ បន្ទាប់ ។

**របាយ និង ស្ថានភាព** : ខ្លាលឿងមាសជាប្រភេទសត្វកម្រ និង ទទួលរងការគំរាមកំហែងយ៉ាងខ្លាំង ។ វាមាននៅតំបន់ភាគខាងជើង ភូមិភាគឦសាន្ត និង ឥសាន្ត នៃប្រទេសកម្ពុជា ។

ប្រភេទនេះត្រូវបានហាមឃាត់ធ្វើការបរបាញ់ និង អាជីវកម្ម ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ចុះក្នុងបញ្ជី IVCN(NT) ជាប្រភេទសត្វជិតទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី១ នៃអនុសញ្ញា CITES ។





# ៥៨.ខ្លាគ្រីថ្មកែវ Marbled Cat *Pardofelis marmorat*

**ទំហំ** : ក្បាល-ដងខ្លួន : ៤៥០-៥៣០ មម. ទំងន់ : ២-៥ គក្រ ។

**ភិនភាគ** : ខ្លាគ្រីថ្មកែវមានមាឌជាមធ្យម ដងខ្លួនវែង ត្រចៀកមូល និងកន្ទុយវែងសំពោង សម្បុរដីផ្នែក ខាងលើ និង ខាងក្រោមត្នោតខ្ចី ជាពិសេសនៅលើដងខ្លួនមានស្នាមអុចៗ ធំ-តូច រាយប៉ាយ ។ នៅលើក្បាល ក និង ខ្នងមានឆ្នូតៗពណ៌ខ្មៅ ។ ស្នាមអុចធំជាយពណ៌ខ្មៅនៅចំហៀងខ្លួន ។ នៅលើជើង និង កន្ទុយមានស្នាមអុចៗពណ៌ខ្មៅ និង ស្នាមអុចធំៗនៅត្រគៀក ប៉ុន្តែមានទំហំតូចជាងខ្លាពពក ។

**ជីវសាស្ត្រ** : វារស់នៅតំបន់ព្រៃឈើខ្ពស់ៗ និង ព្រៃក្រោយពីធ្វើអាជីវកម្មជាធម្មតា ប្រភេទសត្វនេះ ចេញរកស៊ីនៅពេលយប់ និង នៅលើដើមឈើ ។ អាហាររបស់វាគឺ ត្រកួត អន្សង កំប្រុក បក្សី រញ៉ី ស្វា កណ្តុរ រញ៉ី ទន្សាយ ។

**របាយ និង ស្ថានភាព** : វាជាប្រភេទសត្វកំរ និង ត្រូវបានហាមឃាត់ការបរបាញ់ និង អាជីវកម្ម ដោយប្រកាសរបស់ក្រសួង កសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ហើយជាប្រភេទមួយដែលពុំទាន់មាន ទិន្នន័យគ្រប់គ្រាន់ដើម្បីចំណាត់ថ្នាក់ចុះក្នុងបញ្ជីក្រហម IVCN (DD) ដែលជាប្រភេទទទួលការគំរាមកំហែង លើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។









# ៤៩.ខ្លាពពក Clouded Leopard *Pardofelis nebulosa*

**ទំហំ** : ក្បាល-ដងខ្លួន : ៦៥០-៩៥០ មម. ទំងន់ : ១៦-២៣ គក្រ ។

**ពិពណ៌នា** : ខ្លាពពកមានមាឌធំជាងខ្លាត្រីថ្មកែវ មានសម្បុរពណ៌ក្រម៉ៅប្រផេះ នៅលើដងខ្លួនមានផ្ទាំងៗ ដូចជាពពកធំៗ នៅផ្នែកខាងក្រោយនៃផ្ទាំងនេះមានពណ៌ខ្មៅ ខ័ណ្ឌជាកំណាត់ជុំផ្ទាំងនីមួយៗ ។ ជុំផ្ទាំង នេះរីកធំនៅផ្នែកខាងក្រោយស្មា ដែលចាប់ផ្តើមពីលើខ្នងរហូតស្ទើរដល់ក្រោមពោះ ។ ច្រមុះមានពណ៌ ស នៅលើថ្ពាសមានស្នាមអុចតូចៗ ។ វាមានកន្ទុយវែង ស្នាមអុចៗនៅផ្នែកគល់ និង បន្ទះៗនៅផ្នែកចុង ។ វាមានជើងខ្លីប្រអប់ជើងធំ ងាយស្រួលក្នុងការប្រតោងមែកឈើ ។ ខ្លាពពកងាយក្នុងការ ចំណាំណាស់ គឺយើងគ្រាន់តែក្រឡេកឃើញនៅលើដងខ្លួនរបស់វា មានផ្ទាំងរង្វង់សណ្ឋានដូចដុំពពករាយពាសពេញដងខ្លួន។

**ជីវសាស្ត្រ** : វាចូលចិត្តរស់នៅតំបន់ព្រៃស្រោង និង ពាក់កណ្តាលស្រោង និង ព្រៃចំរុះ ។ ខ្លាពពក ជាសត្វរាត្រីចរ ច្រើនរស់នៅលើដើមឈើ និង ជាគូរ ។ ជាធម្មតាវាចាប់ចំណីដោយលោតចុះពីលើដើមឈើសង្គ្រប់លើសត្វនៅដី ដូចជាសត្វខ្លារខិនដែរ ។ អាហាររបស់វាមានបក្សី ពស់ ជ្រូកព្រៃ ឈ្លូស ប្រើស ស្វា ជាដើម ។ ខ្លាពពកមានក្រញ៉ាំជើង-មុខមុតសំរាប់ចាប់ចំណី រួចទើបខាំជាក្រោយ ។ ខ្លាពពកបង្កើតកូនម្តងបានពី ២-៤ក្បាល បន្ទាប់ពីមានគភ៌រយៈពេល ៨០-៩៥ថ្ងៃ ។

**របាយ និង ស្ថានភាព** : ខ្លាពពកគឺជាសត្វកំរ មាននៅភូមិភាគឥសាន្ត និរតី និង ភាគខាងជើង ។ វាត្រូវបានហាមឃាត់ការបរបាញ់ និង ធ្វើអាជីវកម្ម ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ចុះក្នុងបញ្ជីក្រហម IUCN(GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។





# ៥០.ខ្លារខិន Leopard *Panthera pardus*

**ទំហំ** : ក្បាល-ដងខ្លួន : ១.០៨០-១.៣០០ មម. ទំងន់ : ៤៥-៦៥ គក្រ ។

**ភិនភាគ** : ខ្លារខិនមានលក្ខណៈងាយចំណាំណាស់ គឺវាមានពណ៌លឿងឬក្រហមត្នោត និង មានអុចៗ ពណ៌ខ្មៅជាកញ្ចុំ នៅពាសពេញខ្លួន ។

**ជីវសាស្ត្រ** : ខ្លារខិនអាចរស់នៅក្នុងតំបន់ព្រៃស្ទើរគ្រប់ប្រភេទ ចាប់ពីព្រៃស្រោងរហូតដល់ព្រៃគម្ពោត ដែលមានថ្មាំងថ្ម ។ វាជាសត្វរហ័សរហួន និង ចូលចិត្តឡើងដើមឈើដែលជាជំនាញពិសេសរបស់វា ។ វាពុំសូវចាញ់កំដៅថ្ងៃដូចខ្លាធំទេ ហើយអាចរស់ឆ្ងាយពីទឹកយ៉ាងប្រសើរ ។ បើទោះជាវាអាចហែលទឹកបាន ក៏វានៅតែព្យាយាមគេចចេញពីតំបន់ទឹកដែរ ។ ខ្លារខិនស៊ីសាច់គ្រប់ប្រភេទដែលវាអាចចាប់បានដូចជា ជ្រូកព្រៃ ស្វា សត្វល្អិត ជាដើម ។ ជារឿយៗ វាចាប់ចំណីដោយលោតសង្គ្រប់ពីលើដើមឈើ រួចទាញសត្វ នោះឡើងលើដើម្បីស៊ី ។

វាចូលចិត្តរកចំណីតែឯកឯង និង ជាសត្វរាត្រីចរ ។ វាដើរជាគូរតែក្នុងរដូវបន្តពូជ ។ ខ្លារខិន អាចបង្កើតកូនម្តងបានពី ១-៤ក្បាល បន្ទាប់ពីពរពោះអស់រយៈពេល ៩០-៩៥ថ្ងៃ កូនរស់នៅជាមួយមេ រហូតដល់អាយុពី ១-២ឆ្នាំ ។

**របាយ និង ស្ថានភាព** : វាមានតិចតួចតាមតំបន់នានាដូចជា ភូមិភាគឥសាន្ត និរតី និងភាគខាងជើង ។ ហើយត្រូវបានហាមឃាត់ការបរបាញ់ និង អាជីវកម្ម ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និងជាប្រភេទសត្វស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញា CITES ។







# ៥១.ខ្លាធំ Tiger *Panthera tigris*

**ទំហំ** : ក្បាល-ដងខ្លួន : ១.៧០០-២.២៨០ មម. ទំងន់ : ១៨០-២៤៥ គក្រ ។

**ពិពណ៌នា** : ខ្លាធំជាប្រភេទខ្លាដែលមានមាឌធំជាងគេបំផុត ក្នុងចំណោមត្រកូលខ្លា និង ងាយស្រួលក្នុង ការកត់ ចំណាំ។ វាមានសម្បុរក្រហម លឿង ឬត្នោតខ្ចី មានឆ្នូតបញ្ឈរ ពណ៌ក្រម៉ៅកាត់ទទឹងដងខ្លួន ។ នៅផ្នែកខាងក្រោមចង្កា និង បំពង់ក មានពណ៌ស ។ កន្ទុយមានសម្បុរពណ៌ខ្មៅជាកង់ៗ និង ខ្មៅផ្នែកខាងចុង ។

**ជីវសាស្ត្រ** : ខ្លាធំអាចរស់នៅក្នុងជំរកគ្រប់ប្រភេទ ដែលមានទឹក ចំណី និង ម្លប់គ្រប់គ្រាន់ព្រោះវាជាសត្វចាញ់កំដៅថ្ងៃ ។ នៅពេលថ្ងៃក្តៅខ្លាំង ខ្លាធំចំណាយពេលច្រើនម៉ោង ដើម្បីដេកត្រាំទឹក ។ វាមានភាពស្ទាត់ជំនាញក្នុងការហែលទឹក ហើយវាពុំឡើងដើមឈើទេ បើសិនពុំចាំបាច់ ។ ខ្លាធំអាចចាប់ចំណីបាន ចាប់ពីសត្វតូចរហូតដល់សត្វធំ ( ទន្សោង ខ្ទីង) ។ ខ្លាធំអាចបង្កាត់ពូជបានគ្រប់រដូវ ។ វាអាចបង្កើត កូនបានពី ១-៧ក្បាល បន្ទាប់ពីពរពោះរយៈពេលប្រហែល ១០០ថ្ងៃ ។ វាអាចមានអាយុរហូតដល់ ២៥ឆ្នាំ ក្នុងធម្មជាតិ ។

**ឋានៈ និង ស្ថានភាព** : ខ្លាធំជាប្រភេទសត្វដែលទទួលរងគ្រោះថ្នាក់បំផុត ដោយការបរបាញ់ដើម្បី ពាណិជ្ជកម្មស្បែក ឆ្អឹង នៅតាមតំបន់មួយចំនួន ក្នុងប្រទេសកម្ពុជា ដូចជា ភូមិភាគឥសាន ភូមិភាគ ខាងជើង និង ភូមិភាគនិរតី ។ វាជាប្រភេទហាមឃាត់ការបរបាញ់ និង ធ្វើអាជីវកម្ម ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ចុះក្នុងតារាងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។





# ៥២.ផ្សោតពណ៌ផ្កាឈូក

Indo-Pacific Hump-backed Dolphin

*Sousa chinensis*

**ទំហំ** : ប្រវែងសរុប ៣២០០ ម.ម ចំពោះឈ្មោល និង ២៥០០ ម.ម ចំពោះញីទំងន់រហូតដល់ ២៨៤ គ.ក្រ

**ពិពណ៌នា** : ផ្សោតប្រភេទនេះគឺវាមានការប្រែប្រួលខ្ពស់តាមប្រភេទនិមួយៗ និងត្រូវបានសំគាល់លក្ខណៈដោយវាមានដងខ្លួនរឹងមាំ និងមានប្រវែងវែង ។ ព្រុយខ្នងមានសណ្ឋានរាងខ្ពស់ផ្នែកលើខ្នង និងកណ្តាលខ្នង ។ មានមាត់វែងស្រាវ មាត់នេះប្រែប្រួលទៅតាមអាយុកាលរបស់វា ។ វាមានរង្វះមាត់ត្រង់ល្អ ហើយដងខ្លួនអាចមានស្នាម ឬ ចំណុច ។ ព្រុយចំហៀងធំហើយមានចុងមូល ។ ក្បាលវាមានរាងមូលទ្រវែង ។ សំបុរ ផ្នែកពោះមានពណ៌ស្រាលជាងផ្នែកចំហៀង និងផ្នែកខ្នង ។ ទម្រររបស់ព្រុយខ្នងមានប្រវែងជិតស្មើនឹង ១/៣នៃដងខ្លួន ។ ផ្នែកគល់កន្ទុយ មានពណ៌ប្រផេះ ស្លេក ឬមានពណ៌ផ្កាឈូកខ្ចីនៅផ្នែកខាងលើ ។ កូនរបស់វាដែលទើបនឹងកើតមានពណ៌ ស្រាល បន្ទាប់មកនៅពេលពេញវ័យ វាមានពណ៌ផ្កាឈូកស្រាល មានអុចៗ ឬ ស្នាមអុច ធំៗ ។

**ជីវសាស្ត្រ** : វារស់នៅជាក្រុមដែលមានតិចជាង ១០ក្បាល តែពេលខ្លះមានរហូតដល់ទៅ ៣០ក្បាល ។ ក្រុមទាំងនេះចូលចិត្តរស់នៅ និងលេងនៅតាមឆ្នេរខ្សាច់ ហើយរកចំណីនៅតាមចន្លោះថ្មាំងថ្ម ។

**រចាយ និង ស្ថានភាព** : ជាប្រភេទសត្វមានតិចតួចស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ និងត្រូវបានចុះក្នុងបញ្ជីក្រហម IVCN(DD) តែពុំទាន់មានពត៌មាន គ្រប់គ្រាន់ដើម្បីចំណាត់ថ្នាក់នៅឡើយ និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។



# ៥៣.ផ្សោតបង្វិល



**ទំហំ** : ប្រវែងសរុប ២០០០ម.ម ចំពោះសត្វញី និង ២៤០០.មម ចំពោះសត្វឈ្មោល ទំងន់ច្រើនជាង ៧៧ គ.ក្រ កូនដែលទើបនឹងកើតមានប្រវែងប្រហែល ៧៥០-៨០០ ម.ម ។

**ភិនភាគ** : ដងខ្លួនមានរាងស្រាវ មាត់តូច វែងស្តើង ហើយមានពណ៌ក្រម៉ៅ ។ ក្បាលមានរាងមូលទ្រវែងស្រាវ ។ វាមានផ្នត់ស្ថិតនៅត្រង់ថ្ពាស និងមាត់ផ្នត់នេះ មានពណ៌ខ្មៅ ។ ថ្ពាសរាងជាចំណោត ហើយដងខ្លួនភាគច្រើន មានពណ៌ប្រផេះចាស់ ។ ព្រុយខ្នងមានចុងទេរទ្រេតទៅក្រោយ និងមានការប្រែប្រួលទៅតាមអាយុកាលរបស់វា ។ គល់កន្ទុយរបស់វា មានលក្ខណៈជាសាច់ដុំនៅផ្នែកខាងលើ និង ខាងក្រោម ។ វាមានឆ្នូតពណ៌ប្រផេះចាស់ លាតពីភ្នែកដល់ព្រុយចំហៀង ដែលព្រុយនេះរាងវែងហើយស្រួច និង កន្ទុយរបស់វាមានពណ៌ ប្រផេះក្រម៉ៅ ។ ជាធម្មតា វាលោតចេញពីក្នុងទឹក ហើយបង្វិលខ្លួនអាចរហូតដល់ ប្រាំពីរជុំ មុនពេលធ្លាក់ចុះទៅក្នុងទឹកវិញ ។

**ជីវសាស្ត្រ** : ហ្វូងវាមានចាប់ពី ៥០ក្បាលឡើងទៅ ។ វារកស៊ីនៅពេលយប់ ចំណីអាហាររបស់វាមានត្រី និងមឹក ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វមានតិចតួច ស្ថិតនៅតាមបណ្តោយ ឆ្នេរសមុទ្រ និង ជាប្រភេទដែលត្រូវបានចុះក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។





# ៥៤.ផ្សោតខ្មៅ_លឿង

**Common Dolphin**
***Delphinus delphis***

**ទំហំ** :ប្រវែងសរុប ២៣០០-២៧០០ ម.ម ទំងន់ ៦០-៧០ គ.ក្រ

**ភិនភាគ** : សំបុររបស់វាមានការផ្លាស់ប្តូរច្រើនយ៉ាង ។

**ជីវសាស្ត្រ** : វារស់នៅជាក្រុមអាចដល់ទៅ ១០០ក្បាល ។ វាអាចហែលក្នុងល្បឿនបាន ពី ៣៥-៤០គ.ម/ម៉ ។ ចំណីអាហាររបស់វាមាន ត្រី ។ វាមានគភ៌រយៈពេល ៩ខែ ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វសំបូរជាមធ្យម រស់នៅតាមឆ្នេរសមុទ្រ និង ជាប្រភេទដែលត្រូវបានចុះក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។







# ៥៥.ផ្សោតច្រមុះដប

**Bottle-nosed Dolphin**
***Tursiops truncatus***

**ទំហំ** : នៅពេលពេញវ័យមានប្រវែងពី ១៩០០-៣៨០០ម.ម ទំងន់ធ្ងន់បំផុត ៦៥០ គ.ក្រ ។

**ពិពណ៌នា** : ផ្នែកក្បាលមានផ្នត់ដែលស្ថិតនៅរវាងថ្ងាសនឹងមាត់ ។ ព្រុយខ្នងខ្ពស់ និងទ្រនុងផ្នែកខាងមុខមានពណ៌ស្លេក ជាងផ្នែកចំហៀង ។ ផ្នែកចុងស្រួចនៃព្រុយខ្នងមានរាងដូចទំពក់ ។ មានឆ្នូតពណ៌ក្រម៉ៅលាតចាប់ពីភ្នែក រហូតដល់ព្រុយចំហៀង ។ គល់នៃព្រុយចំហៀងធំ មានពណ៌ក្រម៉ៅ ស្រួចចុង ។ នៅចំហៀងខ្លួន ពណ៌ប្រផេះ ស្លេក និងប្រផេះត្នោត និងមានគល់កន្ទុយធំក្រាស់ ។ ផ្នែកពោះ ពណ៌សប្រផេះស្រាល ឬផ្កាឈូកខ្ចី (វាមានចំណុចៗនៅពេលវាមានវ័យចាស់) ។ មានស្នាមធំៗ នៅពេលវាពេញវ័យចំពោះសត្វខ្លះ ។ នៅលើខ្នងវា មានពណ៌ដែលអាចផ្លាស់ប្តូរពីប្រផេះស្រាល រហូតដល់ពណ៌ខ្មៅ និងពណ៌ស (ជូនកាលមានពណ៌លាយនឹង ពណ៌ផ្កាឈូក ) នៅត្រង់ពោះ។

**ជីវសាស្ត្រ** : ជាទូទៅវារស់នៅជាក្រុមដែលមានចំនួនតិចជាង ២០ក្បាល ប៉ុន្តែហ្វូងធំៗអាចមានដល់ទៅរាប់រយក្បាល ដែលរស់នៅជិតឆ្នេរ។ នៅតំបន់ខ្លះវាមានជំរកកំណត់ ខ្លះទៀតវាធ្វើការបំលាស់ទី ដោយហែលជាជួរៗ ។ វាអាចសំរបសំរួលខ្លួនបានខ្ពស់ និងងាយស្រួល ដល់ការបង្ហាត់បង្រៀន ។ ចំណីអាហាររបស់វាគឺត្រី មឹក បង្គា ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វមានតិចតួច តាមឆ្នេរសមុទ្រ និង ជាប្រភេទដែលបានចុះក្នុងតារាងឧបសម្ព័ន្ធ ទី២ របស់អនុសញ្ញា CITES ។





# ៥៦.ផ្សោតទន្លេ

**Irrawaddy Dolphin**
*Orcaella brevirostris*

**ទំហំ** : ប្រវែងសរុប ១៨០០-២៧៥០ ម.ម

**រូបភាព** : វាមានក្បាលមូលរលោង ភ្នែកតូច ព្រុយខ្នងខ្លី សំបុរលឿងក្រម៉ៅស្មើ ផងខ្លួនរលោងគ្មានស្រកា ចំពុះខ្លី ។ វារស់នៅជាហ្វូងដែលមានចំនួនពី៥-១០ក្បាល ។

**ជីវសាស្ត្រ** : វារស់នៅក្នុងទឹក ចំណីអាហាររបស់វាមានត្រី និងកំពឹស ។ វាដកដង្ហើម ក្នុងរយៈពេលពី៧០-១៥០វិនាទី ម្តង ។ សត្វញីមានគភ៌រយៈពេល៩ខែ ។ កូនវាដែលកើតមកមានប្រវែងប្រហែល៤០ភាគរយនៃប្រវែងរបស់មេវា ។

**រាយ និង ស្ថានភាព** : ជាប្រភេទមានតិចតួច ស្ថិតនៅអន្លង់ជ្រៅៗ នៃដងទន្លេសេកុង ទន្លេមេគង្គលើ ឆ្នេរសមុទ្រ និង ត្រូវបានចុះក្នុងបញ្ជីក្រហម **IVCN (DD)** ប៉ុន្តែពុំទាន់មានពត៌មានគ្រប់គ្រាន់ ដើម្បីចំណាត់ថ្នាក់នៅឡើយ និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី២ របស់អនុសញ្ញា **CITES** ។







# ៥៧.ផ្សោតគ្មានព្រុយខ្នង

## Finless Porpoise
## *Neophocaena phocaenoides*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ១២០០-១៩០០មម ទំងន់ ៣០-៤៥គ.ក្រ

**ភិនភាគ** : ផ្សោតប្រភេទនេះពុំមានមាត់វែងទេ ។ វាមានថ្ងះមាត់តូច ហើយរាងកោងឡើងលើបន្តិច និង មានថ្ងាសមូល ។ ដងខ្លួនទាំងមូលមានសម្បុរប្រផេះខៀវព្រលែតជួនកាលមានលាយពណ៌ទឹកក្រូចនៅលើខ្នង និង ចំហៀងខ្លួន ។ ចាប់ពីចង្ការហូតដល់ពោះមានពណ៌ព្រលែតជាង ខ្នង និង ខ្លួន ។ សម្បុរដងខ្លួនអាចប្រែពណ៌ ទៅជាក្រម៉ៅបន្តិចទៅតាមអាយុរបស់វា ។ព្រុយមុខវែងស្រួចនិងមានគល់តូច ។ សត្វប្រភេទនេះ ពុំមានព្រុយខ្នងទេ ។

**ជីវសាស្ត្រ** : ជាទូទៅវារស់នៅតែឯង ឬ ហ្វូងតូចៗ (២ក្បាល ឬអាចដល់១០ក្បាល) ។ វាដកដង្ហើម ពី៣-៤ដងបន្តបន្ទាប់គ្នាយ៉ាងរហ័ស ក្រោយពីមុជក្រោមផ្ទៃទឹកបាន មួយនាទី វាឡើងខាងលើផ្ទៃទឹកម្តងទៀត ក៏ប៉ុន្តែឆ្ងាយពីកន្លែងមុន ។ កូនស្ថិតនៅជាប់នឹងខ្នងរបស់វា ដែលជារឿយៗវាអាចខ្ទាតហួសពីផ្ទៃទឹក នៅពេលដែលមេវាឡើងមកលើផ្ទៃទឹកដើម្បីដកដង្ហើម ។ ចំណីអាហាររបស់វាមាន បង្គា មឹក ត្រី ។

**របាយ និង ស្ថានភាព** : វាច្រើនរស់នៅតំបន់ព្រៃកោងកាង វាលភក់ ។ ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក ប៉ុន្តែពុំទាន់មានពត៌មានគ្រប់គ្រាន់ដើម្បីចាត់ថ្នាក់ក្នុងបញ្ជីក្រហម IVCN (DD) និងស្ថិតក្នុងតារាងឧបសម្ព័ន្ធទី១ របស់អនុសញ្ញា CITES ។





# ៥៨. ជ្រូកទឹក          Dugong *Dugong dugong*

**ទំហំ** : ប្រវែងសរុបវែងបំផុត ៣៣០០ ម.ម          ទំងន់ធ្ងន់បំផុត ៤០០ គ.ក្រ

**រូបភាព** : ជ្រូកទឹកមានព្រុយមុខពីរទំរង់ដូចច្រវាទូកនិងពុំមានក្រចកទេ ។ ច្រមុះរបស់វាអាចបិទ បើកបាន ។ ជាទូទៅស្បែករបស់វារលោង ជូនកាលមានផ្នត់ និងមានរោមខ្លីៗរង្វើលៗ ។ ជ្រូកទឹកពេញវ័យមានពណ៌ ប្រផេះស្រាលនៅផ្នែកពោះ ។ កូនរបស់វា មានពណ៌ប្រផេះស្រាល ។

**ជីវសាស្ត្រ** : ជ្រូកទឹកច្រើនរស់នៅជាហ្វូងតូចៗពី១រហូតដល់៦ក្បាល ។ វាអាចអត់ដង្ហើមក្នុងទឹករហូតដល់៨នាទី ។ ការបន្តពូជរបស់វាមានស្ទើរពេញមួយឆ្នាំ ហើយវាច្រើនកើតកូនចាប់ពីខែមិថុនាដល់ខែកញ្ញា ក្រោយពីមានគភ៌ អស់រយៈពេល ១៣-១៤ខែ ដោយកើតកូនម្តងបានមួយ ។ ចំណីអាហាររបស់វាមានរុក្ខជាតិស្ទើរគ្រប់ប្រភេទដែលមាននៅបាតសមុទ្រ ក៏ប៉ុន្តែអាហារសំខាន់របស់វាគឺស្មៅសមុទ្រ ។

**របាយ និង ស្ថានភាព** : ជាប្រភេទកម្រ មាននៅតាមតំបន់ឆ្នេរខេត្តកំពត កែប និងឆកកំពង់សោម ។ ត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។







# ៥៩.ដំរី Asian Elephant *Elephas maximus*

**ទំហំ** : ក្បាល-ដងខ្លួន :៤.០០០-៦.០០០.មម . កំពស់ : ២.៥០០-៣.០០០ មម. ទំងន់ : ៣.៥០០-៥.០០០ គក្រ ។

**ភិនភាគ** : ដំរីជាថនិកសត្វចតុបាតដែលមានមាឌធំជាងគេបំផុត ។ វាមានប្រមោយវែង មានស្បែកក្រាស់ និង មានរោមរឹងៗ ស្លឹកត្រចៀកមានរាងដូចផ្ចិត តែស្តើង ដំរីអាស៊ីមាន ក្រចកម្រាមជើង ១៨ គឺនៅជើងមុខនីមួយៗ មានក្រចកម្រាមជើង ៥ ឯជើងក្រោយ នីមួយៗមានម្រាមជើង ៤ តែក៏មានដំរីខ្លះ មានក្រចកម្រាម ជើងដល់ទៅ ២០ដែរ ។

**ជីវសាស្ត្រ** : ដំរីច្រើនរស់នៅតាមព្រៃល្បោះ និង វាលស្មៅ ព្រៃឫស្សី ។ វាស៊ីសំបកឈើ មើមឈើ ឫឫសឈើខ្ចីៗ ស្លឹកឫស្សី ផ្លែឈើដូចជាអំពៅ ចេក ។ល។ វាអាចផឹកទឹករហូត ដល់ ២០០លីត្រ ក្នុងមួយថ្ងៃ (នៅកន្លែងសំបូរទឹក) ។ ដំរីអាស៊ីមានភ្លុកតែដំរីឈ្មោល ឯដំរីញី និង ដំរីឈ្មោលខ្លះ ដែលយើងមើលមិនឃើញ ព្រោះភ្លុកនេះស្ថិតក្នុងមាត់ ។ ដំរីចិញ្ចឹមកូនដោយទឹកដោះ ដំរីច្រើនផ្តល់កំណើតនៅខែកក្កដា-សីហា ។ ពរពោះរយៈពេល ២១ខែ (យូរបំផុត ២៥ខែ) កើតកូនម្តងបាន ០១ក្បាល ដោយកម្រអាច កើតបានភ្លោះ ០២ក្បាល ដំរីមេ មួយក្បាល ក្នុងមួយជីវិតអាចបង្កើតកូនបាន ៤ ឬ ៥ដង ហើយដំរីមេ អាចមានកូនបានរហូតដល់អាយុ ៥០-៧០ឆ្នាំ ។ គេអាចសំគាល់ដំរីចុះប្រេងនៅពេលដែល គេឃើញមានប្រេងហូរចេញពីរន្ធមួយនៅចន្លោះរន្ធត្រចៀក និង ភ្នែក ។

**របាយ និង ស្ថានភាព** : ដំរីមានតិចតួចក្នុងប្រទេសកម្ពុជា ដែលមានស្ថិតនៅក្នុង តំបន់មួយចំនួនដូចជា ភូមិភាគឥសាន និរតី និង ភូមិភាគខាងជើង ។ ដំរីត្រូវបានហាម ឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួង កសិកម្មរុក្ខា-ប្រមាញ់ និង នេសាទ និង ជា ប្រភេទសត្វត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទសត្វកំពុងទទួលរង ការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។





# ៦០.រមាស(កុយមួយ)

**ទំហំ** : ក្បាល-ដងខ្លួន : ៣.០០០-៣.២០០ មម . កំពស់ត្រង់ស្មា : ១.៦០០-១.៨០០ មម. ទំងន់ : ១.៥០០-២.០០០ គក្រ ។

**ភិនភាគ** : រមាសមានស្បែកក្រាស់ និងមានផ្ទាំងផ្នត់៣ ផ្នត់ទី១ នៅផ្នែកខាងមុខស្មា ផ្នត់ទី២ នៅផ្នែកខាងក្រោយស្មា និងផ្នត់ទី៣ ចាប់ពីចង្កេះទៅក្រោមកាត់តាមជើងក្រោយមើលទៅដូចជាអាវក្រោះ ។ ស្បែកវារលីងមានពណ៌ប្រផេះ ។ រមាសមានជើងខ្លីៗតែរឹងមាំណាស់ ជើងនីមួយៗរបស់វាមានម្រាម ៣ ។ វាមានដុះកុយមួយនៅលើខ្នងច្រមុះរបស់វា ។

**ជីវសាស្ត្រ** : រមាសចូលចិត្តរស់នៅតាមព្រៃស្លុក ដែលមានទឹកគ្រប់គ្រាន់ វាចូលចិត្តដេកនៀលលេងភក់។ នៅរដូវបន្តពូជ រមាសរស់នៅជាគូ រមាសឈ្មោលចូលចិត្តចេញដើរឆ្ងាយៗ តែវាក៏ត្រឡប់មករកជំរករបស់វាវិញតាមផ្លូវដែលដែលវាចាកចេញ ឯរមាសញីចូលចិត្តនៅការពារជំរក ។ វាមានបបូរមាត់ខាងលើធំ បង្កលក្ខណៈងាយស្រួលដល់ការទាញយកមែកឈើ និង ស្លឹកឈើដាក់បញ្ចូលទៅក្នុងមាត់ ។ រមាសចិញ្ចឹមកូនដោយទឹកដោះ ពរពោះរហូតដល់ ១៦-១៨ខែ កើតកូនបាន ១ ក្នុងមួយលើក ។ កូនរមាសបៅដោះមេវា រយៈពេល ១ឆ្នាំ តែមេរបស់វានឹងនៅមើលថែកូនរហូតដល់ធំពេញវ័យ ។ រមាសអាចបង្កាត់ពូជបាននៅ ពេលរមាសញីមានអាយុពី ៣-៤ ឆ្នាំ និងរមាសឈ្មោលចាប់ពី អាយុ ៦ឆ្នាំ ។

**របាយ និង ស្ថានភាព** : រមាសមានរស់នៅកម្ពុជាជាយូរមកហើយ ឈ្មោះតំបន់មួយចំនួនក្នុងប្រទេសកម្ពុជាយើង បានយកឈ្មោះរមាសមកដាក់ ដូចជា : ក្បាលរមាស (ខេត្តកំពត) រមាសហែក(ខេត្តស្វាយរៀង) ស្ពុកអាចម៍រមាស(ខេត្តកំពង់ឆ្នាំង) នេះគឺជាភស្តុតាងយ៉ាងច្បាស់ដែលបញ្ជាក់ថា សត្វរមាសពិតជាធ្លាប់រស់ នៅព្រះរាជាណាចក្រកម្ពុជា ។ បើទោះបីជាគេពុំដែលមានការអះអាងពីវត្តមានជាកំណត់ក៏ដោយ ។ តាម

ការអះអាងពីប្រជាជនមូលដ្ឋានថា វាអាចមានរស់នៅតំបន់មួយចំនួនដូចជា ខេត្តក្រចេះ ខេត្តកំពង់ចាម និង តំបន់ភ្នំក្រវាញជាដើម ។ វាត្រូវបានហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និងចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុង ឧបសម្ព័ន្ធ ទី១ របស់អនុសញ្ញា CITES ។





# ៦១. ជ្រូកព្រៃ **Wild Pig** ***Sus scrofa***

**ទំហំ** : ក្បាល-ដងខ្លួនរហូតដល់ : ១៥០០ ម.ម . ទំងន់ : ១៥០ គក្រ ។

**ពិពណ៌ន** : ជ្រូកព្រៃជាសត្វមានសំបុរផ្លាស់ប្តូរទៅតាមវ័យ ជ្រូកក្មេង មានសំបុរពណ៌ប្រផេះ-ត្នោត និង ប្រែជាប្រផេះសុទ្ធកាលណាវាមានចំណាស់ជាង ៥ឆ្នាំ ។ ជ្រូកព្រៃបាមានកន្ទុយបះត្រង់ទៅក្រោយ ឬ ត្រង់ឡើងលើ ឯជ្រូកព្រៃមេ មានកន្ទុយសំយុងចុះក្រោម ។ ចំពោះចង្កូមមួយគូរនៅថ្គាមក្រោមលូតចេញ ជាខ្នាយមួយគូរស្រួចជួនកាលខ្នាយនេះកោងខុបជាពាក់កណ្តាលរង្វង់ ដែលជាឧបករណ៍សំខាន់សំរាប់ការពារខ្លួន ។ ជ្រូកព្រៃមាន វិញ្ញាណវៃបំផុត គឺច្រមុះ និង ត្រចៀក ។

**ជីវសាស្ត្រ** : ជាសត្វចូលចិត្តរស់នៅជាយព្រៃស្រោង ព្រៃកូនឈើស្ទាប់ជិត និង ព្រៃស្ងាត់ ដែលមានថ្លុក ត្រពាំងសំរាប់ដេកត្រាំភក់នៅពេលថ្ងៃ ហើយចូលចិត្តរស់នៅបំផុតក្នុងព្រៃសើម និងនៅរដូវប្រាំងវាតែងនៅតាមបណ្តោយដងស្ទឹង ព្រែក ។

ជ្រូកព្រៃជាសត្វស៊ីអាហារគ្រប់យ៉ាង មានសត្វឥតឆ្អឹងកងនានា ផ្សិត ឫសឈើ សាច់សត្វងាប់ មើមឈើ ពន្លកល្បះ ទំពាំង ព្រមទាំងផ្លែឈើ និង បន្លែ រាប់ទាំងគ្រាប់ធញ្ញជាតិផង ។ ក្នុងការរកចំណី វាប្រើច្រមុះសំរាប់ឈ្ងុសដីរឹង-ទន់ ។ ជ្រូកព្រៃជាធម្មតារកស៊ីនៅពេលព្រលឹមស្រាងៗ និង ព្រលប់ ប៉ុន្តែវា អាចរកស៊ីយប់ដែរ កាលណាបើមានការរំខានច្រើន ។

វាជោយញី-ឈ្មោលនៅខែវិច្ឆិកា ហើយក្រោយពីមានគភ៌រយៈពេល ៥ខែ មេជ្រូកអាចផ្តល់កំណើត កូនជាលើកដំបូងពី ៤-៨ក្បាល និង លើកទីពីរ ១៥-១៧ក្បាល វាបំបៅកូនពី ៣-៤ខែ ។ សត្វជ្រូកព្រៃ ញីអាចបន្តពូជ បាននៅអាយុ ៦-៧ខែ។ អាយុកាលរបស់វាជាមធ្យម ១០-១២ឆ្នាំ និង អាចដល់២០ឆ្នាំ ។

**របាយ និង ស្ថានភាព** : ជាសត្វមាននៅគ្រប់តំបន់ទូទាំងប្រទេស និង មានការរីកសាយយ៉ាងច្រើន ។ ជាប្រភេទសត្វត្រូវបានហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។





# ៦២.ឈ្លូសតូច

**Lesser Mousedeer**
*Tragulus javanicus*

**ទំហំ** : ក្បាល-ដងខ្លួន : ៤០-៤៨ មម. កំពស់ : ២០០ ម.ម. ទំងន់ : ០.៧-២ គក្រ ។

**ពិពណ៌ន** : ក្តាន់ព្រៀងតូច ឬផ្ទង់តូចជាសត្វមានមាឌប្រហាក់ប្រហែលនឹងទន្សាយ តែសម្បុរដូចសត្វឈ្លូស ។ នៅលើដងខ្លួនពាសដោយរោមពណ៌ក្រហមត្នោត និង ឆ្នូត ៣ជួរ នៅផ្នែកក្រោម ក ដែលឆ្នូតនេះអាចនឹងប្រែប្រួល ។ ផ្នែកខាងក្រោមនៃដងខ្លួន ស ឬ ស-លឿងស្រាល ។

**ជីវសាស្ត្រ** : ជាសត្វរស់នៅតែឯកឯង លើកលែងក្នុងរដូវបន្តពូជទើបវានៅជាគូរ ។ ជំរកដ៏ប្រសើរនៃសត្វ នេះគឺចូលចិត្តនៅតាមរន្ធឈើ ក្រហែងថ្ម ប៉ុន្តែបើពុំមានលទ្ធភាព បែបនេះទេ វាអាចរស់នៅតាមព្រៃឈើញឹក ចង្អៀត ឬព្រៃឫស្សីដែលគ្រជាក់ហើយ ងងឹត ។ ជាសត្វរាត្រីចរ ចំណីអាហាររបស់វា គឺពន្លករុក្ខជាតិ ត្រួយស្លឹកឈើ ផ្កា ផ្លែឈើ និងទំពាំងផង ។ ជាធម្មតាសត្វនេះវាធ្វើចលនាលោតត្រឹកៗផ្លោះយ៉ាងរហ័សនៅពេល មានអាសន្ន តែក្រោយពីរត់បានបន្តិច តែងឈប់ញឹកញាប់ហើយពិនិត្យមើលហេតុការណ៍ ជុំវិញខ្លួនវា ។ ក្នុងការទាក់ទងគ្នា ផ្ទង់តូចតែងគោះជើងក្រោយលើដី ឬ អង្កត់ឈើយ៉ាង រហ័សជាសញ្ញាសំគាល់ ។ សត្វនេះមានសមត្ថភាពខ្ពស់ក្នុងការបង្កើតកូន ក្រោយពីមាន គភ៌រយៈពេល ១៤០-១៧០ថ្ងៃ បង្កើតកូនបានមួយជួនកាលអាចភ្លោះ តែដោយកម្រ ។

**របាយ និង ស្ថានភាព** : មានជាមធ្យម និងស្មើរគ្រប់ទីកន្លែង និងជាប្រភេទត្រូវ បាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។





# ៦៣.ក្ដាន់ព្រៀងធំ Greater Mousedeer *Tragulus napu*

**ទំហំ** : ក្បាល-ដងខ្លួន : ៥០-៦០មម. កំពស់ : ៣០-៣៥សម. ទំងន់ : ៤-៦គក្រ ។

**ពិពណ៌ន** : ក្ដាន់ព្រៀងធំ ឬផ្ទុងធំក៏ដូចក្ដាន់ព្រៀងតូចដែរ រូបរាងដងខ្លួនពណ៌សម្បុរ និង លក្ខណៈជីវសាស្ត្ររបស់ក្ដាន់ព្រៀងធំ ពុំមានភាពខុសប្លែកគ្នាពីផ្ទុងតូចទេ ប៉ុន្ដែទំហំនៃដង ខ្លួន និង អវយវៈមានភាពខុសគ្នាខ្លះៗ ។

**ជីវសាស្ត្រ** : ផ្ទុងធំជាសត្វរស់នៅតែឯង ឬជាគូនៅពេលដោយញី-ឈ្មោល ហើយវា ចូលចិត្តរស់នៅក្នុង ក្រហែងថ្ម ឬរន្ធឈើ និង កន្លែងងងឹត ដែលមានការបិទបាំងជិតហើយ ត្រជាក់ ។ ផ្ទុងធំមានលក្ខណៈ និង ទំលាប់ ស្រដៀងគ្នានឹងផ្ទុងតូច ហើយវាមាន សមត្ថភាពខ្ពស់ណាស់ក្នុងការបង្កើតកូនដែលគេសង្កេតឃើញថា សត្វញីរកឈ្មោល និង រួមរ័ក្សគ្នាក្នុងរយៈពេល ២ថ្ងៃ ក្រោយពីកើតកូន ។ ជាធម្មតា វាកើតកូនតែមួយប៉ុណ្ណោះ ថ្វីបើអាចមានកូនភ្លោះយូរៗម្ដងក៏ដោយ ។

**ស្ថានភាព និង ស្ថានភាព** : មានជាមធ្យម និងស្ទើរគ្រប់ទីកន្លែង និង ជាប្រភេទត្រូវ ហាមឃាត់ការបរបាញ់ ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។







**ទំហំ** : រមាំងឈ្មោលមានកំពស់ ១.០០០-១.១៤០ មម រមាំងញីមានកំពស់ ១០០-១.០០០ មម . ទំងន់ : ១០០គក្រ ។

**ភិនភាគ** : ជាថនិកសត្វតិណាសី មានមាឌតូចជាងប្រើសបន្តិច ឯស្នែងវាមានចំពាមខ្លីបែកចុះក្រោម គ្របលើចិញ្ចើម ។ នៅខាងចុងស្នែងផ្នែកខាងលើ មានរាងសំប៉ែតបែកជាម្រាម ។ ជាធម្មតាសម្បុរវា លឿងស្រអាប់ឬក្រម៉ៅចាស់មានអុចៗស ឯផ្នែកពោះមានរោមពណ៌ស ។ ប៉ុន្តែសម្បុរនេះ អាចប្រែប្រួល ទៅតាមរដូវកាល ។ នៅរដូវជ្រុះស្នែង វាមានរោមវែងៗរុំជិតចំរុះពណ៌ប្រផេះ ក្រហម និង លឿងក្រម៉ៅ ដែលធ្វើឱ្យគល់កវាមានប្រែងយ៉ាងសង្ហា ។

**ជីវសាស្ត្រ** : រមាំងជាសត្វពុំសូវភ្ញាក់ផ្អើលរស់នៅជាហ្វូង ពី ១០-១៥ក្បាល ។ វាចូលចិត្តរស់នៅតាមវាល ទំនាប ថ្លុក ឬ ត្រពាំង និង ព្រៃជ្រុះស្លឹកជារៀងរាល់ឆ្នាំ ។ អាហាររបស់រមាំង គឺស្មៅ ស្បូវ ព្រិច ល្បះរុក្ខជាតិ ។ ថនិកសត្វនេះ ជ្រុះស្នែងរាល់ឆ្នាំនៅខែ មិថុនា ដែលជារដូវកាលសំបូរចំណីសំរាប់ការ លូតលាស់របស់ស្នែង ។ រដូវកាលញី-ឈ្មោល ប្រព្រឹត្តទៅក្នុងចន្លោះខែ មីនា-ឧសភា ហើយក្រោយពីរ ពោះ ៦-៨ខែ រមាំងកើតបានកូនមួយគត់ ។

**របាយ និង ស្ថានភាព** : មានដោយកម្រ មាននៅតំបន់ភូមិភាគខាងជើង និងឥសាន្ត ។ ជាប្រភេទ សត្វត្រូវហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។ និង ចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងតារាង ឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។





# ៦៥.ប្រើសស្បូវ Sambar *Cervus unicolor*

**ទំហំ** : ក្បាល-ដងខ្លួន :២.១០០ មម កំពស់ត្រង់ស្មា : ១.៣០០ម.ម ទំងន់ : ១២០-២០០ គក្រ

**ភិនភាគ** : ជាថនិកសត្វតិណាសី ស្ថិតក្នុងត្រកូលប្រើសដែលមានមាឌធំជាងគេ ។ រោមស្រោបជុំវិញដង ខ្លួនពណ៌ប្រផេះស្មើរក្រម៉ៅ និង មុំ ក រោមញីកសណ្ឋានជាប្រែង ។ កន្ទុយរបស់វាខ្លី មានរោមអង្កាញ់ តែងរស់រវីកជានិច្ចនៅពេលរកចំណី ។ នៅលើស្នែង ដែលពីក្នុងទៅក្រៅ និង ពីមុខទៅក្រោយ មានស្នែង ស្រួចដុះចេញពីភាគខាងក្រោយ និង ចំពាមមួយនៅភាគខាងលើផែកចុងស្រួចពីរ ជួនកាលចំពាមនេះជា លំនាំបន្តិចបន្តួច ប៉ុន្តែ ប្រើសខ្លះស្នែងចំពាមអាចលូតធំវែង អាស្រ័យនឹងសុខភាពរបស់វា ។ គ្រប់សត្វប្រើស ទាំងអស់មាន ក្រពេញក្លិនបើកចំហមួយនៅលើថ្ពាល់ ដែលជាការងាយស្រួលក្នុងការ ទំនាក់ទំនងគ្នាក្នុង ចំងាយមួយ ។

**ជីវសាស្ត្រ** : ជាសត្វរស់នៅជិតកន្លែងទឹកច្រើនបែបរាប់ទាំងព្រៃស្រោង ពាក់កណ្ដាលស្រោង និងព្រៃល្បោះ ។ រដូវកាច់ស្នែងប្រព្រឹត្តទៅក្នុងខែកក្កដា-កញ្ញា ជាពេលដែលវាត្រូវការ ពារស្នែងខ្ចីដោយមានការប្រុងប្រយ័ត្នបំផុត និង ពុំសូវបង្ហាញខ្លួន ។ ការរកចំណីប្រើស តែងប្រមូលផ្ដុំគ្នាជាហ្វូងតូច១ពី ៥-៦ក្បាល ។ នៅតាមតំបន់ព្រៃឈើដែលមានគ្រប់ សារព័ន្ធដំណុះរុក្ខជាតិដូចជា ត្រួយរុក្ខជាតិខ្ចី១ សន្លឹក ផ្កា ស្មៅ ស្បូវ និង ផ្លែឈើផងដែរ ពេលខ្លះ វារកស៊ីតាមដីទំនាបមានស្មៅ ទឹក និង ដីរាបផង សំរាប់ បង្កើនការលូតលាស់ ស្នែងខ្ចីរបស់វា ។ ប្រើសស្បូវមានទំលាប់ចេញរកស៊ីនៅពេលយប់ ចាប់ពីថ្ងៃលិចរហូត ដល់ថ្ងៃរះ ។ ដើមរដូវភ្លៀងជាពេលកាមសញ្ញាដែលប្រើសឈ្មោលស្កាត់រកហ្វូងប្រើសញី ដោយចេតនា ។ ការប្រមូលផ្ដុំរដូវស្បាវនេះ មានរយៈពេលខ្លី គឺក្នុងខែ មេសា-ឧសភា បន្ទាប់មកហើយប្រើសឈ្មោលបាន ចាកចេញពីប្រើសញីក្រោយពីមានគភ៌ ៨ខែ វាអាច បង្កើតបានកូនមួយ ។

**រចាយ និង ស្ថានភាព** : ជាប្រភេទសត្វមានវត្តមាននៅគ្រប់តំបន់ព្រៃឈើនៃ

ប្រទេស ។ ប្រើសស្បូវ ត្រូវបានហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួង កសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។





# ៦៦.ក្តាន់ Hog Deer *Axis porcinus*

**ទំហំ** : កំពស់ : ៨០០ សម . ទំងន់ : ៥០ គក្រ ។

**ពិពណ៌** : ជាថនិកសត្វមានរាងតូចជាងរមាំង សម្បុរលឿងត្នោត កន្ទុយតូចមានរោមក្រាស់ៗ ។ វាមាន ស្នែងដូចប្រើស តែតូច និង ខ្លីជាង ។

**ជីវសាស្ត្រ** : ក្តាន់ចូលចិត្តរស់នៅតាមព្រៃក្នុងវាលទំនាបល្បាប់ភក់ ឬតាមដំណុះរុក្ខជាតិសងខាងទន្លេ ជាពិសេសជិតតំបន់វាលភក់ដែលមានស្មៅខ្ពស់ៗ ។ ជារឿយៗសត្វនេះរស់នៅជាគូ ញី-ឈ្មោល តែជុំគ្នាជាហ្វូងពី ១០-១៥ក្បាល ។ អាហាររបស់ក្តាន់ពុំខុសគ្នានឹងថនិកសត្វស្នែងគាន់ឯទៀតទេ ។ ការជំរុះស្នែង ប្រព្រឹត្តទៅក្នុងខែ មករា-មិនា ហើយស្នែងដុះខ្ចី (ស្នែងទន់) មានរោមស្តើងខុសពីប្រើស ។ រដូវកាល់ ញី-ឈ្មោលរបស់ក្តាន់ គឺក្នុងខែ មិថុនា-កក្កដា ក្រោយពីពរពោះ ៨ខែ ក្តាន់ញីបង្កើតកូនបានមួយ ។

**ស្ថានភាព និង ស្ថានភាព** : ជាប្រភេទសត្វមានដោយកម្រ ។ មាននៅភូមិភាគពិរតី ។ ជាប្រភេទសត្វ ត្រូវបានហាមឃាត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ។ ត្រូវបានចុះក្នុងបញ្ជី ក្រហម IVCN (DD) ជាប្រភេទមិនទាន់មានទិន្នន័យគ្រប់គ្រាន់និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។





# ៦៧.ឈ្លូស Red Muntjac *Muntiacus muntjak*

**ទំហំ** : ក្បាល-ដងខ្លួន : ៩០០-១.០៥០ មម. ទំងន់ : ២០-២៨ គក្រ ។

**ភិនភាគ** : ឈ្លូសជាថនិកសត្វគិលាសី មានរោមគ្របពីដងខ្លួនពណ៌ក្រហមស្រគាំ ។ ក្រោមពោះ កន្ទុយ និង ផ្ទៃខាងក្នុងភ្លៅមានពណ៌ ស ។ ស្នែងឈ្លូសមានប្រវែងអតិបរមា ១៨សម ស្នែងនីមួយៗ ចែកជាពីរកំណាត់ គឺដំបូងជាឆ្អឹងមានកំពស់ ១២សម ស្រោបដោយរោមជិត និង ភាគបន្តគឺជាតួស្នែងតាន់ ដែលមានរាងជាទំពក់ខុបពីក្រៅចូលទៅក្នុង ។ នៅជាប់នឹងគល់ស្នែង មានមៀងខ្លីមួយបែកចាក់ទៅ ខាងមុខបន្តិច ។

**ជីវសាស្ត្រ** :ឈ្លូសតែងតែដើរ និង រត់ដោយដាក់ក្បាលយ៉ាងទាប ។ នៅពេលភ្ញាក់ ឬធុំក្លិនអ្វីចំឡែក វាតែងតែស្រែក អឺក អឺក ... ជួនកាលសម្រែកនេះមានច្រើនទាទី រួចដើរចេញយឺតៗ ពេលជុះអាចម៍ វាស្រែកក្អកៗ ។ សត្វនេះមាន ទំលាប់រស់នៅតែឯង និង ជាគូរក្នុងរដូវបន្តពូជ ។ វាជាសត្វរស់នៅក្នុងព្រៃគ្រប់ប្រភេទដូចជា ព្រៃល្បោះ ព្រៃស្រោង វាលស្មៅជាដើម ។ នៅរដូវវស្សាឈ្លូសមានទំលាប់រស់នៅតាមព្រៃស្រោង តំបន់ទំនាប ក្បែរជ្រោះសំបូរស្មៅ ។ នៅរដូវប្រាំងវាចេញទៅ រកស៊ីព្រៃល្បោះ វាលស្មៅព្រិច ។ ជាសត្វរកស៊ីពេលយប់ និង ព្រលឹម ស្រាងៗ អាហាររបស់វាគឺ ស្មៅ ល្បះខ្ចីនៃរុក្ខជាតិ និង ផ្លែឈើ ។ ជារៀងរាល់ឆ្នាំឈ្លូសជំរុះស្នែងរវាងខែ កក្កដា-សីហា ហើយស្នែងខ្ចីក៏ចាប់ដុះឡើងវិញ ។ ក្នុងរយៈពេលនេះវាពុំសូវបង្ហាញវត្តមានទេ ដើម្បីសុវត្ថិភាពខ្លួន និង ថែរក្សាស្នែងឱ្យបានរឹងមាំ ។ រដូវកាលញី-ឈ្មោល ប្រព្រឹត្តទៅក្នុងខែ ធ្នូ - មករា ក្រោយមកវាផ្តល់កំណើតកូនមួយ (កម្រភ្លោះ) នៅក្នុងខែមិថុនា ឬ កក្កដា ក្រោយពីមានគភ៌ ៦ខែ ។

**របាយ និង ស្ថានភាព** : ជាប្រភេទសំបូរ មានស្ទើរគ្រប់ទីកន្លែង និង ជាប្រភេទសត្វហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។









# ៦៨.ឈ្លូសយក្ស

## Large-antlered Muntjac
*Muntiacus vuquangensis*

**ពិពណ៌** : ជាថនិកសត្វតិណាសី មានមាឌធំជាងឈ្លូសបន្តិច សត្វទាំងពីរនេះមានលក្ខណៈ និង ពណ៌ សម្បុរស្រដៀងគ្នា ប៉ុន្តែនៅផ្នែកចំហៀងខ្លួនវាមានពណ៌ត្នោតចាស់ តែឈ្លូសមានពណ៌ក្រម៉ៅ ។ កន្ទុយ ឈ្លូសយក្សមានពណ៌ត្នោតចាស់ ធំ និង ខ្លីជាងឈ្លូសធម្មតា ។ ស្នែងវាធំ និង វែងជាង ជាធម្មតាមិន បត់កោងផ្នែកចុងដូចស្នែងឈ្លូសទេ ។ ហើយផ្នែកគល់ស្នែងចាប់ពីជំពាមមកក្រោម ស្រោបដោយរោមជិតមានប្រវែងខ្លីជាងឈ្លូសធម្មតា ។

**ជីវសាស្ត្រ** : ឈ្លូសយក្សចូលចិត្តរស់នៅតំបន់ខ្ពង់រាបដែលមានរយៈកំពស់ ៥០០ម ក្នុងព្រៃស្រោង ពាក់កណ្ដាលស្រោង ។ វាចេញរកស៊ីនៅពេលព្រឹកព្រលឹម និង ពេលព្រលប់ ។ ស្លឹករុក្ខជាតិខ្ចីៗស្ទើរគ្រប់ប្រភេទ និង ផ្លែឈើ ជាចំណីដ៏ប្រសើររបស់ឈ្លូសយក្ស ។ ជាធម្មតា ឈ្លូសយក្សចូលចិត្តរស់នៅឯកឯង ជួនកាលនៅជាគូ តែមិនផ្តុំគ្នាជាហ្វូងទេ ។

**របាយ និង ស្ថានភាព** : ជាសត្វមានដោយកំរ ។ មានរស់នៅភូមិភាគឥសាន្ត ភូមិភាគខាងជើង និងតំបន់ជួរភ្នំក្រវាញ ។ ស្ថិតក្នុងឧបសម្ព័ន្ធ ទី១ នៃអនុសញ្ញា CITES ។



**ទំហំ** : ក្បាល-ដងខ្លួន : ២.១០០-២.២២៥ ម.ម . កំពស់ត្រង់ស្មា : ១.៧១០-១.៩០០ ម.ម . ទំងន់ : ៧០០-៩០០គក្រ ។

**ភិនភាគ** : គោព្រៃជាប្រភេទមួយមានរូបរាងស្រដៀងទៅនឹងទន្សោង ។ ប៉ុន្តែគេអាចសំគាល់បានច្បាស់ តាមលក្ខណៈមួយចំនួន បើទោះជាវាមានរូបរាងស្រដៀងទន្សោងក៏ដោយ ។ គោព្រៃមានបូរវែងធ្លាក់ ចុះដល់ជង្គង់ និងស្ទើរតែដល់ដីនៅពេលវាចាស់ ។ ស្នែងគោព្រៃឈ្មោល និង ញី មានលក្ខណៈខុសគ្នា ។ ស្នែង ឈ្មោលធំជាងស្នែងញី វាដុះចេញមកក្រៅកោងទៅមុខ រួចងើបឡើងលើ និងមានបែកចុងស្នែងនៅ ពេលដែល-វាមានអាយុប្រមាណ ៣ ឆ្នាំ ។ ស្នែងញីដុះមកមុខរាងងើបបន្តិច រួចរមួលឡើងលើ ។ ជើងក្រោមជង្គង់ទាំងបួនមានពណ៌ស ឬប្រផេះ ។ សំបុររបស់គោព្រៃអាចប្រែប្រួល នៅពេលក្មេងមាន សំបុរត្នោត ដល់ជំទង់មានសំបុរប្រផេះ និង ប្រផេះចាស់នៅពេល វាចាស់ ។

**ជីវសាស្ត្រ** : គោព្រៃចូលចិត្តរស់នៅតាមព្រៃល្បោះ វាលស្មៅមានព្រៃគម្ពោត និងជាពិសេសតំបន់ដី ទ្រាប ។ វារស់នៅជាហ្វូង១ គេអាចជួបប្រទះជាមួយហ្វូងទន្សោង ខ្ទីង ឬ ប្រើសជាដើម ។ វាចេញរកស៊ី នៅពេលព្រឹកព្រលឹម និង ព្រលប់ ។ គោព្រៃដោយញី-ឈ្មោលក្នុងកំឡុងខែ មេសា និង បង្កើតកូន ក្នុងខែ ធ្នូ ឬ មករា ។ វាជាសត្វដែលឆាប់ផ្អើលជាងប្រភេទដទៃទៀត ។

**ស្ថានភាព និង របាយ** : គោព្រៃជាប្រភេទមួយកម្របំផុត ។ វាអាចមាននៅតំបន់មួយចំនួន ដូចជា ខេត្តសៀមរាប ឧត្តរមានជ័យ ខេត្តព្រះវិហារ និង ភូមិភាគឥសាន្ត មានខេត្តមណ្ឌលគិរី និង រតនៈគិរី ។ គោព្រៃជាប្រភេទមួយត្រូវបានហាមឃាត់ការបរបាញ់ និង ធ្វើអាជីវកម្ម ដោយប្រកាសរបស់ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។ និងត្រូវបានចុះបញ្ជីក្រហម IVCN (GT) ជាប្រភេទដែលទទួលរងការ គំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។









## ៦៩.គោព្រៃ Kouprey *Bos sauveli*

**ទំហំ** : ក្បាល-ដងខ្លួន : ២.១០០-២.២២៥ ម.ម . កំពស់ត្រង់ស្មា : ១.៧១០-១.៩០០ ម.ម . ទំងន់ : ៧០០-៩០០គក្រ ។

**រូបភាព** : គោព្រៃជាប្រភេទមួយមានរូបរាងស្រដៀងទៅនឹងទន្សោង ។ ប៉ុន្តែគេអាចសំគាល់បានច្បាស់ តាមលក្ខណៈមួយចំនួន បើទោះជាវាមានរូបរាងស្រដៀងទន្សោងក៏ដោយ ។ គោព្រៃមានបួរវែងធ្លាក់ ចុះដល់ជង្គង់ និងស្ទើរតែដល់ដីនៅពេលវាចាស់ ។ ស្នែងគោព្រៃឈ្មោល និង ញី មានលក្ខណៈខុសគ្នា ។ ស្នែង ឈ្មោលធំជាងស្នែងញី វាដុះចេញមកក្រៅកោងទៅមុខ រួចងើបឡើងលើ និងមានបែកចុងស្នែងនៅ ពេលដែល-វាមានអាយុប្រមាណ ៣ ឆ្នាំ ។ ស្នែងញីដុះមកមុខរាងងើបបន្តិច រួចរមួលឡើងលើ ។ ជើងក្រោមជង្គង់ទាំងបួនមានពណ៌ស ឬប្រផេះ ។ សំបុររបស់គោព្រៃអាចប្រែប្រួលនៅពេលក្មេងមាន សំបុរត្នោត ដល់ជំទង់មានសំបុរប្រផេះ និង ប្រផេះចាស់នៅពេលវាចាស់ ។

**ជីវសាស្ត្រ** : គោព្រៃចូលចិត្តរស់នៅតាមព្រៃល្បោះ វាលស្មៅមានព្រៃគម្ពោត និងជាពិសេសតំបន់ដី ច្រាប ។ វារស់នៅជាហ្វូងៗ គេអាចជួបប្រទះជាមួយហ្វូងទន្សោង ខ្ទីង ឬ ប្រើសជាដើម ។ វាចេញរកស៊ី នៅពេលព្រឹកព្រលឹម និង ព្រលប់ ។ គោព្រៃដោយញី-ឈ្មោលក្នុងកំឡុងខែ មេសា និង បង្កើតកូន ក្នុងខែ ធ្នូ ឬ មករា ។ វាជាសត្វដែលឆាប់ផ្អើលជាងប្រភេទដទៃទៀត ។

**ស្ថានភាព និង របាយ** : គោព្រៃជាប្រភេទមួយកម្របំផុត ។ វាអាចមាននៅតំបន់មួយចំនួន ដូចជា ខេត្តសៀមរាប ឧត្តរមានជ័យ ខេត្តព្រះវិហារ និង ភូមិភាគឥសាន្ត មាន ខេត្តមណ្ឌលគិរី និង រតនៈគិរី ។ គោព្រៃជាប្រភេទមួយត្រូវបានហាមឃាត់ការបរបាញ់ និង ធ្វើអាជីវកម្ម ដោយប្រកាសរបស់ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។ និងត្រូវបានចុះបញ្ជីក្រហម IVCN (GT) ជាប្រភេទដែលទទួលរងការ គំរាមកំហែងលើពិភពលោក និង ស្ថិតក្នុងឧបសម្ព័ន្ធទី ១ របស់អនុសញ្ញា CITES ។









# ៧០.ខ្ទីង

**Gaur** *Bos gauru*

**ទំហំ** : ក្បាល-ដងខ្លួន : ២.៥០០-៣.០០០ មម . កំពស់ត្រង់ស្មា : ១.៧០០-១.៨៧០ មម . ទំងន់ : ៦៥០-៩០០គក្រ ។

**ពិពណ៌ន** : ខ្ទីងមានមាឌធំ ខ្លួនខ្មៅ បូកក្រាស់ លាតសន្ធឹងរហូតដល់ស្ទើរពាក់កណ្តាលខ្នង ។ ក ខ្លីបន្តិច រាងមាំ មានបួរនៅផ្ទៃកខាងក្រោម ។ ជើងទាំងបួនចាប់ពីជង្គង់ចុះក្រោមពណ៌សប្រផេះ។ ។ នៅលើថ្ងាស មានរោមវែងពណ៌ប្រផេះ ឬ ពណ៌លឿងមាសស្រាល ។ កូនរបស់វាមានពណ៌ត្នោត រហូតដល់វាមាន អាយុពី ៤-៥ ខែ ទើបក្លាយទៅជាពណ៌ខ្មៅ ។ ខ្ទីងញីមានមាឌ ស្នែង តូចជាង ហើយពុំសូវមានបូក និងបួរដូចខ្ទីងឈ្មោលទេ ។ ស្នែងខ្ទីងរាងសំប៉ែតជាងស្នែងទន្សោង ហើយដុះមកពណ៌ប្រផេះខៀវផ្ទៃកគល់ ដុះចេញក្រៅ រួចកោងឡើងលើដូចទន្សោងដែរ ។

**ជីវសាស្ត្រ**: ខ្ទីងអាចរស់នៅបានលើរយៈកំពស់ពីតំបន់ទំនាបរហូតដល់កំពស់ ២០០០ម ។ ខ្ទីងរស់នៅ ក្នុងព្រៃស្រោង ព្រៃល្បោះ វាលស្មៅ និងអាចរស់នៅរយៈកំពស់ខ្ពស់ជាងទន្សោង ។ ជាធម្មតា ខ្ទីងចេញ រកស៊ីនៅពេលព្រលឹម និង ពេលល្ងាច ។ វាចូលចិត្តរស់នៅជាហ្វូង ។ អាហាររបស់វាល្បះខ្ចី ទំពាំង ស្មៅ វល្លិ៍ ជាដើម ។ ខ្ទីងញីអាចបង្កើតកូនមួយបន្ទាប់ពីមានគភ៌រយៈពេលពី ៨-៩ ខែកន្លះ ។

**ស្ថានភាព និង របាយ** : ខ្ទីងជាប្រភេទមួយដែលរងនូវការគំរាមកំហែងយ៉ាងខ្លាំង ហើយចំនួនរបស់វាមានការថយចុះគួរឱ្យព្រួយបារម្ភ ។ ខ្ទីងរស់នៅក្នុងតំបន់មួយចំនួនដូចជាភូមិភាគឥសាន្ត ភូមិភាគខាងជើង ខេត្ត កោះកុង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ ជាដើម ។ ខ្ទីងត្រូវបានចាត់ចូលក្នុងប្រភេទហាមឃាត់ការបរបាញ់ និង ធ្វើអាជីវកម្ម ដោយប្រកាសរបស់ក្រសួង កសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ជាប្រភេទសត្វចុះក្នុងបញ្ជីក្រហម IUCN (GT) ដែលទទួលការគំរាមកំហែងលើពិភពលោក និងស្ថិតក្នុងតារាងឧបសម្ព័ន្ធទី១ របស់អនុសញ្ញា CITES ។





# ៧១.ខទ្បោង Banteng *Bos javanicus*

**ទំហំ** : ក្បាល-ដងខ្លួន : ១.៩០០-២.២៥០ ម.ម កំពស់ត្រង់ស្មា : ១.៥៥០-១.៦៥០ ម.ម , ទំងន់ : ៦០០-៨០០គ.ក្រ ។

**ពិពណ៌នា** : ខទ្បោងមានរូបរាងដូចគោស្រុក ។ ខទ្បោងជំទង់មានសំបុរត្នោតថ្លា ។ ជើងទាំង ៤ ខាង ក្រោមជង្គង់មានពណ៌ ស ដូចខ្ទីង និង គោព្រៃរេះ ។ ប៉ុន្តែវាមានចំណុចមួយដែលប្លែកពីគេ គឺពណ៌ ស នៅផ្នែកក្រោយត្រង់គូថ ។ ស្នែងខទ្បោងរាងមូលជាងស្នែងខ្ទីង មានពណ៌លឿងស្រគាំនៅផ្នែកពាក់កណ្តាលចុះក្រោម ហើយចុងស្នែងពណ៌ខ្មៅ ។

**ជីវសាស្ត្រ** : ខទ្បោងចូលចិត្តរស់នៅតំបន់ព្រៃល្បោះ វាលស្មៅ ព្រៃគម្ពោតជាដើម ។ វាមិនសូវរស់ នៅតំបន់ទីចំណោតទេ ។ វាចូលចិត្តរស់នៅជាហ្វូងៗ ឬនៅជាមួយគោព្រៃប្រើស ខ្ទីង ជាដើម ។ ខទ្បោងចេញរកស៊ីនៅព្រឹកព្រលឹម និង ពេលល្ងាច ។ ជាធម្មតាហ្វូងខទ្បោងតែងតែដឹកនាំដោយមេហ្វូង ជាខទ្បោង មេចាស់ ។ ខទ្បោងដោយញី-ឈ្មោលនៅខែ ឧសភា-មិថុនា និង អាចបង្កើតកូនបាន ១-២ក្បាល បន្ទាប់ពីមានគភ៌បាន ៩-៩ខែកន្លះ ។ វាអាចបន្តពូជបាននៅអាយុមិនតិចជាង២ឆ្នាំ ។

**ស្ថានភាព និង រេបាយ:** ខទ្បោងជាប្រភេទដែលទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងពីការបរបាញ់ ដើម្បីពាណិជ្ជកម្មសាច់ ស្នែង ។ បច្ចុប្បន្ន ខទ្បោងពុំសូវសំបូរទេ ចំនួនរបស់វាមានការថយចុះយ៉ាងខ្លាំងក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ ។ វារស់នៅរាយប៉ាយស្ទើរគ្រប់ទីកន្លែង មានដូចជា ភាគនិរតី ភាគឥសាន្ត និង ភាគខាងជើងនៃប្រទេសកម្ពុជា ។

ខទ្បោងត្រូវបានចាត់ចូលក្នុងប្រភេទសត្វហាមឃាត់ការបរបាញ់ក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ជាប្រភេទសត្វដែលទទួលរងនូវការគំរាមកំហែងលើពិភពលោកដែល ស្ថិតក្នុងបញ្ជីក្រហម IUCN (GT) ។





# ៧២. ក្របីព្រៃ Wild Water Buffalo *Bubalus arnee*

**ទំហំ** : ក្បាល-ដងខ្លួន : ២៤០០-២៨០០ មម . កំពស់ត្រង់ស្មា : ១៦០០-១៩០០ មម . ទំងន់ : ៨០០-១២០០ គក្រ ។

**រូបភាព** : ក្របីព្រៃមានរូបរាងដូចក្របីស្រុក ។ ប៉ុន្តែក្របីព្រៃមានភាពរហ័សរហួនជាង និង ឆាប់ក្រេវ ក្រោធ ។ វាមានពណ៌ប្រផេះ ឬ ត្នោតខ្មៅ ។ នៅខាងក្រោម ក មានពណ៌ ស រាងជាអក្សរវេ (V) ។ ស្នែងទាំងពីរមានរាងសំប៉ែតគន្លាក់១បត់ទៅក្រោយក្របីព្រៃមានតំណាតស្នែងធំជាងក្របីស្រុក ។

**ជីវសាស្ត្រ** : ក្របីព្រៃចូលចិត្តរស់នៅតំបន់ព្រៃល្បោះ វាលស្មៅក្បែរទឹក វាពុំសូវចូលចិត្តព្រៃស្រោងទេ ។ ក្របីព្រៃរស់នៅជាហ្វូង ហើយចេញទៅរកស៊ីនៅពេលព្រឹកព្រលឹម និង ពេលល្ងាច ។ នៅពេលថ្ងៃវាដេក ទំពារអៀង ឬដេកត្រាំទឹក ។ ក្របីព្រៃដោយញីឈ្មោលនៅកំឡុងខែ តុលា-វិច្ឆិកា និង បង្កើតបាន កូនមួយបន្ទាប់ពីមានគភ៌រយៈពេលប្រហែល ១០ខែ ។

**ស្ថានភាព និង រចាយ** : ក្របីព្រៃជាប្រភេទមួយគម្រ វាមានចំនួនតិចតួចដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា ។ ក្របីព្រៃ មានវត្តមានតែក្នុងប៉ុន្មានខេត្តប៉ុណ្ណោះ ដូចជាខេត្តព្រះវិហារ និង ខេត្តមណ្ឌលគិរី រតនគិរី ។ ក្របីព្រៃត្រូវបានចាត់ចូលក្នុងប្រភេទហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់និងនេសាទ និងត្រូវបានចុះក្នុងបញ្ជី IVCN (GT) ជាប្រភេទដែលទទួលរងនូវការគំរាមកំហែង លើពិភពលោក ។





# ៧៣.ខ្ទីងវល្លិ៍ Khting Vor *Pseudonovibos spiralis*

ខ្ទីងវល្លិ៍គឺជាប្រភេទខ្ទីងម្យ៉ាង ដែលមនុស្សភាគតិចបំផុតបានឃើញនិងស្គាល់ ។ អាថិកំបាំងប្រភេទ សត្វខ្ទីងវល្លិ៍គឺពុំទាន់មាននរណាម្នាក់មានកំណត់ត្រាច្បាស់លាស់នៅឡើយទេ។ ប៉ុន្តែគេអាចកំណត់សំគាល់វា បានតាមរយៈស្នែង ។ប្រជាជនខ្មែរមានជំនឿថា ក្រៅពីចំណើរបស់វា វាប្រហែលជាសត្វស៊ីសត្វពស់ដែរ ហើយដោយសារពិសពស់ពុំអាចសម្លាប់វាបាន ទើបគេយកស្នែងរបស់វាមក ធ្វើថ្នាំរំងាប់ពិសពស់ ។ ស្នែងខ្ទីងវល្លិ៍ មានលក្ខណៈខុសពីស្នែងសត្វដទៃ វាមានរាងដូចស្លឹកដុះឡើងលើ ពៀកចេញបន្តិចនិងបត់រមួលនៅផ្នែកខាងចុង ។ ចំណែករូបរាង និង ពណ៌សំបុររបស់វា គឺយើងពុំអាច-ពិពណ៌នាបានទេ។ ប្រភេទនេះអាច មានរស់នៅតំបន់ភាគខាងឥសាន និង ជួរភ្នំក្រវាញនិងត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក ។

**ទំហំ** : ក្បាល-ដងខ្លួន : ១.៤០០-១.៥០០ មម . កំពស់ត្រង់ស្មា : ៨៥០-៩៤០ មម . ទំងន់ : ៨៥-១៤០ គក្រ ។

**ពិពណ៌នា** : កែះមានសំបុរខ្មៅប្រផេះ និង រោមវែងៗស្តើង ។ វាមានខ្លួនខ្លី ហើយជើងទាំង ៤ របស់វាវែង មានស្នែងដូចសត្វពពែ ដុះបត់កោងទៅក្រោយបន្តិចប្រវែងពី ២០០-៣០០មម ពណ៌ខ្មៅ និង មាន គន្លាក់ៗនៅផ្ទៃកគល់ ។ ផ្នែកខាងលើដងខ្លួនសំបុរខ្មៅ និង ផ្នែកក្រោមចាប់ពីក្បាលជង្គង់ចុះពណ៌ប្រផេះ ។ នៅលើ ក របស់វាមានរោមវែងៗសំបុរលឿង ។ កន្ទុយខ្លី ហើយមានរោមច្រើនសំពោង សម្បុរខ្មៅប្រផេះ ត្រចៀកវាវែងត្រង់ខ្មៅលើ ។

**ជីវសាស្ត្រ** : កែះចូលចិត្តរស់នៅតំបន់ព្រៃភ្នំ ជ្រលង ថ្មាំងថ្ម ដែលមានគំរបព្រៃ និង ស្រទាប់រុក្ខជាតិថ្នាក់ក្រោមច្រើន ។ កែះមានជើងយ៉ាងចំណាប់ក្នុងការដើរឡើងតាមថ្មាំងថ្មចោតៗ។ នៅពេលថ្ងៃវាចូលចិត្ត សំរាកតាមគម្ពោតព្រៃក្រាស់ ហើយចេញរកស៊ីនៅពេលព្រឹកព្រលឹម ឬក្បាលព្រលប់ ។ វាស៊ីរុក្ខជាតិស្ទើរ គ្រប់ប្រភេទ ។ ជាធម្មតាវារស់នៅឯកោ ។ វាបន្តពូជនៅខែ តុលា-ធ្នូ និងកើតបាន កូន ១-២ បន្ទាប់ពីមានគភ៌ ៧ខែ ។ កូនរស់នៅជាមួយមេវាស្ទើរពេញមួយឆ្នាំទើបចាកចេញ ។

**ស្ថានភាព និង របាយ** : សត្វកែះជាប្រភេទកម្រ ។ គេអាចជួបវាយ៉ាងលំបាកនៅតាម តំបន់ព្រៃភ្នំ ។ ភាគច្រើនរស់នៅភូមិភាគឥសាន និង និរតីនៃប្រទេស ។

កែះត្រូវបានចាត់ចូលក្នុងប្រភេទសត្វហាមឃាត់ការបរបាញ់ ដោយប្រកាសក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។ ជាប្រភេទសត្វដែលទទួលការគំរាមកំហែងលើពិភពលោក ដែលបានចុះក្នុងបញ្ជី ក្រហម IUCN (GT) និង ស្ថិតក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញា CITES ។





## ៧៥.កំប្រុកធំ Black Giant Squirrel *Ratufa bicolor*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៣៧០-៤០៥ ម.ម កន្ទុយ ៤២៥-៥០០ម.ម

ទំងន់ ១.៤ គ.ក

**ភិនភាគ** : ជាប្រភេទកំប្រុកដែលមានទំហំធំ កន្ទុយវែងជាងក្បាលនិងដងខ្លួន ។ ផ្នែកក្រោមពោះ សម្បុរលឿងទុំ ។ ផ្នែកខ្នងមានពណ៌ខ្មៅ ឬត្នោតចាស់ បំពង់ក និងក្បាលខាងលើ និងនៅជុំវិញភ្នែកមានពណ៌ខ្មៅ មានអុចៗ ខ្មៅពីរ នៅទឹងចង្កា និងកន្ទុយពណ៌ទឹកក្រូច នៅផ្នែកខាងក្រោម ។

**ជីវសាស្ត្រ** : វារស់នៅក្នុងរន្ធឈើខ្ពស់ លើដើមឈើធំៗតាមមាត់ស្ទឹង ឬ អូរ។ វាធ្វើចលនាផ្លាស់ទីពីមែកឈើមួយទៅ មែកឈើមួយទៀត ឬ ពីដើមឈើមួយទៅដើមឈើមួយទៀត ដោយវារ ឬលោត។ វាជាសត្វ រកស៊ីនៅពេលថ្ងៃ ។ ចំណីអាហាររបស់វាមានសត្វល្អិត ពងសត្វស្លាប ផ្លែឈើ ។

**របាយ និង ស្ថានភាព** : មានជាមធ្យម ស្ទើរទូទាំងប្រទេស នៃតំបន់ដែលមានព្រៃក្រាស់ និងដើមឈើខ្ពស់ៗ និង ត្រូវបានចុះក្នុងតារាងឧបសម្ព័ន្ធទី ២ របស់អនុសញ្ញា CITES ។



# ៧៦.កំប្រុកឆ្នូតខ្នង

**Pallas's Squirrel**
***Callosciurus erythraeus***

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ២០០-២៦០ ម.ម        កន្ទុយ ១៩៧ ម.ម

**ភិនភាគ** : ជាប្រភេទសត្វដែលមានមាឌជាមធ្យម និងមានឆ្នូតនៅតាមបណ្តោយខ្នង។ ខ្នង និង កន្ទុយមានពណ៌ប្រផេះ ត្នោត ហើយជាធម្មតាមានឆ្នូតពណ៌ក្រហម ។

**ជីវសាស្ត្រ** : វាច្រើនរស់នៅក្នុងប្រភេទព្រៃស្រោង ព្រៃល្បោះ តំបន់ព្រៃភ្នំដែលមានរយៈកំពស់ប្រហែល ១០០០ម៉ែត្រ ហើយពេលខ្លះគេក៏អាចឃើញវានៅក្នុងព្រៃឫស្សីក្នុងតំបន់វាលទំនាបដែរ។ វាតែងតែរស់នៅដាច់តែឯង ឬជាក្រុមគ្រួសារតូច ។ ពួកវាធ្វើសំបុកនៅតាមមែកឈើខ្ពស់ៗ ។ ចំណីអាហាររបស់វាមាន បន្លែ រុក្ខជាតិ និង សត្វល្អិត ។

**របាយ និង ស្ថានភាព** : មានជាមធ្យម នៅភាគខាងកើតទន្លេមេគង្គ ។



# ៧៧.កំប្រុកពណ៌

**Variable Squirrel**
***Callosciurus finlaysonii***

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ២១២-២១៨ ម.ម កន្ទុយ ២២៥-២៤០ ម.ម ទំងន់ ៣០០ ក្រ

**ពិពណ៌ន** : វាមានដងខ្លួនគ្របដណ្ដប់ដោយរោមទន់ និងមានសំបុរច្រើនពណ៌ ខ្លះមានសំបុរខ្មៅ ខ្លះស ខ្លះក្រហមសុទ្ធ ខ្លះលាយចំរុះពណ៌ ខ្លះមានពណ៌ក្រម៉ៅចាស់ មានបង្កង់ពណ៌សតល់កន្ទុយ និង ខ្លះមានកន្ទុយក្រហមត្នោត។ កន្ទុយវែង ហើយរោមកន្ទុយវែងជាងរោមដងខ្លួន ។

**ជីវសាស្ត្រ** : វារស់នៅក្នុងព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃរបោះ ចំការដូង ហើយធ្វើសំបុកក្នុងរន្ធឈើ ។ អាយុកាលរបស់វាអាចរស់បានរហូតដល់ ២៧ឆ្នាំ ហើយជាប្រភេទសត្វរហ័សរហួន។ រស់នៅលើដើមឈើ វាជាសត្វភាត្រីចរ ។ ចំណីអាហាររបស់វាមានផ្លែឈើ គ្រាប់ធញ្ញជាតិ និងអាហារផ្សេងៗទៀត ជាពិសេសគ្រាប់ខាងក្នុង ។ សត្វញីមានដោះពីរគូ ។

**របាយ និង ស្ថានភាព** : វាជាប្រភេទសត្វសំបូរ មាននៅភាគខាងជើងបឹងទន្លេសាប និង ខាងលិចទន្លេមេគង្គ ។





# ៧៨.កខ្ចិច

**Cambodian Striped Squirrel**
*Tamiops rodolphi*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួនប្រហែល ១២៣ ម.ម    កន្ទុយ ១២២ ម.ម

**ភិនភាគ** : វាមានមាឌតូចល្អិត សំបុរត្នោត ផ្ទៃកខ្ចង និង មានឆ្នូតៗ ព្រលែត ។

**ជីវសាស្ត្រ** : ជាទូទៅ វាច្រើនតែរស់នៅក្នុងតំបន់ព្រៃភ្នំដែលមានរយៈកំពស់ប្រហែល ៧០០ម វារស់នៅតែឯង ឬ រស់នៅជាក្រុមតូចៗសត្វនេះវាមាន ជំរកនៅក្នុងរន្ធឈើ ចំណីអាហាររបស់វាមានផ្លែឈើ ដូងបន្លែ សត្វល្អិត។

**រចាយ និង ស្ថានភាព** : ជាប្រភេទសត្វសំបូរ មានគ្រប់ទីកន្លែង ។



# ៧៩.កំខ្ទន Berdmore's Squirrel *Menetes berdmorei*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួនប្រហែល ៨៤ ម.ម កន្ទុយ ១៤០ ម.ម

**ពិពណ៌នា** : វាមានមាឌតូចមធ្យម ដងខ្លួនទ្រវែសជាងសត្វកណ្ដុរ និងមានពណ៌ប្រផេះឆ្នូតស្រអាប់ នៅផ្នែកចំហៀង ។ មានកន្ទុយខ្លីជាងដងខ្លួន រោមខាងលើមានពណ៌ប្រផេះក្រហមទុំ ។ ចំពោះសត្វញីមានដោះបីគូ ។

**ជីវសាស្ត្រ** : វារកចំណីនៅលើដីក្នុងព្រៃស្ទើរគ្រប់ប្រភេទ ក្នុងចំការ ។ ចំណីអាហាររបស់វាមានស្រូវ ពោត ចេក ។

**ទោឃ និង ស្ថានភាព** : ជាប្រភេទសត្វមានជាមធ្យម ស្ទើរគ្រប់ទីកន្លែង ។



# ៨០.កំប្រុកស្លាបធំ

## Indian Giant Flying Squirrel
*Petaurista philippensis*

**ទំហំ :** ប្រវែងក្បាល-ដងខ្លួន ៣៩៨-៤៤៩ ម.ម     កន្ទុយ ៤៨៥-៥៧០ ម.ម

**ភិនភាគ** : សត្វប្រភេទនេះមានពណ៌ប្រផេះត្នោត ឬ ក្រម៉ៅនិងមានពណ៌ខ្មៅនៅកន្ទុយ ។ នៅផ្ទៃខាងខ្នងមានរោម ច្រើន ជាពិសេសថ្ពាស និងស្មា ។ ភ្នាសស្លាបភ្ជាប់ពី ក ជើងមុខ ទៅ ក ជើងក្រោយរហូតដល់កន្ទុយ ។

**ជីវសាស្ត្រ** : ប្រភេទនេះធ្វើសំបុកនៅក្នុងប្រហោងឈើ ឬ តាមច្រាំងថ្មចោត ។ ការរស់នៅនិងរកស៊ី នៅក្នុងព្រៃ ស្រោង ។ កើតកូនម្តងបានមួយ ។

**របាយ និង ស្ថានភាព** : មានដោយកម្រ ជាប្រភេទសត្វហាមបរបាញ់ក្នុង ប្រកាសលេខ ៣៥៩ ប្រក.កសក. ក្រសួង កសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។



## ៨១.កំប្រុកស្លាបថ្ពាល់ក្រហម

**Red-cheeked Flying Squirrel**
*Hylopetes spadiceus*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ១៣០-១៦៥ ម.ម កន្ទុយ ១០០-១៤០ ម.ម

**រូបភាព** : គឺជាប្រភេទសត្វកំប្រុកស្លាបតូចមួយដែលមានពណ៌លឿងទុំ ផ្នែកលើ ។ រោមផ្នែកខាងក្រោមមានពណ៌ខ្មៅ ភ្នាសស្បែកនៃស្លាប ផ្នែកខាងលើមានពណ៌ខ្មៅ ។ វាមានកន្ទុយរាងសំប៉ែត ដូចស្លាបសត្វពណ៌ទឹកក្រូច ព្រលែត ហើយថ្ពាល់មានពណ៌ត្នោត ឬលាយពណ៌ទឹកក្រូច ជួនកាលមានពណ៌សនៅខាងចុងកន្ទុយ ។

**ជីវសាស្ត្រ** : វាជាប្រភេទសត្វដែលរស់នៅក្នុងតំបន់ព្រៃស្រោង ជួនកាលវារស់នៅលើដើមឈើស្ថិតនៅតាមបណ្តោយដងផ្លូវ ។ វាធ្វើសំបុកក្នុងរន្ធឈើរស់ ឬដើមដូង ។ ជាទូទៅរន្ធវាមានកំពស់ពីដីប្រហែល ៣-៤ ម៉ែត្រ និងអាចបង្កើតកើតកូនម្តងបានពីរ ។ វាជាសត្វរាត្រីចរ ។ ស៊ីផ្លែឈើ ជាអាហារ ។

**របាយ និង ស្ថានភាព** : មានជាមធ្យម នៅតំបន់ភ្នំ ក្រវាញ ។

## ៨២.កំប្រុកស្លាបត្លំ

**Particoloured Flying Squirrel**
*Hylopetes alboniger*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ១៩៥-២១០ម.ម កន្ទុយ ១៨១-២០០ ម.ម

**រូបភាព** : វាមានមាឌធំជាង កំប្រុកថ្ពាល់ក្រហមបន្តិច មានសំបុរត្នោត កន្ទុយព្រលែត ។

**ជីវសាស្ត្រ** : វាជាប្រភេទកំប្រុកស្លាបរស់នៅលើភ្នំពួកវាក៏មានឃើញក្នុងប្រភេទព្រៃចំរុះដែលមានដើមល្វា ផងដែរ ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វកម្រ មានរស់នៅខាងកើតទន្លេមេគង្គ និងត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក ។





# ៨៣.កណ្ដុរផ្ទះ(កណ្ដុរបង្គន់) House Rat *Rattus rattus*

**ទំហំ** : ក្បាលដងខ្លួន ១២៥-២០៥ មម   កន្ទុយ ១៨៨មម   ទម្ងន់ ៨៥-២៨០ ក្រ

**ពិពណ៌នា** : ផ្នែកខាងលើដងខ្លួនមានពណ៌ត្នោតខ្ចី ខាងក្រោមមានពណ៌ប្រផេះត្នោត ឬសសុទ្ធ និងមានពិណាខ្មៅ ជិតនៅត្រង់ទ្រូង ។ច្រមុះស្រួច ស្លឹកត្រចៀកធំរោមគ្រើមនិងពុំមាន ប្រែងនៅផ្នែកខាងខ្នងទេ ។កន្ទុយវាពណ៌ត្នោតចាស់ ។

**ជីវសាស្ត្រ** : រស់នៅជិតស្និទ្ធជាមួយមនុស្ស ។ ជំរកវាគឺ ធំការ ភូមិករ ផ្ទះសំបែង ព្រៃឬស្សី ឃ្លាំង និងជំរកធម្មជាតិឯទៀត លើកលែងតែ ព្រៃតំបន់ភ្នំ ។ វាជាប្រភេទ តែមួយគត់ដែលអាចរស់នៅបានតាមវាលភក់ ព្រៃកោងកាង និង មានដោះពាគូ ។ វាមានគភិស្ទើរតែរៀងរាល់ខែ ដោយគ្មានកំណត់រដូវកាលច្បាស់លាស់ ។ មានគភិរយៈពេល ២១ ថ្ងៃ អាចបន្តពូជបាននៅអាយុ ៨០ ថ្ងៃ អាយុកាលរបស់វាដល់ ៤ ឆ្នាំ ។ វាធ្វើសំបុក ដោយប្រើប្រាស់មែកឈើ ឫស្សីករុក្ខជាតិ ខោអាវ និង សម្ភារៈផ្សេងៗទៀត ។ ចំណីអាហារគឺ ដូង រុក្ខជាតិ ផ្លែឈើ សត្វ និង ចំណីឯទៀត ។

**ទោយ និង ស្ថានភាព** : ជាប្រភេទសំបូរ និងមានស្ទើរគ្រប់ទីកន្លែង ។



# ៨៤.កណ្តុរទំប្រែង

**Large Bandicoot Rat**
***Bandicota indica***

**ទំហំ :** ក្បាលដងខ្លួន ២០០-៣០០ ម ម   កន្ទុយ ២៤៤មម   ទម្ងន់ ៥៤៥ ក្រ

**ពិពណ៌នា** : ផ្នែកខាងខ្នងមានរោមពណ៌ខ្មៅវែងក្រាស់ ខាងក្រោម មានពណ៌ប្រផេះ ។

ប្រភេទនេះអាចមានការប្រែប្រួល ពណ៌ពីប្រផេះងងឹត ទៅប្រផេះត្នោត ។ កន្ទុយមានពណ៌ត្នោតចាស់ ។ ជើងទាំងបួន វែង និង ពណ៌ខ្មៅ រីឯប្រម៉ាមជើង ស ក្រចកពុំស្ទួរកោង ។ ទំរង់មុខមូលទ្រវែង ។

**ជីវសាស្ត្រ** : មានរន្ធនៅក្នុងដី ធំទូលាយ ដែលមានផ្លូវចូលពី ២ - ៦ មាត់រូងមានអង្កត់ផ្ចិតប្រហែល ១៣ ស.ម រន្ធរបស់វាច្រើននៅតាមបណ្តោយផ្លូវ វាលស្រែ ។ វារស់នៅតាមវាលភក់ មាត់បឹងវាលស្រែ ភូមិករ ជួនកាលគេ ឃើញមានធ្វើសំបុកនៅក្បែរដំបូក ។ វាជាសត្វរាត្រីចរ នៅពេលថ្ងៃវាដេក សំងំ ក្នុងរូងដើម្បីលាក់ខ្លួន ។ វារស់នៅតែឯង ឬ ជាក្រុមតូចៗ វាផ្ទុកចំណី អាហារនៅក្នុងរូង វាជាសត្វពូកែហែលទឹក ។ ចំណីអាហារមាន : រុក្ខជាតិ ដំណាំ គ្រាប់ធញ្ញជាតិ អំពៅ សត្វល្អិត និង សត្វឥតឆ្អឹងកង ។ នៅតាមមាត់រូងខ្លះ គេតែងសង្កេតឃើញមានគំនរ សំបកធញ្ញជាតិ និងសំបកខ្យងត្រី លាស ក្តាម ។ ជួនកាលវាស៊ីគ្រាប់ស្រូវព្រោះក្នុងស្រែមុនពេលចេញពន្លក ។ វាចូលចិត្តកាត់ស្រូវក្នុងស្រែ ។ សត្វញីមានដោះបីគូ ។

**រចាយ និង ស្ថានភាព** : ជាប្រភេទសំបូរ មានស្ទើរគ្រប់ទីកន្លែង ។





# ៨៥.កណ្ដុរត្នុំ

**Large Bamboo Rat**
*Rhizomys sumatrensis*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ២៨០-៤៨០ ម.ម ទម្ងន់ ២-៤ គ.ក្រ

**ពិពណ៌នា** : កណ្ដុរភ្នំធំមានសម្បុរផ្នែកខាងខ្នងពណ៌ត្នោតព្រលែត ហើយភ្លឺថ្លាជាងផ្នែកខាងក្រោម ខ្លួនមានរោមខ្លី នៅផ្នែកពោះ កន្ទុយគ្មានរោមហើយវែងជាងកន្ទុយកណ្ដុរប្រភេទផ្សេង ទៀត នៅផ្នែកចុងខាងកន្ទុយមាន ពណ៌ផ្កាឈូក និងមានក្រញ៉ាំជើងធំ ។

**ជីវសាស្ត្រ** : វាមានធ្មេញនិងជើងរឹងមាំ ហើយចូលចិត្តរស់នៅក្នុងរន្ធដីនៃព្រៃដែលធ្វើអាជីវកម្មរួច ឬនៅក្រោម គុម្ពឫស្សី ដោយពួនសំងំក្នុងពេលថ្ងៃ និងចេញរកស៊ីក្នុងពេលយប់ ។ ចំណីអាហាររបស់វាភាគច្រើនឫស្សី និងទំពាំង និងស៊ីអំពៅក្នុងចំការ ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វសំបូរជាមធ្យម នៅភាគខាងកើតនិងខាងលិចទន្លេមេគង្គ ។





# ៨៦.ប្រម៉ា East Asian Porcupine *Hystrix brachyura*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៦៣៥-៧២៥ ម.ម ទំងន់ ៨ គ.ក្រ

**ភិនភាគ** : ប្រម៉ាជាសត្វកកេរធំមួយក្នុងចំណោមសត្វកកេរផ្សេងៗទៀត និងមានដងខ្លួនខ្លី ត្រចៀកតូច ។ ដងខ្លួន ផ្នែកខាងលើ និងកន្ទុយគ្រប ដណ្តប់ដោយរោមបន្លាធំៗ និងវែងៗ(កាំ)ដែលមានប្រវែងពី ២០០-២៥០មម ។ រោមបន្លារបស់វាភាគច្រើនមានពណ៌ខ្មៅកណ្តាល សចុង និង គល់ ហើយមានចំនួនតិចតួច មានពណ៌ខ្មៅ នៅផ្នែកគល់ និងសនៅ ផ្នែកចុងនៃកាំរបស់វា ។ ម្រាមជើងខ្លីហើយធំនិងមានក្រចកមាំ ។ កន្ទុយខ្លីហើយធំគ្របដណ្តប់ដោយកាំ ។

**ជីវសាស្ត្រ** : វារស់នៅគ្រប់ប្រភេទនៃព្រៃ ក្នុងរូងដីស្ងួត។ ជាសត្វឆាប់ផ្អើលនិងមានទំលាប់ចេញរកស៊ី នៅពេលយប់។ ចំណីអាហាររបស់វា មានឫសឈើ មើមរុក្ខជាតិ ផ្លែឈើទុំជ្រុះ និង សំបកឈើ។ វាអាចកកេរបំបែកឆ្អឹង សាកសព ដើម្បីស៊ីខួរឆ្អឹង ខាងក្នុងបាន ។

**រចាយ និង ស្ថានភាព** : ជាប្រភេទសត្វមានជាមធ្យម មានស្ទើរគ្រប់ទីកន្លែង ។ ជាប្រភេទសត្វដែលហាមបរបាញ់ ក្នុងប្រកាសលេខ ៣៥៩ ប្រក.កសក. របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និង ត្រូវបានចុះក្នុងបញ្ជីក្រហម IVCN (GT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក ។





# ៨៧.ប្រម៉ោញ

**Asian Brush-tailed Porcupine**
***Atherurus macrourus***

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៣៨១-៥២៥ ម.ម   កន្ទុយ ១៣៥-២២៨ ម.ម

**ភិនភាគ** : មានរូបរាង និងទ្រង់ទ្រាយដូចសត្វប្រម៉ាដែរ តែតូចជាង ។ ផ្នែកខាងលើនៃដងខ្លួនមានរាង សំប៉ែត និងគ្របដណ្ដប់ដោយរោមដូចបន្លា (កាំ) ។ កន្ទុយតូចមានប្រវែងប្រហែលពីរភាគបីនៃដងខ្លួន នៅចុងកន្ទុយមានរោមបន្លាជាកញ្ចុំដូចអំបោស ។ រោមបន្លារបស់វាមានពណ៌ត្នោតចាស់ ហើយវែងនៅ ផ្នែកខាងលើខ្នង និងមានពណ៌ភ្លាវ ហើយខ្លីនៅផ្នែកខាងក្រោមពោះ ។

**ជីវសាស្ត្រ** : វារស់នៅក្នុងព្រៃចំការ ជាពិសេសតំបន់ខ្ពស់ តំបន់ព្រៃតាមមាត់ស្ទឹង បឹង និងជ្រោក ក្រោមគម្ពោតព្រៃ ក្រោមឫសឈើ ឬក្រោមក្រហែងថ្មក្បែរពំនូកដីជិតមាត់ទឹក វាពុំចូលចិត្តដីវាលទេ ។ ជាទូទៅវាសំងំ ក្នុងរូងដី ឬល្អាងថ្មក្នុងពេលថ្ងៃ ហើយចេញរកស៊ីពេលយប់ ។ ពេលខ្លះវារស់នៅជាហ្វូងក្នុងរូងតែមួយ ក្នុងរយៈពេលច្រើនឆ្នាំ ។ វាកំណត់ព្រំដែនរស់នៅរបស់វាដោយពំនូកលាមក ។ វាអាចរត់បានលឿន និងអាចហែលទឹកបានយ៉ាងស្ទាត់ជំនាញទៀតផង ។ ប្រម៉ោញក៏អាចឡើងដើមឈើបានដែរ ។ ចំណី អាហាររបស់វាមាន ប្រទាល ឫសឈើ មើមឈើ ផ្លែឈើ គ្រាប់ធញ្ញជាតិ ដំណាំក្នុងចំការ សំបកនៃប្រភេទឈើខ្លះ សាកសព(ឆ្អឹង) ។ វាមានអាយុកាលរហូតដល់ ២២-២៣ឆ្នាំ ។ ចំពោះសត្វញីអាចបង្កើតកូនម្តងបានពី ៣-៤ក្បាល ក្នុងមួយសារ ហើយក្នុងមួយឆ្នាំវាអាចបង្កើតកូនបាន ២-៣ដង ។ កូនតូចអាចបើកភ្នែកបាន ក្រោយពេលកើតបានមួយម៉ោង និងអាចស៊ីចំណីអាហាររឹងបាន ពេលវាមានអាយុ ២-៣សប្តាហ៍ ។

**របាយ និង ស្ថានភាព** : ប្រម៉ោញជាប្រភេទសត្វមានជាមធ្យម ស្ទើរគ្រប់ទីកន្លែង ។





# ៨៨.ទន្សាយគល់ Siamese Hare *Lepus peguensis*

**ទំហំ** : ប្រវែងក្បាល-ដងខ្លួន ៤៤០-៥០០ ម.ម ទំងន់ ១,៥ -៧ គ.ក

**រូបភាព** : ទន្សាយគល់មានមាឌតូចជាង ប្រភេទទន្សាយនៅក្នុងប្រទេសប៉ែកអឺរ៉ុប បីដង ។ សម្បុរវាមានពណ៌ត្នោតខ្ចី នៅផ្នែកខាងលើ និងពណ៌ស នៅផ្នែកខាងក្រោម ។ ចំណែកកន្ទុយមានពីរ ពណ៌ខុសគ្នា គឺផ្នែកខាង លើពណ៌ត្នោត និង ផ្នែកខាងក្រោម ពណ៌ស ។ ស្លឹកត្រចៀកមានពណ៌ប្រផេះ ហើយ ខាងចុងមានពណ៌ខ្មៅ ។

**ជីវសាស្ត្រ** : វាមានជំរកក្នុងព្រៃរបោះ វាលស្មៅធំៗ ចំការដំណាំ ដីចោះបង់ចោល ។ វាពុំមានជំនាញខាងកកាយ ឬជីករន្ធទេ ។ ជាសត្វរស់នៅតែម្នាក់ឯង ហើយពុំសូវផ្លាស់ប្តូរទីកន្លែង វាចូលចិត្តរស់នៅក្នុងគម្ពោតព្រៃ និងស្មៅខ្ពស់ៗ។ វាមានភាពរហ័សរហួន ក្នុងការរត់គេច ឬ គេចវេះពីសត្រូវ។ វាលាក់ខ្លួននៅពេលថ្ងៃ ក្នុងគម្ពោតព្រៃខ្ពស់ៗ ហើយចេញរកស៊ីនៅពេលល្ងាច ឬ ពេលយប់ ។ ចំណីអាហាររបស់វាមាន សំបកឈើ មែកឈើតូចៗ ត្រួយរុក្ខជាតិ និងស្មៅ ។ វាមានអាយុកាលរហូតដល់ ៦ឆ្នាំ ។

**របាយ និង ស្ថានភាព** : ជាប្រភេទសត្វសំបូរ មានស្ទើរគ្រប់ទីកន្លែង ។ ជាប្រភេទហាមការបរបាញ់ ដោយប្រកាស លេខ ៣៥៩ ប្រក.កសក របស់ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។



## V- សំរាប់ការអានបន្ថែមៈ

ដើម្បីសិក្សាបន្ថែមអំពីថនិកសត្វក្នុងតំបន់ និងការអភិរក្ស អ្នកអានដែលមានចំណាប់អារម្មណ៍ អាចរកអត្ថបទទាំងនេះ បាននៅបណ្ណាល័យ អង្គការ សមាគមអភិរក្សសត្វព្រៃ (WCS) ផ្ទះលេខ ៤ ផ្លូវ៣១២ ភ្នំពេញ ។


Carwardine, M. (1995). *Whales, Dolphins and Porpoises.* Dorling Kindersley. London and New York.

Duckworth, J. W., Salter, R. E. and Khounboline, K. (compilers) (1999). *Wildlife in Lao PDR: 1999 Status Report.* Vientiane: IUCN-The World Conservation Union / Wildlife Conservation Society / Centre for Protected Areas and Watershed Management.

Duckworth, J.W. and Hedges, S. (1998). *Tracking Tigers: A review of the status of Tiger, Asian Elephant, Gaur and Banteng in Vietnam, Lao, Cambodia and Yunnan (China), with recommendations for future conservation action.* WWF Indochina. Hanoi.

Corbett, G.B. and Hill, J.E. (1992). *The Mammals of the Indomalayan Region: A systematic review.* Oxford University Press. Oxford.

Graham, M. and Round, P.D. (1994) *Thailand's vanishing flora and fauna.* Finance One. Bangkok.

Lekagul, B. and McNeely, J.A (1977). *Mammals of Thailand.* Association for the Conservation of Wildlife. Bangkok.

Payne, J., Francis, C.M. and Phillipps, K. (1985). *A field guide to the mammals of Borneo.* The Sabah Society and WWF Malaysia. Kota Kinabalu.

Pfeffer, P. (1969) Considerations sur l'ecologie des forets claires du Cambodge oriental. *Terre et Vie* 1969 (1): 3-24.

Wharton, C. H. (1957). *An ecological study of the Kouprey* Novibos sauveli *(Urbain).* Manila: Institute of Science and Technology (monograph 5).

# VI- វិធីសាស្ត្រមើលបញ្ជីឈ្មោះថនិកសត្វ

**CITES** (Convention on International Trade in Endangered Species of Flora and Fauna) គឺជាអនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្ម អន្តរជាតិ លើប្រភេទជិតផុតពូជនៃសត្វ និង រុក្ខជាតិ ។ នៅក្នុងអនុសញ្ញានេះមានចែកជាបីឧបសម្ព័ន្ធ ដើម្បីគ្រប់គ្រងការធ្វើពាណិជ្ជកម្ម ជាលក្ខណៈអន្តរជាតិគឺ :

**ឧបសម្ព័ន្ធទី I :** ការធ្វើពាណិជ្ជកម្មលើសំណាក ឬផ្នែកណាមួយរបស់វាអាចអនុញ្ញាតទៅបានតែក្នុងលក្ខណៈពិសេសមួយគត់ ចំពោះប្រភេទរងការគំរាមកំហែង ឈានទៅរកការផុតពូជ ។

**ឧបសម្ព័ន្ធទី II :** ការធ្វើពាណិជ្ជកម្មលើសំណាក ឬ ផ្នែកណាមួយ របស់វា ត្រូវស្ថិតក្នុងការត្រួតពិនិត្យតាមច្បាប់យ៉ាងតឹងរឹងបំផុត ចំពោះប្រភេទដែលនឹងទទួលរងការគំរាមកំហែង ឈានទៅរកការផុតពូជ ។

**ឧបសម្ព័ន្ធទី III :** ការធ្វើពាណិជ្ជកម្មលើសំណាក ឬ ផ្នែកណាមួយរបស់វាត្រូវយោងទៅតាមច្បាប់ ចំពោះប្រភេទដែលតំរូវកំណត់ឱ្យធ្វើអាជីកម្ម ។

**ស្ថានភាពគំរាមកំហែង** (IUCN Threatened Status)

ស្ថានភាពគំរាមកំហែងជាទូទៅនៅក្នុងពិភពលោករួមមាន :

GT : ជាប្រភេទដែលទទួលរងការគំរាមកំហែងលើពិភពលោក

NT : ជាប្រភេទជិតទទួលរងការគំរាមកំហែងលើពិភពលោក

DD : ជាប្រភេទដែលពុំទាន់មានទិន្នន័យគ្រប់គ្រាន់

**ស្ថានភាពក្នុងប្រទេស** (Status in Cambodia )

C : ជាប្រភេទដែលបានកត់ត្រាដោយអ្នកវិទ្យាសាស្រ្ត

C? : ជាប្រភេទដែលមាននៅកម្ពុជា ប៉ុន្តែពុំមានការកត់ត្រានៅឡើយ

: ជាប្រភេទដែលមានក្នុងតំបន់ជិតខាង នឹង ប្រហែលជាអាចមានក្នុងប្រទេសកម្ពុជា

# បញ្ជីឈ្មោះថនិកសត្វ

| | ឈ្មោះខ្មែរ | English Name | Scientific name | IUCN | CITES | Status |
|---|---|---|---|---|---|---|
| ១ | ពង្រូល | Sunda Pangolin | *Manis javanica* | NT | II | C |
| ២ | កណ្ដុរស្អុយ | House Shrew | *Suncus murinus* | | | C |
| ៣ | កន្ធើក | Northern Treeshrew | *Tupaia belangeri* | | II | C |
| ៤ | កន្ធើកក្បាលឆ្នូត | Northern Smooth-tailed Treeshrew | *Dendrogale murina* | | II | C |
| ៥ | ម្ភាធ | Sunda Colugo | *Cynocephalus variegatus* | | | |
| ៦ | ប្រឹងកោះ | Island Flying-fox | *Pteropus hypomelanus* | | II | C |
| ៧ | ប្រឹងមធ្យម | Lyle's Flying-fox | *Pteropus lylei* | | II | C |
| ៨ | ប្រឹងធំ | Large Flying-fox | *Pteropus vampyrus* | | II | |
| ៩ | ប្រឹងអង្គាម | Greater Long-tongued Fruit Bat | *Macroglossus sobrinus* | | | C |
| ១០ | ប្រចៀវ | Tomb Bat | *Taphozous theobaldi* | | | C |
| ១១ | ប្រចៀវ | Lesser False Vampire Bat | *Megaderma spasma* | | | C |
| ១២ | ប្រចៀវ | Bornean Horseshoe Bat | *Rhinolophus borneensis* | | | C |
| ១៣ | ប្រចៀវ | Thick-thumbed Whiskered Bat | *Myotis rosseti* | NT | | C |
| ១៤ | ប្រចៀវ | Wrinkle-lipped bat | *Tadarida plicata* | | | C |
| ១៥ | ខ្ញើប្រហើរ | Slow Loris | *Nycticebus coucang* | | II | C |
| ១៦ | ស្វាក្រោស | Pig-tailed Macaque | *Macaca nemestrina* | GT | II | C |

| | ឈ្មោះខ្មែរ | English Name | Scientific name | IUCN | CITES | Status |
|---|---|---|---|---|---|---|
| ១៧ | ស្វាក្ដាម | Long-tailed Macaque | *Macaca fascicularis* | NT | II | C |
| ១៨ | ស្វាអង្កត់ | Stump-tailed Macaque | *Macaca arctoides* | GT | II | C |
| ១៩ | ស្វាព្រាម | Silvered Langur | *Semnopithecus cristatus* | NT | II | C |
| ២០ | ស្វាក្រវ៉ាត់ | Douc Langur | *Pygathrix nemaeus* | GT | I | C |
| ២១ | ទោចមួង | Pileated Gibbon | *Hylobates pileatus* | GT | I | C |
| ២២ | ទោចថ្ពាល់លឿង | Yellow-cheeked Gibbon | *Hylobates gabriellae* | DD | I | C |
| ២៣ | ឆ្កែចចក | Asiatic Jackal | *Canis aureus* | | II | C |
| ២៤ | ឆ្កែព្រៃ | Dhole | *Cuon alpinus* | GT | II | C |
| ២៥ | ខ្លាឃ្មុំធំ | Asiatic Black Bear | *Ursus thibetanus* | GT | I | C |
| ២៦ | ខ្លាឃ្មុំតូច | Sun Bear | *Ursus malayanus* | DD | I | C |
| ២៧ | សំពោចកលឿង | Yellow-throated Marten | *Martes flavigula* | | III | C |
| ២៨ | ជ្រូកពោន. ជ្រូកព្រុល | Hog Badger | *Arctonyx collaris* | | | C |
| ២៩ | ឆ្មក | Large-toothed Ferret Badger | *Melogale personata* | | | C |
| ៣០ | ភេក្បាលសរីប៉ត | Eurasian Otter | *Lutra lutra* | | I | |
| ៣១ | ភេរោមច្រមុះ | Hairy-nosed Otter | *Lutra sumatrana* | GT | II | C |
| ៣២ | ភេខ្ទួនរលោង | Smooth Otter | *Lutrogale perspicillata* | GT | II | C |
| ៣៣ | ភេតូច | Oriental Small-clawed Otter | *Aonyx cinerea* | NT | II | C |

| | ឈ្មោះខ្មែរ | English Name | Scientific name | IUCN | CITES | Status |
|---|---|---|---|---|---|---|
| ៣៤ | ទ្វីង | Large Indian Civet | *Viverra zibetha* | | III | C |
| ៣៥ | សំពោចធំ | Large-spotted Civet | *Viverra megaspila* | | | C |
| ៣៦ | សំពោចស្ញី.ឈ្មុសស្ញី | Small Indian Civet | *Viverricula indica* | | III | C |
| ៣៧ | សំពោចក្រអូប.សំពោចត្នោត | Common Palm Civet | *Paradoxurus hermaphroditus* | | III | C |
| ៣៨ | សំពោចពណ៌ពោត | Masked Palm Civet | *Paguma larvata* | | III | C |
| ៣៩ | ឈ្មុសប្រេង | Binturong | *Arctictis binturong* | | III | C |
| ៤០ | សំពោចអុចខ្នង | Small-toothed Palm Civet | *Arctogalidia trivirgata* | | | C |
| ៤១ | កំពឹងឆ្នូត | Owston's Civet | *Hemigalus owstoni* | GT | | C |
| ៤២ | ស្កាតូច | Small Asian Mongoose | *Herpestes javanicus* | | | C |
| ៤៣ | ស្កាធំ | Crab-eating Mongoose | *Herpestes urva* | | III | C |
| ៤៤ | ឆ្មាព្រៃ | Jungle Cat | *Felis chaus* | | II | C |
| ៤៥ | ឆ្មាដាវ | Leopard Cat | *Prionailurus bengalensis* | | I | C |
| ៤៦ | ខ្លាត្រី | Fishing Cat | *Prionailurus viverrinus* | NT | II | C |
| ៤៧ | ខ្លាឈឿងមាស | Asian Golden Cat | *Catopuma temminckii* | NT | I | C |
| ៤៨ | ខ្លាក្រិថ្មកែវ | Marbled Cat | *Pardofelis marmorata* | DD | I | C |
| ៤៩ | ខ្លាពពក | Clouded Leopard | *Neofelis nebulosa* | GT | I | C |
| ៥០ | ខ្លារខិន | Leopard | *Panthera pardus* | | I | C |

| | ឈ្មោះខ្មែរ | English Name | Scientific name | IUCN | CITES | Status |
|---|---|---|---|---|---|---|
| ៥១ | ខ្លាធំ (ខ្លាដំបង) | Tiger | *Panthera tigris* | GT | I | C |
| ៥២ | ផ្សោតពណ៌ផ្កាឈូក | Indo-Pacific Hump-backed Dolphin | *Sousa chinensis* | DD | I | C? |
| ៥៣ | ផ្សោតបង្វិល | Spinner Dolphin | *Stenella longirostris* | | II | C? |
| ៥៤ | ផ្សោតខ្មៅ-លឿង | Common Dolphin | *Delphinus delphis* | | II | |
| ៥៥ | ផ្សោតច្រមុះដប | Bottle-nosed Dolphin | *Tursiops truncatus* | | II | |
| ៥៦ | ផ្សោតទន្លេ | Irrawaddy Dolphin | *Orcaella brevirostris* | DD | II | C |
| ៥៧ | ផ្សោតគ្មានព្រុយខ្នង | Finless Porpoise | *Neophocaena phocaenoides* | DD | I | C |
| ៥៨ | ជ្រូកទឹក | Dugong | *Dugong dugon* | GT | I | C |
| ៥៩ | ដំរី | Asian Elephant | *Elephas maximus* | GT | I | C |
| ៦០ | រមាសកុយ ១ | Javan Rhinoceros | *Rhinoceros sondaicus* | GT | I | C |
| ៦១ | ជ្រូកព្រៃ | Wild Pig | *Sus scrofa* | | | C |
| ៦២ | ក្ដាន់ទ្រៀងតូច-ផ្លុងតូច | Lesser Mousedeer | *Tragulus javanicus* | | | C |
| ៦៣ | ក្ដាន់ទ្រៀងធំ-ផ្លុងធំ | Greater Mousedeer | *Tragulus napu* | | | |
| ៦៤ | រមាំង | Eld's Deer | *Cervus eldii* | GT | I | C |
| ៦៥ | ប្រើស | Sambar | *Cervus unicolor* | | | C |
| ៦៦ | ក្ដាន់ | Hog Deer | *Axis porcinus* | DD | I | C |

|  | ឈ្មោះខ្មែរ | English Name | Scientific name | IUCN | CITES | Status |
|---|---|---|---|---|---|---|
| ៦៧ | ឈ្លូស | Red Muntjac | *Muntiacus muntjak* |  |  | C |
| ៦៨ | ឈ្លូសយក្ស | Large-antlered Muntjac | *Muntiacus vuquangensis* |  | I | C? |
| ៦៩ | គោព្រៃ | Kouprey | *Bos sauveli* | GT | I | C |
| ៧០ | ខ្ទីង | Gaur | *Bos gaurus* | GT | I | C |
| ៧១ | ទន្សោង | Banteng | *Bos javanicus* | GT |  | C |
| ៧២ | ក្របីព្រៃ | Wild Water Buffalo | *Bubalus arnee* | GT |  | C |
| ៧៣ | ខ្ទីងវល្លិ, ខ្ទីងពស់ | Khting Vor | *Pseudonovibos spiralis* | GT |  | C? |
| ៧៤ | កែះ | Southern Serow | *Naemorhedus sumatraensis* | GT | I | C |
| ៧៥ | កំប្រុកធំ | Black Giant Squirrel | *Ratufa bicolor* |  | II | C |
| ៧៦ | កំប្រុកឆ្នូតខ្នង | Pallas's Squirrel | *Callosciurus erythraeus* |  |  | C? |
| ៧៧ | កំប្រុកពណ៌ | Variable Squirrel | *Callosciurus finlaysonii* |  |  | C |
| ៧៨ | កង្ហិប | Cambodian Striped Squirrel | *Tamiops rodolphii* |  |  | C |
| ៧៩ | កង្ហូន | Berdmore's Squirrel | *Menetes berdmorei* |  |  | C |
| ៨០ | កំប្រុកស្លាបធំ | Indian Giant Flying Squirrel | *Petaurista philippensis* |  |  | C |
| ៨១ | កំប្រុកស្លាបថ្ពាល់ក្រហម | Red-cheeked Flying Squirrel | *Hylopetes spadiceus* |  |  | C |

| | ឈ្មោះខ្មែរ | English Name | Scientific name | IUCN | CITES | Status |
|---|---|---|---|---|---|---|
| ៨២ | កំប្រុកស្លាបភ្លឺ | Particoloured Flying Squirrel | *Hylopetes alboniger* | GT | | |
| ៨៣ | កណ្ដុរ(ផ្ទះ) | House Rat | *Rattus rattus* | | | ( |
| ៨៤ | កណ្ដុរព្រែង | Large Bandicoot Rat | *Bandicota indica* | | | ( |
| ៨៥ | កណ្ដុរភ្លូធំ | Large Bamboo Rat | *Rhizomys sumatrensis* | | | (? |
| ៨៦ | ប្រមាំ | East Asian Porcupine | *Hystrix brachyura* | GT | | ( |
| ៨៧ | ប្រម៉ាញ | Asian Brush-tailed Porcupine | *Atherurus macrourus* | | | ( |
| ៨៨ | ទន្សាយគល់ | Siamese Hare | *Lepus peguensis* | | | ( |


WCS
WILDLIFE CONSERVATION SOCIETY